# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ៣៣ លេខ ៣ ខែមីនា

ព.ស. ២៥០៣ គ.ស. ១៩៦១

ភ្នំពេញ

## ពុទ្ធសាសនា និងពុទ្ធសាសនិកបានទទួល
## ព្រះបរមរាជូបត្ថម្ភពីព្រះរាជបល្ល័ង្ក

កាលពីថ្ងៃទី ២ មីនា ១៩៦១ ក្នុងពេលដែលសម្ដេចព្រះប្រមុខរដ្ឋ ស្ដេចយាងទៅសម្ពោធបើកការហត្ថកម្មផ្លូវរាជអយស្មយាន ភ្នំពេញ ក្រុងព្រះសីហនុលើកទី ២ នៅឃុំប្រទះឡាំង, ព្រះអង្គទ្រង់បានព្រះរាជ-បរិច្ចាគព្រះរាជទ្រព្យផ្ទាល់ព្រះអង្គ ចំនួន ៥០០០៛០០ ក្នុងការកសាងព្រះវិហារ វត្តតាំងនោម ឃុំប្រទះឡាំង ស្រុកភ្នំពេញ ខេត្តកណ្ដាល ។

កាលពីថ្ងៃទី ២៨ មីនា ១៩៦១ សម្ដេចព្រះមហាក្សត្រិយានី ជាម្ចាស់ជីវិត ទ្រង់សព្វព្រះរាជហឫទ័យ ព្រះរាជទាននូវចីវរ ១៧ ស្បង់ ១៧ និងប្រាក់ ១២០០០៛ ដល់សហជីវិន សឹង-កៀក ថ ដើម្បីយកទៅប្រគេនព្រះសង្ឃ និងជូនជនរួមជាតិខ្មែរកម្ពុជាក្រោម ដែលភៀសខ្លួនមកនៅក្នុងដែន ស្រុកគិរីវង្ស ខេត្តតាកែវ ។

ព្រះរាជវិភាគទាននេះ ជាសក្ខីភាព បង្ហាញឲ្យឃើញព្រះរាជហឫទ័យ ប្រកបដោយព្រះរាជសទ្ធាជ្រះថ្លាចំពោះព្រះពុទ្ធសាសនា និងព្រហ្មវិហារ-ធម៌ចំពោះព្រះសង្ឃពុទ្ធសាសនិក និងកូនចៅព្រះអង្គដែលទទួលរងគ្រោះជាអាសន្ន ។

---

## ពិធីបុណ្យចំរើនព្រះជន្មាយុ

សម្ដេចព្រះមហាសុមេធាធិបតី (ជួន - ណាត ជោតញ្ញាណោ)
សង្ឃនាយកគណៈមហានិកាយ ក្នុងព្រះជន្មាយុគំរប់ ៧៧ ឆ្នាំ ។

កាលពីថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ ១០-១១ រោច ខែផល្គុណ ឆ្នាំជូត ទោស័ក ព.ស. ២៥០៣ (១១-១២ មីនា ១៩៦១) ក្រុមសិស្សានុសិស្ស ទាំងបព្វជិតទាំងគ្រហស្ថ បានប្រជុំគ្នា ធ្វើពិធីបុណ្យចំរើនព្រះជន្មវស្សា ប្រ-គេនសម្ដេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ ក្រោម

BIBLIOTHEQUE [illegible] EXPRESS ORIENT

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

ចេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា បញ្ជីរឿង ទំព័រ


- ពុទ្ធជីវប្បវត្តិ (តមក) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . ២៣៧
- ព្រះនិព្វាន ឬនិរ្វាណ លោកកុម្ម៉ង់ដង់ រូបែរត៍ រៀបរៀង ក្រមការ ជុំ-មៅ ប្រែ . ២៤៧
- ព្រះអភិធម្មបិដក គម្ពីរព្រះកថាវត្ថុ (តមក) លោក ប៊ូ-ប៉ូ រៀបរៀង . . . ២៥៨
- ចតុរសភិហិណី(ត)សម្តេចព្រះធម្មលិខិត ល្វី-ឯម ប្រែ ព្រះញ. ញាណ-ឈិន ពិនិត្យ ២៦៩
- មហោសថជាតក(ត):លោកអ៊ុម-ភនបម្រុងពីសាស្ត្រាស្លឹករឹតព្រះពុទ្ធវង្សកឹម-ធូរពិនិត្យ . ២៧៦


ផ្នែកអក្សរសាស្ត្រ


- វប្បធម៌ខ្មែរ (តមក) លោក លី-ធាមតេង រៀបរៀង . . . ២៨៤
- ពាក្យខ្មែរប្រែពីបារាំងសែស ដោយគណៈកម្មការវប្បធម៌ . . . . . . . . ២៩០
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . ២៩១
- រឿងសាមកុក (តមក) ឧកញ៉ា នូ-កន ប្រែ . . . . ២៩២
- រឿងព្រេងទាក់ទងដោយការស្ថាបនាប្រាសាទអង្គរ (ត) លោក ញ៉ែម-ទឹម រៀបរៀង . ៣០៤
- រឿងព្រេងប្រទេសចិន ចែងអំពីបព្វជិតនឹងដើមព័រ ភិក្ខុ ម៉ែន-វៀម ប្រែ . . ៣១៦
- រង្គើ ១ ធ្វើឲ្យបាត់គោអស់ លោកញូង-សឿង រៀបរៀង . . . . , ៣២២
- គតិព្យាយសុភាសិត លោក ញ៉ែម-ទឹម រៀបរៀង . . ; , , . . ៣៣២


ផ្នែកកំណត់ទិនប្រវត្តិការណ៍


- មហាសន្និបាត នៃពុទ្ធិកសមាគមមជ្ឈមណ្ឌលកម្ពុជរដ្ឋលើកទី ៩ . . . . . . ៣៣៨
- ពិធីសម្ពោធបើកការអប់រំវិជ្ជាគរុកោសល្យ . . . . . . . . . . . ៣៤៧


មួយឆ្នាំ មាន ១២ សៀវភៅ ដំឡៃជារ ២៣០ រ ០០

33e Année — N° 3 — Mars 1961

# KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire
publiée par l'Institut Bouddhique de Phnom-Penh

## Sommaire


### Partie religieuse

Pages

— La Vie du Buddha (suite) par Vèn. *PANG KHAT* . . . . 237
— Le Nirvana par le Commandant *ROBERT* . . . . . . . . 247
— Prah Abhidhammapitaka, Kampi de Preah Kathavathu (suite) par *M. BOU-PO* . . . . . 258
— Madhurasavahini (suite) par Samdech Preah Dhammalikhita *LOUIS-EM*, revu et corrigé par Vèn. *NHÉAN-CHHOEUN* . . . . 269
— Mahosatha Jataka (suite) relevé du manuscrit sur feuilles de latanier par *M. IM-PHON*, revu et corrigé par Vèn. *KEM-TO* . . . . 276

### Partie littéraire

— La Culture Khmère (suite) par *M. LY-THEAM-TENG* . . 284
— Activités de la Commission Culturelle . . . . . . . . . . . . . . 290
— Dictionnaire Sanscrit-Khmèr (suite) par Vèn. *PANG-KHAT* . . 291
— Histoire de Sam-Kok (suite) traduite par Oknha *NOU-KAN* . . . . . . . 292
— La Fondation d'Angkor d'après une légende khmère par *M. NHEM-KHEM* . . . . . 304
— Le bonze et le poirier (Contes et légendes de Chine) traduite par le bonze *MEN-RIEM* . . . . 316
— La disparition des bœufs (Conte khmère) d'après *M. NHOUNG-SŒUNG* . . . . 322
— Commentaire d'un proverbe par *M. NHEM-KHEM* . . . . . 332

### Notes et chroniques

— Le 9ème Congrès de l'Association des Bouddhistes Centre du Cambodge . . . 338
— Fête d'inauguration des Cours de pédagogie . . . . . . . . . . 347


Prix d'abonnement annuel (comprenant 12 numéros): 23o|oo

# ពរស័ព្ទសាធុការក្នុងឱកាសចូលឆ្នាំថ្មី

ក្នុងឱកាសចូលឆ្នាំឆ្លូវត្រីស័ក ជាឆ្នាំថ្មីនៃពុទ្ធសករាជ ២៥០៤ នេះ, ក្រុមពុទ្ធសាសនបណ្ឌិត្យ សូមបួងសួងចំពោះគុណព្រះរតនត្រ័យ នឹងវត្ថុស័ក្តិសិទ្ធិក្នុងលោក មានទេវតារក្សាស្វេតច្ឆត្រ, នឹងព្រះកែវមរកតនៃប្រទេសកម្ពុជាជាដើម ព្រមទាំងទេវតាព្រះនាម គិរិណីទេវា ដែលរក្សាឆ្នាំថ្មីនេះ សូមប្រសិទ្ធិពរថ្វាយ-ប្រគេន-ជូនចំពោះ៖

–សម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិត, សម្តេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋ ជាទីស្នេហាស្មើដោយជីវិត នៃប្រជាពលរដ្ឋខ្មែរ ព្រមទាំងព្រះរាជវង្សានុវង្ស សូមទ្រង់បានប្រកបដោយព្រះជោគជ័យសិរីមង្គលមហាប្រសើរ, ព្រះវឌ្ឍនភាព, ព្រះសុខមាលភាព នឹងព្រះជន្មាយុយឺនយូរអស់កាលជាអង្វែង ។

–សម្តេចក្រុមព្រះ ប្រធាន នឹងសមាជិក ក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក ព្រមទាំងគ្រួសារ ។

–សម្តេចព្រះសង្ឃនាយកទាំងពីរគណៈ ព្រមទាំងព្រះសង្ឃគ្រប់វត្តអារាមក្នុងប្រទេសកម្ពុជា ។

–សមាជិកព្រះរាជរដ្ឋាភិបាល ព្រមទាំងគ្រួសារ ។

ប្រធាននឹងសមាជិកសភាទាំងពីរ ព្រមទាំងគ្រួសារ ។

–អ្នករាជការគ្រប់ជាន់ថ្នាក់ ទាហាន - ស៊ីវិល ព្រមទាំងគ្រួសារ ។

–ប្រជាពលរដ្ឋ ពាណិជ្ជករ, កសិករ, កម្មករ ក្នុងព្រះរាជាណាចក្រទាំងមូល ព្រមទាំងគ្រួសារ ។

សូមបានប្រកបដោយសិរីសួស្តី នឹងជោគជ័យសេចក្តីសុខ..ចំរើន គ្រប់ប្រការកុំបីឃ្លាត ។

## ផ្នែកសាសនា

### ពុទ្ធជីវប្បវត្តិ

*ព្រះមហា ប៉ាង-ខាត់ រៀបរៀង*

(តមក)

### ៦– ទ្រង់ជាកូនមាន់ច្បង

*ព្រះភគវ័ទ្រង់បានឃើញពន្លឺមុនជាងមនុស្ស ទេវតា មារ ព្រហ្ម ដូចសេចក្ដីដែលទ្រង់ត្រាស់ចំពោះវេរញ្ជព្រាហ្មណ៍ថា*(១)

ម្នាលព្រាហ្មណ៍! ប្រៀបដូចសុតមាន់ទាំង ៨ ក្ដី ១០ ក្ដី ១២ ក្ដី សុតមាន់ទាំងនោះ គឺមេមាន់ក្រាបដោយប្រពៃហើយ ធ្វើឲ្យកក់ក្ដៅដោយប្រពៃហើយ ឲ្យបាប់ក្លិនវាជាមេដោយប្រពៃហើយ បណ្ដាកូនមាន់ទាំងនោះ កូនមាន់ណាទំលាយសំបកសុតដោយចុងក្រចកជើង ឬដោយចុងចំពុះ ហើយញាស់ចេញមកដោយស្រួលមុនគេបំផុត បើដូច្នេះតើ អ្នកផងគួរហៅកូនមាន់នោះថាកូនច្បងឬកូនពៅ? ព្រាហ្មណ៍ទូលថា បពិត្រព្រះគោតមដ៏ចំរើន កូនមាន់នោះ គេគួរហៅថា កូនច្បង ព្រោះវាជាកូនបងគេបំផុត ។

---

១– មហាវិភង្គ វេរញ្ជកណ្ឌ សៀវ. ១ ទំព័រ ១១ ។

ម្នាលព្រាហ្មណ៍ ! កាលបើពពួកសត្វ ដូចស៊ុតមាន់កើតហើយ មានអវិជ្ជាសេចក្ដីល្ងង់ ដូចជាសំបកស៊ុតកំពុងរួបរឹតក្នុងលោក មានតែតថាគតម្នាក់ឯង ដែលទំលាយសំបកស៊ុតគឺអវិជ្ជា ហើយត្រាស់ដឹងខ្លួនឯង ដោយប្រពៃនូវសម្មាសម្ពោធិញាណ ដែលមិនមានគុណជាតិឯទៀតប្រសើរជាងឡើយ ។ ម្នាលព្រាហ្មណ៍ ! តថាគតជាចម្បង ជាបុគ្គលប្រសើរបំផុតជាងសត្វលោក, ម្នាលព្រាហ្មណ៍ ! ព្យាយាមតថាគត បានតាំងផ្ដើមហើយ មិនបន្ធូរបន្ថយ ទាំងស្មារតីតថាគត ក៏ប្រុងមិនឲ្យភ្លាត់ កាយសោតក៏ស្ងប់រម្ងាប់ មិនក្រវល់ក្រវាយ ចិត្តក៏នឹងល្អ ជាចិត្តមានអារម្មណ៍តែមួយ ។

ម្នាលព្រាហ្មណ៍ ! តថាគតស្ងាត់ចាកកាមទាំងឡាយ ចាកកុសលទាំងឡាយ ចូលបឋមជ្ឈានប្រកបដោយវិតក្កៈវិចារៈ បីតិ សុខៈ ដែលកើតពីសេចក្ដីស្ងប់ស្ងាត់ជាអារម្មណ៍, ចូលដល់ទុតិយជ្ឈាន ជាទីផូរផង់ ញុំាងចិត្តជាសមាធិឲ្យកើតឡើងមានតែបីតិនឹងសុខៈ លះបង់បីតិះចេញហើយ ចូលដល់តតិយជ្ឈានជាបុគ្គលមានចិត្តព្រងើយ នៅជាសុខ, លះបង់សុខផង

លះបង់ទុក្ខផង រលត់នូវសោមនស្សនឹងទោមនស្សអំពីមុនផង តថាគតចូលដល់ចតុត្ថជ្ឈាន មិនមានទុក្ខ មិនមានសុខ មានតែសតិដ៏ស្អាតចំពោះត្រង់ឧបេក្ខា ។ កាលបើចិត្តបរិសុទ្ធផូរផង់ មិនមានកិលេស មិនសៅហ្មង ជាចិត្តទន់ សមគួរដល់កម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រយ៉ាងនេះហើយ តថាគត បានបង្អោនចិត្តចូលទៅក្នុងបុព្វេនិវាសានុស្សតិញ្ញាណ ។ តថាគតរលឹកជាតិជាអនេក រលឹកបាន ១ ជាតិ ២ ជាតិ ។ល។ ១ សែនជាតិ រលឹកច្រើនសំវដ្តកប្ប ច្រើនវិវដ្តកប្ប ច្រើនសំវដ្តវិវដ្តកប្ប ដូចនេះថា តថាគតកើតក្នុងភពឯណោះ ឈ្មោះយ៉ាងនេះ គោត្រ សម្បុរ អាហារ ទទួលសុខទុក្ខយ៉ាងនេះ កំណត់អាយុប៉ុណ្ណោះ ច្យុតចាកអត្តភាពនោះ បានទៅកើតក្នុងភពឯណោះ...តថាគត រលឹកតាមនូវជាតិ ដែលអាស្រ័យនៅពីមុនបានច្រើនជាតិ ព្រមទាំងអាការទាំងឧទ្ទេសយ៉ាងនេះ ។ ម្នាលព្រាហ្មណ៍! នេះជាបឋមវិជ្ជា ដែលតថាគតបានត្រាស់ដឹងក្នុងបឋមយាមនៃរាត្រី អវិជ្ជាបាត់ទៅ វិជ្ជាកើតឡើង ងងឹតបាត់ទៅ ពន្លឺកើតឡើង ដល់តថាគតដែលកំពុងអង្គុយប្រុង

ស្មារតី មិនប្រហែសធ្វេស ជុតបំផ្លាញកិលេស មានចិត្តមូល ស្លុង ដូចបណ្ឌិតទាំងឡាយដែលបានបឋមវិជ្ជាដូច្នោះដែរ ។ ម្នាលព្រាហ្មណ៍! នេះជាបឋមវិជ្ជា ដែលតថាគតបានត្រាស់ ដឹង ដូចជាកូនមាន់ប្បុងញាស់ចេញចាកសំបកស៊ុត ។

ម្នាលព្រាហ្មណ៍! កាលចិត្តបរិសុទ្ធផូរផង់ មិនមាន កិលេសប្រាសចាកសេចក្តីសៅហ្មង ជាចិត្តទន់ សមគួរដល់ កម្ម ជាចិត្តនឹងធឹងមិនញាប់ញ័រ យ៉ាងនេះហើយ តថាគត ទើបបង្អោនចិត្តចូលទៅក្នុងញាណ ដែលនាំឲ្យត្រាស់ដឹង នូវចុតិនឹងបដិសន្ធិនៃសត្វទាំងឡាយ ។ តថាគតពិចារណា មើលនូវសត្វទាំងឡាយ ដែលច្យុតនឹងចាប់បដិសន្ធិទាបថោក ឧត្តម ល្អ អាក្រក់ ទៅកាន់សុគតិ ទុគ្គតិ ដោយចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធក្រៃលែង ជាងចក្ខុរបស់មនុស្សសាមញ្ញ ឃើញច្បាស់ នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមយថាកម្មថា "អើហ្ន៎! សត្វទាំងនេះ ប្រព្រឹត្តអាក្រក់ ដោយកាយវាចាចិត្ត ជាមិច្ឆា- ទិដ្ឋិ ប្រកាន់នូវកម្មជាមិច្ឆាទិដ្ឋិ និយាយតិះដៀលអរិយបុគ្គល ទាំងឡាយ សត្វទាំងនោះ លុះរំលាងខន្ធទៅ បន្ទាប់ពី

មរណៈ ទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក ។ មួយសោត អើហ្នុ៎! សត្វទាំងនេះ ប្រព្រឹត្តល្អដោយកាយវាចាចិត្ត ជាសម្មាទិដ្ឋិ ប្រកាន់នូវកម្មជាសម្មាទិដ្ឋិ មិនតិះដៀលអរិយបុគ្គលទាំងឡាយ សត្វទាំងនោះ លុះរំលាងខន្ធទៅ បន្ទាប់ពីមរណៈទៅកើតឯសុគតិ ។ ម្នាលព្រាហ្មណ៍! នេះជាវិជ្ជាទី ២ ដែលតថាគតបានត្រាស់ដឹង ក្នុងមជ្ឈិមយាមនៃរាត្រី អវិជ្ជាបាត់ទៅ វិជ្ជាកើតឡើង ងងឹតបាត់ទៅ ពន្លឺកើតឡើង ដល់តថាគតដែលកំពុងប្រុងស្មារតី មិនប្រហែសធ្វេស ខំប្រឹងដុតបំផ្លាញកិលេស មានចិត្តមូលស្លុង ដូចបណ្ឌិតទាំងឡាយដែលបាននូវវិជ្ជាទី ២ ដូច្នោះដែរ ។ ម្នាលព្រាហ្មណ៍! នេះជាវិជ្ជាទី ២ ដែលតថាគត បានត្រាស់ដឹង ដូចជាកូនមាន់ដែលញាស់ចេញចាកសំបកស៊ុត ។

ម្នាលព្រាហ្មណ៍! កាលចិត្តបរិសុទ្ធផូរផង់ មិនមានកិលេសមិនមានសេចក្ដីសៅហ្មង ជាចិត្តទន់គួរដល់កម្ម ជាចិត្តនឹងធឹងមិនញាប់ញ័រយ៉ាងនេះហើយ តថាគត ទើបបង្អោនចិត្តបំពោះទៅក្នុងញាណ ជាហេតុនាំឲ្យអស់ទៅ នៃអាសវៈ

ទាំងឡាយ (អាសវក្ខយញ្ញាណ) តថាគតដឹងច្បាស់តាមពិតថា នេះទុក្ខ នេះជាហេតុនាំឲ្យកើតទុក្ខ នេះសេចក្ដីរលត់ទុក្ខ នេះឧបាយឲ្យបានដល់នូវសេចក្ដីរលត់ទុក្ខ ធម៌ប៉ុណ្ណេះជាអាសវៈ ធម៌នេះជាហេតុនាំឲ្យកើតអាសវៈ នេះសេចក្ដីរលត់នៃអាសវៈ នេះជាឧបាយឲ្យបានដល់នូវសេចក្ដីរលត់ទៅនៃអាសវៈ កាលតថាគតដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ចិត្តតថាគត ក៏ផុតចាកអាសវៈ គឺកាមផង ភពផង អវិជ្ជាផង លុះចិត្តតថាគតរួចផុតស្រឡះហើយ ប្រាជ្ញាកើតដល់តថាគតថា រួចផុតស្រឡះចាកអាសវធម៌ហើយ កំណើតអស់ហើយ ព្រហ្មចរិយធម៌បានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ចបានធ្វើស្រេចហើយ មិនមានកិច្ចដទៃក្រៅពីសោឡសកិច្ចទៀតឡើយ ។ ម្នាលព្រាហ្មណ៍! នេះជាវិជ្ជាទី ៣ ដែលតថាគតបានត្រាស់ដឹងក្នុងបច្ឆិមយាមនៃរាត្រី អវិជ្ជាបាត់ទៅ វិជ្ជាកើតឡើង ងងឹតបាត់ទៅពន្លឺកើតឡើង ដល់តថាគតដែលកំពុងប្រុងស្មារតី មិនប្រហែសធ្វេស ខំប្រឹងដុតបំផ្លាញកិលេស មានចិត្តមូលស្ងួនដូចបណ្ឌិតទាំងឡាយដែលបានវិជ្ជាទី ៣ ដូច្នោះដែរ ។ ម្នាលព្រាហ្មណ៍

ការត្រាស់ដឹងរបស់តថាគតគម្រប់ ៣ នេះ ដូចគ្នានឹងការញ្ញាស់របស់កូនមាន់ប្បងអំពីសំបកស៊ុត ។

### ៣– ទ្រង់ជាបុគ្គលខ្ពស់ផុត

*ព្រះតថាគតទ្រង់ហាំនពោលអំពីគុណធម៌របស់ព្រះអង្គ ដែលឥតមានបុគ្គលណាមួយស្មើបាន ដូចពុទ្ធភាសិតដែលត្រាស់ចំពោះអចេលកស្សប ថា(១) ។*

ម្នាលកស្សប ! សមណព្រាហ្មណ៍ពួកមួយ ជាសីលវាទ (ពោលអំពីសីលខ្លួន) សមណព្រាហ្មណ៍ទាំងនោះ តែងសរសើរគុណរបស់សីលដោយអនេកបរិយាយ ។ ម្នាលកស្សប ! បើទុកជាអរិយសីលដ៏ក្រៃលែងប៉ុណ្ណោះ តថាគតមិនឃើញបុគ្គលណាត្រឹមស្មើតថាគតក្នុងអរិយសីលនោះទេ, ក្រៃលែងជាងមកពីណាបាន ! តថាគតជាអ្នកក្រៃលែងក្នុងគុណគឺអធិសីលនោះដោយពិត ។

ម្នាលកស្សប ! សមណព្រាហ្មណ៍ពួកមួយ ជាតបោជិគុច្ឆវាទ (ពោលអំពីការខ្ពើមកិលេស ) សមណព្រាហ្មណ៍ទាំងនោះ

១– មហាសីហនាទសូត្រ សីលខន្ធវគ្គ សៀវ. ១៥ ទំព័រ ១១២ ។

តែងសរសើរគុណនៃការខ្ពើមកិលេសដោយតបៈ ជាអនេកបរិ-
យាយ ៗ ម្នាលកស្សប! បើទុកជាការខ្ពើមកិលេសដោយតបៈ
ដ៏ប្រសើរក្រៃលែងប៉ុន្មាន ក៏តថាគតមិនឃើញបុគ្គលណាត្រឹម
ស្មើនឹងការខ្ពើមកិលេសរបស់តថាគតក្នុងតបៈនោះទេ, ក្រៃលែង
ជាងមកពីណាបាន? តថាគតជាអ្នកក្រៃលែងក្នុងគុណគឺការ
ខ្ពើមកិលេសពិត, ៗ

ម្នាលកស្សប! សមណព្រាហ្មណ៍ពួកមួយ ជាវិមុត្តិវាទ
(ពោលអួតវិមុត្តិ) សមណព្រាហ្មណ៍ទាំងនោះ តែងសរសើរគុណ
របស់វិមុត្តិដោយអនេកបរិយាយៗម្នាលកស្សប!បើទុកជាវិមុត្តិដ៏
ប្រសើរក្រៃលែងប៉ុន្មាន ក៏តថាគតមិនឃើញមានបុគ្គលណាត្រឹម
ស្មើនឹងវិមុត្តិរបស់តថាគតក្នុងវិមុត្តិនោះទេ, ក្រៃលែងជាងមកពី
ណាបាន? តថាគតក្រៃលែងក្នុងគុណគឺអធិវិមុត្តិនោះដោយពិតៗ

## ៨- ទ្រង់ជាព្រះតថាគត

*ទ្រង់ព្រះនាមថា "តថាគត" ព្រោះព្រះអង្គបានត្រាស់ដឹង ហើយ ដូចព្រះតម្រាស់ដែលទ្រង់ត្រាស់បំពោះភិក្ខុទាំងឡាយថា*(១)

១- បឋមបណ្ណាសក ខុរវេលវគ្គ សៀ. ៤២ ទំព័រ ៥៣ ។

ម្នាលភិក្ខុទាំងឡាយ! លោកគឺទុក្ខសច្ច តថាគតត្រាស់ដឹងហើយ តថាគតផុតចាកលោកគឺទុក្ខសច្ចហើយ, លោកសមុទយៈ គឺទុក្ខសមុទ័យ តថាគតបានត្រាស់ដឹងហើយ លះបង់ហើយ, លោកនិរោធ គឺទុក្ខនិរោធ តថាគតត្រាស់ដឹងហើយ តថាគតបានធ្វើឲ្យជាក់ច្បាស់ហើយ, លោកនិរោធគាមិនីបដិបទា គឺទុក្ខនិរោធគាមិនីបដិបទា តថាគតបានត្រាស់ដឹងហើយ តថាគត បានចំរើនស្រេចហើយ ។

ម្នាលភិក្ខុទាំងឡាយ! អារម្មណ៍ណា ដែលលោកព្រមទាំងទេវលោក មារលោក ព្រហ្មលោកដែលពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាតិ ជាសម្មតិទេព និងមនុស្សដ៏សេសឃើញឮ ពាល់ត្រូវ ដឹងច្បាស់ បានដើរស្វែងរកត្រាប់រង្គាត់រក អារម្មណ៍នោះ តថាគតបានដឹងជាក់ស្ដែងដោយសារចិត្ត ព្រោះហេតុនោះ បានជាគេហៅថា "តថាគត",

ម្នាលភិក្ខុទាំងឡាយ! តថាគតបានត្រាស់ដឹងក្នុងរាត្រីណា បរិនិព្វានក្នុងរាត្រីណា តែងពោលបរិបា សំដែងបេញ

នូវភាវៈណា ក្នុងបន្ទោះនោះ កិច្ចមានការត្រាស់ដឹងជាដើមទាំងនោះ ដូច្នោះមែន មិនមែនជាមិនមែនទេ ព្រោះហេតុនោះបាន ជាគេហៅថា "តថាគត",

ម្នាលភិក្ខុទាំងឡាយ! តថាគត ថាយ៉ាងណា ធ្វើយ៉ាងនោះ ធ្វើយ៉ាងណា ថាយ៉ាងនោះ ថាយ៉ាងណា ធ្វើយ៉ាងនោះ ធ្វើយ៉ាងណា ថាយ៉ាងនោះ ហេតុនោះ ទើបបានជាគេហៅថា "តថាគត",

ម្នាលភិក្ខុទាំងឡាយ! តថាគត ជាអ្នកគ្របសង្កត់ អង់អាច ជាអ្នកឃើញពិត មានអំណាចគ្របសង្កត់លោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្ស ជាសម្មតិទេពនឹងមនុស្សដ៏សេសបាន ហេតុនោះទើបគេហៅថា "តថាគត" ។

( នៅមានត )

## ព្រះនិព្វាន ឬ និព្វាណ

# លោក កុម្មង់ដង់ រ៉ូបែរត៍ រៀបរៀង

ក្រមការ ដុំ-មៅ ប្រែជាភាសាខ្មែរ

(តមក)

គម្ពីរទីឃនិកាយសំដែងថា រូបអង្គតថាគតនៅប្រព្រឹត្តទៅជាធម្មតា ពិតមែនតែសេចក្តីប្រាថ្នាក្នុងភពថ្មីនោះបានកាច់បំបាក់ចោលស្រឡះ, រូបអង្គតថាគតនៅប្រព្រឹត្តទៅដរាបណា មនុស្សនឹងទេវតាទាំងឡាយក៏នៅឃើញតថាគតដរាបនោះ; វេលាណាតែរូបអង្គតថាគត ប្រែក្លាយទៅហើយ មនុស្សព្រមទាំងទេវតាក៏លែងបានឃើញសោះឡើយ ។

មុននឹងឲ្យយោបល់បញ្ចប់សេចក្តីនេះ យើងត្រូវត្រឡប់មកនិយាយអំពីនិព្វាន ដែលបានសម្រេចតាំងពីកាលរូបរស់នៅជាមុននិព្វាននោះវិញ គឺថាក្នុងនិព្វានដែលសល់នៅខន្ធនេះ ព្រះអរហន្តលោកសោយសុខ ក្នុងព្រះនិព្វានដែលលោកបានដល់នោះ ប៉ុន្តែសោយតែក្នុងពេលដែលលោកកំពុងធ្វើឈានប៉ុណ្ណោះទេ វេលាដែលលោកចេញពីឈានសមាបត្តិមកវិញ លោកនៅចាំទាំងអស់ ប៉ុន្តែសេចក្តីដែលលោកបានប្រទះឃើញ ឬដែលបានប៉ះពាល់ទាំងប៉ុន្មាននោះ នឹងយកមកប្រែស្រាយជាភាសាសម្រាប់មនុស្សថាដូច្នេះដូច្នោះមិនកើត ព្រោះគ្មានពាក្យសម្រាប់មនុស្សលោកនឹងនិយាយឲ្យចំ ។

មានពាក្យបុច្ឆាក្នុងគម្ពីរទិដ្ឋធម្មនិព្វានថា ដើម្បីនឹងឲ្យបានដល់នូវព្រះនិព្វាននោះត្រូវធ្វើដូចម្ដេច? វិសជ្ជនាថា: ដើម្បីឲ្យបាននូវព្រះនិព្វាននោះត្រូវចំរើននូវរូបជ្ឈាន ៤ អរូបជ្ឈាន ៤ ដែលហៅថា សមាបត្តិទាំង ៨ ប្រការនឹងឈានថ្នាក់បំផុត ១ ទៀតដែលហៅថា សញ្ញាវេទយិតនិរោធ ហើយដែលជាឈានផ្ទាល់នឹងគួព្រះនិព្វាន កាលណាតែបានធ្វើឈានទាំងប៉ុន្មាននេះហើយ អ្នកដែលធ្វើឈានក៏បានដល់នូវព្រះអរហត្ត ហើយបានទីជាព្រះអរហន្តក្នុងវេលានោះ ។

ឯឈានទាំងប៉ុន្មាននេះ បែបដូចជាសេចក្ដីហាត់តម្រង់នៅសន្ទុះឬកំឡាំងចិត្តរបស់មនុស្ស, ឯកំឡាំងសន្ទុះរបស់ចិត្តនោះ អាចនឹងក្លាឡើងបាន ឬថយទៅវិញនោះ មកតែពីការព្យាយាមហាត់ ឬដោយធ្វេសប្រហែសបោះបង់ចោលប៉ុណ្ណោះ; មានគួរនាដូចជាគេហាត់កីឡាយកកំឡាំងពលំដោយក្បួនខាគដូចោះដៃ; គឺថាបើព្យាយាមហាត់កល ១ ថ្ងៃទៅ នឹងមានកំឡាំងពលំច្រើនឡើង ហើយបើធ្វេសបោះបង់ចោលទៅវិញនោះ កំឡាំងក៏ដុនថយទៅវិញ ។

ក្នុងមហាទស្សនសុត្ត មានសំដែងអំពីឈានទាំង ៤ ថ្នាក់ខាងដើមគឺព្រះសម្មាសម្ពុទ្ធ ទ្រង់សំដែងប្រាប់ពនឹងព្រះមហាអានន្ទថា ដើម្បីនឹងឲ្យបានដល់បឋមជ្ឈានឬឈានថ្នាក់ទី ១ នោះ ត្រូវតាំងសមាធិលះបង់នូវចិត្តអាក្រក់ គឺនីវរណទាំង ៥ ចោលទាំងអស់ ហើយចំរើននូវសមាសតិ

គឺសេចក្ដីរឭកត្រូវឬគំនិតត្រង់ ដូចមានសំដែងក្នុងអដ្ឋង្គិកមគ្គ គឺផ្លូវប្រកបដោយអង្គ ៨ នោះឯង; ធ្វើដូច្នេះនឹងបានដល់នូវបឋមជ្ឈាន គឺសុខ: សេចក្ដីស្រួលកាយស្រួលចិត្ត; បីតិ សេចក្ដីឆ្អែតកាយឆ្អែតចិត្ត; ឯកគ្គតា ការបានតាំងចិត្តនឹងនៅក្នុងអារម្មណ៍តែ ១; វិតក្ក: សេចក្ដីរំពឹងគិតពិចារណា; វិចារ: ការញុំាងចិត្តឲ្យជាប់នៅក្នុងអារម្មណ៍ ។

ចំរើនតពីនេះទៅទៀត ត្រូវលះបង់សេចក្ដីរំពឹង (វិតក្ក:) ការញុំាងចិត្តឲ្យនៅក្នុងអារម្មណ៍ (វិចារ:) ចេញ; នឹងបានដល់នូវទុតិយជ្ឈាន គឺសុខ: សេចក្ដីស្រួលកាយស្រួលចិត្ត; បីតិ សេចក្ដីឆ្អែតកាយឆ្អែតចិត្ត ដែលកើតឡើងដោយសេចក្ដីក្ដីច្បាស់ គឺសេចក្ដីមូលអារម្មណ៍ នឹងសេចក្ដីដែលមានចិត្តស្ទុះខ្ពស់ឡើង ។

លុះលះបង់នូវសេចក្ដីត្រេកក្នុងបីតិ គឺសេចក្ដីឆ្អែតកាយឆ្អែតចិត្តនេះចេញហើយ ព្រះយោគាវចរតាំងនៅក្នុងសេចក្ដីព្រងើយកន្តើយ សោយអារម្មណ៍ជាសុខធ្វើជាម្ចាស់ចិត្តបាន ហើយក៏ដល់ទៅថ្នាក់ឈានទី ៣ ឬតតិយជ្ឈាន គឺសេចក្ដីដែលពេញចិត្តរីកពាយឥតវង្វៀស ។

លុះវៀរចាកនូវសេចក្ដីស្រួលចិត្តគឺសុខចេញ ហើយលះបង់នូវសេចក្ដីឈឺចាប់គឺទុក្ខចោល មិនត្រេកអរនឹងសុខ មិនទោមនស្សនឹងទុក្ខ, ព្រះយោគាវចរក៏បានដល់ទៅឈានថ្នាក់ទី ៤ ឬចតុត្ថជ្ឈាន គឺសេចក្ដី

ដែលឈ្មោះចិត្តឬជាម្ចាស់ចិត្តរបស់ខ្លួនដោយពិតប្រាកដ នឹងជាសេចក្តីដែលក្លៀវក្លាពិតប្រាកដ ។

អារម្មណ៍ទាំងប៉ុន្មាន ដែលជាប់ជូនទៅជាមួយនឹងឈានទាំង ៤ ថ្នាក់ខាងដើម ដែលព្រះយោគាវចរបានចំរើននោះ បានឈ្មោះហៅថាអារម្មណ៍ ៤ គ្មានទីបំផុត ឬអប្បមាណារម្មណ៍ ។ អារម្មណ៍ទាំងនេះជាឥស្សរភាព គន្លងកិរិយាប្រព្រឹត្តទៅជាប្រក្រតី របស់ព្រះយោគាវចរដែលទៅកាន់ព្រះនិព្វាន ។

ឯសម្មាសមាធិ គឺការនាដ៏ប្រពៃនោះ ជាមែកទី ៨ នៃអដ្ឋង្គិកមគ្គនោះឯង ។

ឯថ្នាក់ឈានតពីនេះទៅទៀតនោះ នាំព្រះយោគាវចរដែលធ្វើឈានឲ្យបានដល់ទៅអរូបគត ។ ឈាននោះត្រូវចំរើននូវអាកាសទទេមិនចេះផុត គឺអាកាសានញ្ចាយតនៈ; ចិត្តមិនចេះផុតគឺវិញ្ញាណញ្ចាយតនៈ; សេចក្តីដែលមិនមាននៅសល់អ្វីទាំងអស់ គឺអកិញ្ចញ្ញាយតនៈ, សភាពដែលមានវិញ្ញាណជាកណ្តាលនៃសេចក្តីកត់សំគាល់ គឺនេវសញ្ញានាសញ្ញាយតនៈ, ឯថ្នាក់ចុងបំផុតនោះ គឺសមាធិបំបាត់នូវសញ្ញានឹងវេទនា គឺជាវិលត់នូវសេចក្តីដែលដឹង គន្លងវេលានោះហើយ ដែលព្រះយោគាវចរបានដល់នូវព្រះអរហត្ត គឺបានសម្រេចនូវព្រះនិព្វាន ។

ត្រូវសំគាល់ថា កិរិយាដែលហាត់ធ្វើឈានថ្នាក់ដំបូងនោះ មិនមែន

BIBLIOTHEQUE P.P. D'EXTREME ORIENT

ហាត់បានហើយ នាំឲ្យបានឈានថ្នាក់បំផុតតាំងប៉ុន្មាននោះទៀតឡើយ ។ គម្ពីរព្រះអភិធម្មមានសំដែងដោយជាក់ច្បាស់ណាស់ អំពីរឿងនេះ គឺថាការដែលនឹងធ្វើឈានតាំងប៉ុន្មានខាងក្រោយនោះបាន មានតែអ្នកបួសប៉ុណ្ណោះទេ ទើបអាចនឹងធ្វើបាន, ឯឃរាវាសទោះបីបានហាត់ធ្វើឈានថ្នាក់ខាងដើមតាំងប៉ុន្មានឲ្យស្ទាត់ដូចម្ដេចក៏ដោយ គង់មិនអាចនឹងចំរើននូវអាកាសានញ្ចាយតនៈ ឬវិញ្ញាណញ្ចាយតនៈ ។ល។ បានដែរ ។

គួរយើងចាំទុកថា ព្រះអរហន្តដែលចូលឈាននោះ មិនមែនជាការដែលខ្លួននៅនឹងស្លុកឥតវិញ្ញាណឥតស្មារតី ដូចជាអ្នកតែងសៀវភៅពុទ្ធសាសនាជាតិអឺរ៉ុប គេធ្លាប់ជឿមកនោះឡើយ, ព្រោះគម្ពីរព្រះអភិធម្មមានសំដែងថា ព្រះអរហន្តមានញាណយ៉ាងខ្ពស់មួយ ដោយអំណាចកិរិយាដែលបានឃើញច្បាស់ឥតទើសទាល់ ដែលហៅថាវិបស្សនាញាណនោះឯង ។

គម្ពីរឡាតិលោកមានសំដែងថា អ្នកឯណាដែលបានលះបង់នូវនីវរណធម៌ចោល បានឈ្មោះថាជាអ្នកត្រិះរិះដ៏ប្រពៃ ។

សេចក្ដីដែលឈ្នះនូវចិត្តដោយដាច់ខាត សេចក្ដីដែលបានសម្រេចព្រះអរហត្តនោះហើយ ជាគោលបំផុតរបស់ឈាន ។

សេចក្ដីត្រង់នេះមានពាក្យចោទ ១ ដែលត្រូវចោទសួរ ហើយពាក្យចោទនេះបើទោះបីមិនមែនរកមិនឃើញ ក៏លំបាកនឹងឆ្លើយឲ្យចំ ដូចជា

ពាក្យដែលថានិព្វាននោះដែរ ប៉ុន្តែសេចក្តីវិសជ្ជនាក្នុងកន្លែងនេះ នាំឲ្យឃើញផ្ទុយជាក់ច្បាស់ទៅក្នុងនិព្វាន ឯពាក្យចោទនោះថា " អ្វីដែលចូលនិព្វានទៅវេលាក្រោយទំលាយខន្ធទៅ? " ។

សេចក្តីត្រង់នេះយើងមិនអាចនឹងហ៊ានថា: យើងឆ្លើយត្រូវឡើយ, ដោយហេតុសេចក្តីនេះ មានពាក្យដដែកមិនដាច់ស្រេចតាំងអំពីកើតព្រះពុទ្ធសាសនាម៉្លេះ; មានសេចក្តីជឿងល់នោះក៏ច្រើន ហើយមានសេចក្តីដែលគេបានវិនិច្ឆ័យក៏ច្រើន ។ ចំណែកយើងៗគ្រាន់តែយកសេចក្តីវិនិច្ឆ័យទាំងនោះខ្លះ ហើយស្រង់យកសេចក្តីផ្សេងៗ ដោយអាងដល់គម្ពីរខ្លះដែលត្រឹមត្រូវនោះ មកធៀបគ្នា ។ ចំណែកអ្នកទាំងឡាយកាលគ្នាមានឯកចិត្តរៀងខ្លួននឹងជឿថាដូចម្តេច ១ ហើយនឹងបង្កើតគំនិតថ្មី ១ បាន តាមដែលខ្លួនយល់ឃើញថាគួរ ។

ធាតុទាំងឡាយផ្សេង ១ ជានាមធម៌ ដែលគេបានជឿមកថា មានដោយពិត នឹងសេចក្តីដែលផ្លាស់ប្តូរជាតិ ពីជាតិមួយទៅជាតិមួយ ព្រមទាំងផ្លូវដែលចូលទៅនិព្វាន គឺធាតុដែលសល់នៅជាខាងក្រោយពេលដែលស្លាប់នោះ ជាធាតុដែលមានតាំងអំពីដើមរៀងមក មានឈ្មោះដូចមានខាងក្រោមនេះ៖

ពាក្យថា អាត្មង ខ្មែរធ្លាប់ហៅថាអាត្មា ជួនកាលគេប្រែថា

ព្រលឹង ប៉ុន្តែក្នុងវេលានេះយើងយកសព្ទដែលសម្រាប់ប្រើក្នុងសាសនាដែលគេធ្លាប់ប្រើក្នុងប្រទេសអឺរ៉ុបនោះមកនិយាយដូចតទៅនេះ៖

គម្ពីរក្នុងពុទ្ធសាសនាមិនទទួលស្គាល់ មិនជឿថាមានអត្តាទេឡើយ; ត្រង់នេះមានបុច្ឆាថា ចុះហេតុអ្វីបានជាព្រះសព្វញ្ញុពុទ្ធមិនព្រមទទួលឆ្លើយអំពីការដែលលោកថាទៀងឬមិនទៀង ឬមួយក៏គេសំគាល់ថាលោកនោះហើយជាអត្តា? ឬជាខ្លួនប្រាណ? ។ ដូច្នេះ បើជាគ្មានអត្តា យើងមិនបាច់និយាយអំពីលោកនោះដែរ គឺថាលោកនោះក៏គ្មានដូចគ្នា ។

ពាក្យថាវិញ្ញាណដែលគេតែងប្រែថាសេចក្ដីដឹង ឬប្រាជ្ញានោះ តាមដោយគម្ពីរផ្សេង ៗ ក្នុងពុទ្ធសាសនាថាវិញ្ញាណនេះហើយ ជាមគ្គនាយកនៃកិរិយាផ្លាស់ជាតិមួយទៅជាតិមួយ (សំយុត្តនិកាយ) ក្នុងមួយជាតិ ៗ របស់មនុស្សនោះ វិញ្ញាណនេះឯងជាខន្ធមួយ ដោយធាតុឯទៀតផ្សេង ៗ ចូលផង គឺរូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ ដែលធ្វើឲ្យយើងកាន់ប្រទៀថាមានខ្លួនប្រាណ ដែលវិញ្ញាណនេះបណ្ដាលមកពីសញ្ញាខន្ធ វេទនាខន្ធ នឹងសង្ខារក្ខន្ធ វិញ្ញាណឯងបានត្រួតបញ្ឈាក់ម្ដងទៀត ។ ដូច្នេះឃើញថាហាក់ដូចជាវិញ្ញាណនេះជាឥស្សរភាព ក្នុងប្រជុំធាតុទាំងឡាយរបស់មនុស្ស ។ រឿងយោធិកកិត្តិដែលមានសំដែងក្នុងគម្ពីរទីឃនិកាយមានសេចក្ដីថា ខ្លួនខ្ញុំជារូបដែលអាស្រ័យដោយប្រជុំនៃធាតុ ៤, កើតឡើងដោយមាតានឹងបិតា, រស់នៅដោយអាហារ ហើយមានធម្មតាឬមានជាតិ

—

ត្រូវតែរលាយទៅវិញ; ឯវិញ្ញាណរបស់ខ្ញុំ ដែលមកជាប់នៅជាមួយនោះ នៅជាប់នឹងខ្លួនទាំងនោះ ។

មានសេចក្ដីមួយដែលព្រះសម្មាសម្ពុទ្ធ សំដែងប្រាប់ទៅនឹងមហាអានន្ទ ក្នុងគម្ពីរទីឃនិកាយច្បាស់លាស់ណាស់, គឺព្រះអង្គទ្រង់សួរមហាអានន្ទថា "ម្នាលអានន្ទ! ប្រសិនបើវិញ្ញាណ មិនបានចូលទៅក្នុងគភ៌នៃមាតា តើនាមនឹងរូបអាចតាក់តែងនៅក្នុងគភ៌នៃមាតាដែរឬអ្វី ?" ព្រះមហាអានន្ទ ឆ្លើយថា "នាមនឹងរូប មិនអាចតាក់តែងនៅក្នុងគភ៌បានឡើយ" ។ ព្រះសព្វញ្ញូទ្រង់សួរទៀតថា "ប្រសិនបើវិញ្ញាណនោះចូលទៅក្នុងផ្ទៃនៃមាតាហើយ លុះក្រោយមកក៏ចេញចាកបោះបង់ចោលខ្លួននោះវិញ បើដូច្នេះ តើនាមនឹងរូបអាចកើតឡើងបានឬមិនបាន ?" ព្រះមហាអានន្ទឆ្លើយទូលតបវិញថា "កើតមិនបានទេ" ។ វេលានោះព្រះបរមគ្រូទ្រង់សួរតទៅទៀតថា "ចុះប្រសិនបើវិញ្ញាណដែលមានក្នុងកុមារកុមារីនោះ បោះបង់ចោលខ្លួនចោលចេញ តើនាមរូបនោះប្រព្រឹត្តទៅបានឬទេ ?" មហាអានន្ទឆ្លើយតបទៀតថា "ប្រព្រឹត្តទៅមិនបានទេព្រះអង្គ" ។

គម្ពីរដែលនេះសំដែងថា វិញ្ញាណនោះគឺធម្មជាតិដែលគ្មានចំនួន គ្មានទីបំផុត ដែលជាពន្លឺទូទៅ គឺធម្មជាតិដែលមិនមែនទឹក មិនមែនដី មិនមែនភ្លើង មិនមែនខ្យល់ នឹងថាជាធំក៏មិនបាន តូចក៏មិនបាន

ខ្សោយក៏មិនបាន ខ្លាំងក៏មិនបាន ល្អក៏មិនបាន អាក្រក់ក៏មិនបាន គឺថាជាធម្មជាតិដែលកើតលេចជាមួយគ្នានឹងនាមរូប ។ ប៉ុន្តែបើនាមនឹងរូបប្រាស្រ័យនឹងវិញ្ញាណ វិញ្ញាណក៏ប្រាស្រ័យនឹងនាមរូបដែរ ។

ព្រះបរមសាស្តាឲ្យទ្រង់សួរមហាអានន្ទថា "ម្នាលអានន្ទ ! ប្រសិនបើវិញ្ញាណលែងពឹងពាក់អាស្រ័យនឹងនាមរូប តើជាតិ ជរា ព្យាធិ មរណៈ ដែលជាហេតុដើមរបស់ទុក្ខ នឹងនៅមានតទៅទៀតដែរឬអ្វី ? ។

មហាអានន្ទឆ្លើយតបវិញថា "ជាតិ, ជរា, ព្យាធិ, នឹងមរណៈ មិនមានទៀតឡើយ ។ ព្រះបរមសាស្តាទ្រង់បញ្ជាក់ថា: បើដូច្នេះ ម្នាលអានន្ទ នេះហើយជាហេតុ នេះហើយជាគូ នេះហើយជាដើមចម នេះហើយជាគោលរបស់វិញ្ញាណ គឺនាមនឹងរូបនេះឯង ។

មានពុទ្ធបរិស័ទ ១ អង្គឈ្មោះ សាតិ ជឿថាវិញ្ញាណរបស់មនុស្សសព្វថ្ងៃនេះ ជាវិញ្ញាណដែលជាប់តគ្នាមកពីវិញ្ញាណកាលពីជាតិមុន ៗ ។ គម្ពីរមជ្ឈិមនិកាយសំដែងថា សេចក្តីជឿនេះជាសេចក្តីជឿខុសស្រឡះ ។

មានគម្ពីរខ្លះក្នុងពុទ្ធសាសនា ដូចយ៉ាងគម្ពីរមជ្ឈិមនិកាយនឹងអភិធម្មកោស សំដែងថាវិញ្ញាណនោះបណ្តាលមកអំពីគន្ធរូប ដែលជាធម្មជាតិល្អិតក្រៃលែង ចេញមកពីខ្លួនមនុស្សម្នាក់ ដែលទៅបដិសន្ធិក្នុងគភ៌ថ្មី ប៉ុន្តែគន្ថែងត្រង់នេះមិនបានសំដែងឲ្យច្បាស់ឡើយ ។

មានធាតុម្យ៉ាងទៀតដែលហៅថាសត្ត; ជួនកាលគេហៅថា ជាធម្មជាតិដែលទៀងជានិច្ចរបស់អត្តភាព, ប៉ុន្តែឯសត្តនេះក៏មិនប្លែកពីអាត្មន មិនប្លែកពីជីវៈ មិនប្លែកពីបុគ្គលឡើយ គឺថាឈ្មោះទាំងប៉ុន្មាននេះ សំដៅទៅលើអត្តភាពតែ ១ ប៉ុណ្ណោះ ប៉ុន្តែគម្ពីរទាំងអស់មិនបានសំដែងឲ្យជាការដាច់ស្រេចសោះ ។

ក្នុងគម្ពីរអភិធម្មកោសសំដែងថា ព្រះនាគសេនត្ថេរលោកពោលថា ធម្មជាតិដែលរស់នៅក្នុងជីវៈនោះគ្មានទេ ហើយបើគ្មានដូច្នេះ ឲ្យថាជីវៈនោះមានសណ្ឋានដូចជារូប ឬប្លែកគ្នាពីរូបដូចម្ដេចបាន? ។

ដូច្នេះឃើញថា បើជាជាតិកំណើតរបស់មនុស្សនិមួយ ៗ អាស្រ័យដោយអំពើ ឬកម្មរបស់ខ្លួនតាំងពីជាតិមុន ៗ មកនោះ ក៏គ្មានធម្មជាតិណាមួយដែលចេញផ្លាស់ពីជាតិមុន ៗ នោះឡើយ គឺថាបុគ្គលដែលបានសោយនូវផលកម្មក្នុងមួយជាតិ ៗ នោះ មិនមែនជាតួបុគ្គលដែលបានធ្វើកម្មនោះឡើយ ប៉ុន្តែបុគ្គលនោះមិនមែនជាបុគ្គលដទៃទេ គឺជាធម្មជាតិដែលទាក់ទងត ៗ គ្នា ។

ឯវិញ្ញាណធាតុឯទៀតនោះ សុទ្ធតែជារបស់បណ្ដោះអាសន្នទាំងអស់ ប៉ុន្តែធាតុទាំងប៉ុន្មាននេះហើយដែលប្រាស្រ័យគ្នានឹងធាតុផ្សេងៗអំពីជាតិមុន ៗ រលកនៅក្នុងសមុទ្រនោះមិនមែនកើតដោយទឹកដែលផ្លាស់កន្លែងឡើយ គឺកើតអំពីអាការដែលទឹកកម្រើកជូនតគ្នាទៅ ឯទឹកនោះ

ឥតមានផ្លាស់កន្លែងឡើយ នៅតែកន្លែងដដែលដូចពីដើម ។ ជាតិរបស់មនុស្សវិញក៏មានសណ្ឋានដូចគ្នាដែរ គឺជាអាការដែលកម្រើកជួនគាំ ៗ គ្នានោះឯង ឥតមានអ្វីជិតជាប់ទៅជាមួយអាការនោះឡើយ សេចក្ដីនេះឃើញថាជាការលំបាកនឹងនិយាយឲ្យស្រឡះ អំពីសេចក្ដីទាក់ទងនៃភពពីមួយទៅមួយ លំបាកនឹងគិតអំពីបំណោទខាងក្រោយនេះណាស់ គឺបំណោទដែលចោទថា តើធាតុអ្វីដែលចូលទៅក្នុងនិព្វាននោះ ត្រង់នេះយើងមានសេចក្ដីដែលយើងមិនស្គាល់ ២ យ៉ាង នៅចំពោះមុខយើង គឺធាតុដែលចូលទៅកាន់និព្វាននោះ ១ គួព្រះនិព្វាន ១ សេចក្ដីទាំង ២ នេះយើងមិនបានស្គាល់ទាំងអស់ ។

អំពីនិព្វានរបស់ព្រះអរហន្ត ដែលហៅថា សឧបាទិសេសនិព្វាន ឬនិព្វាននៅឧបាទិនោះ យើងបានដឹងថាព្រះអរហន្តលោកនៅមានអាយតនៈទាំងអស់ នៅមានប្រាជ្ញាមានវិញ្ញាណដែលសំអិតសំអាងដោយផ្ចិតផ្ចង់ហើយម្យ៉ាងទៀតព្រះអរហន្ត លោកមានទាំងអានុភាពយ៉ាងខ្ពង់ខ្ពស់ផងប៉ុន្តែលុះព្រះអរហន្តលោកចូលទៅកាន់ព្រះនិព្វានដែលគ្មានឧបាទិ ឬអនុបាទិសេសនិព្វាននោះ តើដូចម្ដេចទៅវិញ ត្រង់នេះគម្ពីរសំយុត្តនិកាយមានសំដែងសេចក្ដី ២ បទដូចមានខាងក្រោយ ។

(នៅមានត)

# ព្រះអភិធម្មបិដក

# គម្ពីរព្រះកថាវត្ថុ

លោកប៊ូ-ប៉ូ ប្រែរៀបរៀង

## អឈេញ្ញកថា

(តមក)

ឯការប្រាប់, ពន្យល់, បង្រៀន, សំដែងនូវព្រះពុទ្ធវចនៈឲ្យអ្នកដទៃបានយល់, បានចេះដឹងនោះ ចាត់ជាធម្មទានគឺការឲ្យធម៌ជាទាន ។

ធម្មទាននេះ មានផលានិសង្ស៍វិសេសវិសាលណាស់ ដូចព្រះពុទ្ធភាសិតថា សព្វទានំ ធម្មទានំ ជិនាតិ ឲ្យទានធម៌ (មានផល) ឈ្នះទានទាំងអស់ ។ បើបុគ្គលណាមានទ្រព្យសម្បត្តិច្រើន ហើយជាអ្នកមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា បានបរិច្ចាគចីវរ, បិណ្ឌបាត, សេនាសនៈ និងគិលានភេសជ្ជៈ គ្រប់បច្ច័យទាំងបួន ដ៏ច្រើនក្រៃលែង ហើយសុទ្ធតែថ្លៃថ្លាបំផុត ប្រគេនព្រះអរិយសង្ឃ មានព្រះពុទ្ធអង្គជាប្រធាន ដែលគង់ពេញផ្ទៃចក្រវាឡទាំងអស់ អ្នកនោះបានទទួលផលានិសង្ស៍ នៃបច្ច័យទាននេះជាច្រើនអនេកអនន្ត ។ ប៉ុន្តែ បើយកផលនៃអាមិសទាននេះមកប្រៀបផ្ទឹម ចំនឹងផលនៃធម្មទានតែមួយគាថាវិញ ឃើញថាផលអាមិសទានទាំងដើមនោះ មិនស្មើនឹងផលនៃធម្មទានតែមួយចម្រៀកគំរប់ ១៦ ចុងបំផុត ដែលយកមួយចម្រៀកមកចែកជា ១៦

បម្រៀកទៀត ព្រោះធម្មទានជាបច្ច័យឲ្យកើតបញ្ញាល្អប្រពៃ អាចចេះដឹងក្នុងផ្លូវនៃព្រះត្រៃបិដករហូតដល់បានសម្រេចព្រះអរហត្ត បែកធ្លាយក្នុងបដិសម្ភិទាទាំងបួនទៀតផង ។

ប្រការមួយទៀត អ្នកចារឬសរសេរគត់ត្រាព្រះពុទ្ធវចនៈ ដោយលាយល័ក្ខណ៍អក្សរ ក៏រាប់ចូលក្នុងធម្មទាន ព្រោះការគត់ត្រាព្រះពុទ្ធវចនៈនោះ ទុកជាគម្ពីរក្បួនច្បាប់សម្រាប់ឲ្យមនុស្សទាំងពួង អ្នកចង់ចេះដឹងបានអាន, បានឃើញ នៅស្ថិតស្ថេរជាអង្វែងតទៅមុខ ។ ទោះអ្នកសំដែង, បង្រៀន, ចារ, សរសេរព្រះពុទ្ធវចនៈដោយខ្លួនឯងក្ដី ពឹងឬជួលអ្នកផងឲ្យសំដែង, ឲ្យបង្រៀន, ឲ្យចារសរសេរព្រះពុទ្ធវចនៈក្ដី ក៏លោករាប់ជាធម្មទានមានផលដូចគ្នា ។

សកវាទី ចុះពួកមនុស្សបុថុជ្ជនស្ថិតនៅក្នុងអនេញ្ជធម៌ គឺមិនញាប់ញ័រដោយតណ្ហាមានៈទិដ្ឋិខ្លះដែរឬទេ ?

បរវាទី— ពួកមនុស្សបុថុជ្ជនមិនស្ថិតនៅក្នុងអនេញ្ជធម៌ទេ ព្រោះមានចិត្តញាប់ញ័រដោយ តណ្ហា មានៈ ទិដ្ឋិ ជាប្រាកដ ។ តណ្ហា, មានៈ នឹង ទិដ្ឋិ ទាំង ៣ នេះហៅថា ឥញ្ជិតធម៌ ប្រែថាធម៌ធ្វើចិត្តឲ្យញាប់ញ័រ ។ ចិត្តរបស់បុថុជ្ជនមានតណ្ហា, មានៈនឹងទិដ្ឋិ ពេញបរិបូណ៌ ។ ប៉ុន្តែ បើបុថុជ្ជនណាៗស្វាហាប់សង្កត់សង្កិនលះបង់តណ្ហាមានះ ឬទិដ្ឋិចេញពីសន្តាន

បុថុជ្ជននោះក៏អាចសង្កត់សង្កិនលះបង់បានមួយក្អែក, មួយពេល, មួយខណៈប៉ុណ្ណោះ លះមិនដាច់ជ្រះស្រឡះទេ នៅមានតណ្ហា មានះ ទិដ្ឋិដដែល, ប៉ុន្តែ នឹងរលោះថយតិចខ្លះ ដោយអំណាចកម្លាំងខំព្យាយាមសង្កត់សង្កិន លះកាត់ជាញឹកញាប់ ៗ បុថុជ្ជនដែលព្យាយាមសង្កត់សង្កិនតណ្ហា មានះ ឬទិដ្ឋិ បានឃាត់ពីសន្តានមួយខណៈ ៗ នោះ មានឈ្មោះមួយជាន់ទៀតថាជាកល្យាណបុថុជ្ជន គឺបុថុជ្ជនល្អ ឬគួររាប់រកបាន, ហៅម្យ៉ាងទៀតថា សាធុជនក៏បាន, ថាសប្បុរសក៏បាន ៗ កល្យាណបុថុជ្ជននេះហើយ ដែលតទៅមុខនឹងក្លាយខ្លួនទៅជាអរិយជន ៗ សូម្បីបាននាមថាជាកល្យាណបុថុជ្ជនដូច្នេះហើយ ក៏នៅតែលោកមិនរាប់ថាជាអ្នកស្ថិតនៅក្នុងអនេញ្ជធម៌ដែរ ព្រោះមិនបានលះបង់តណ្ហា មានះ ទិដ្ឋិឲ្យដាច់ជ្រះស្រឡះពីសន្តាន គ្រាន់តែសង្កត់សង្កិនបានមួយខណៈ ៗ ប៉ុណ្ណោះ ដូចជាគេយកដុំថ្មសង្កត់ស្មៅ ៗ

សកកទី- ចុះតណ្ហា, មានះ នឹងទិដ្ឋិទាំង ៣ នេះ តើឲ្យទោសយ៉ាងណា បានជាលោកខ្លាចខ្លាំងម្ល៉េះ អ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជាដើម តែងទូន្មានឲ្យបុថុជ្ជនខំព្យាយាមលះបង់ចេញ ?

បរក់ទី- តណ្ហាសេចក្តីប្រាថ្នាបង់បាន ៗ បើបុគ្គលណាបណ្តោយឲ្យចិត្តចង់បានកាន់តែច្រើន កាន់តែធំឡើង ៗ មិនអត់សង្កត់ មិនទប់ទល់

មិនបន្ថយឲ្យស្រាកស្រាន្តខ្លះទេ បុគ្គលនោះឈ្មោះថា ជាអ្នកមានតណ្ហា ច្រើន ៗ អ្នកមានតណ្ហាច្រើនហួសប្រមាណ តែងបានទទួលទុក្ខទោស សោក-ភ័យ សេចក្តីវិនាសជាច្រើនប្រការ ដូចមានព្រះពុទ្ធភាសិតថា: តណ្ហាយ ជាយតេ សោកោ ជាដើម សេចក្តីសោកកើតមក អំពីតណ្ហា សេចក្តីទុក្ខភ័យកើតមកអំពីតណ្ហា បើបុគ្គលណាអស់តណ្ហា ហើយ បុគ្គលនោះលែងមានសោក លែងមានទុក្ខភ័យទៀតឡើយ ៗ អ្នកមានតណ្ហាច្រើនលើសលុបនោះ មិនមែនត្រឹមតែធ្វើខ្លួនឲ្យវិនាសដល់ទៅក្ស័យជីវិតប៉ុណ្ណោះទេ សូម្បីតែនៅរស់ ក៏នាំឲ្យបែកបាក់ព្រាត់ប្រាស ពីញាតិសន្តានពីមិត្រសំឡាញ់ដែរ ដោយហោចទៅគ្រាន់តែចិត្តអៀនខ្មាស ក៏គ្មានផង ព្រោះគិតតែចង់បានខាំងពេក ទាល់តែភ្លេចខ្មាសគេអស់រលីង ដូចម្នានអតីតនិទានក្នុងព្រះសូត្រសំដែងឲ្យឃើញជាគំរូថា ៖

អតីតេ កាលេ ក្នុងកាលកន្លងទៅហើយ ព្រះពុទ្ធជាម្ចាស់ នៃយើងកាលសោយព្រះជាតិជាពោធិសត្វនៅឡើយ បានកើតក្នុងត្រកូល ព្រះមហាក្សត្រ ៗ លុះចំណេរក្រោយមក ព្រះវររាជបិតាទ្រង់ទីវង្គតទៅ ព្រះរាជកុមារជាព្រះជេដ្ឋាប្រគល់រាជសម្បត្តិ ឲ្យព្រះបរមពោធិសត្វជាព្រះ កនិដ្ឋាគ្រប់គ្រង ហើយចេញពីព្រះនគរទៅគង់នៅបច្ចន្តគ្រាមចុងស្រុក មួយ ប៉ុន្តែក្នុងអាណាខេត្តដែននៃព្រះរាជកនិដ្ឋានោះដែរ ៗ ពួកមហា-

ជនក្នុងស្រុកនោះបានដឹងស្គាល់ថា ជាព្រះរាជបុត្រនៃព្រះមហាក្សត្រ ក៏នាំគ្នាគោរពប្រតិបត្តិស្រឡាញ់ពេញចិត្តបម្រើឥតធុញទ្រាន់. យូរបន្តិចទៅទូលព្រះរាជជេដ្ឋា ឲ្យផ្ញើសារទៅសុំព្រះរាជទ្រព្យពីព្រះមហាក្សត្រ ជាព្រះកនិដ្ឋ ។ ក៏ព្រមថ្វាយព្រះរាជទ្រព្យទៅព្រះជេដ្ឋាតាមសុំ ។ ក្រោយមកទៀត ពួកមហាជនក្នុងស្រុកនោះទូលពន្យល់ព្រះជេដ្ឋា ឲ្យផ្ញើសារទៅសុំស្រុកមួយទៀត ព្រះរាជាក៏ព្រមថ្វាយ ។ មិនយូរប៉ុន្មាន អ្នកស្រុកទូលពន្យល់ព្រះជេដ្ឋាសុំស្រុក, សុំនិគម, សុំជនបទ រហូតដល់សុំទីសេនាបតី សុំទីឧបរាជ ។ ព្រះមហាក្សត្រជាព្រះកនិដ្ឋាធិរាជ ក៏ព្រមថ្វាយគ្រប់មុខតាមសុំ មិនឲ្យទើសទាល់អធ្យាស្រ័យនៃព្រះជេដ្ឋាឡើយ ។

អបរភាគេ ចំណេរក្រោយមក មិនជាយូរប៉ុន្មាន ព្រះជេដ្ឋាធិរាជដែលបានទីជាមហាឧបរាជហើយ ក៏មានតណ្ហាកាន់តែចំរើនច្រើនឡើងតាមវេលា, បើទុកជាបានទីមហាឧបរាជហើយ ក៏នៅតែមិនទាន់ល្មមព្រះទ័យ ប្រាថ្នាឲ្យបានរាជសម្បត្តិទៀត ទើបលើកសេនារេហ៍ពលទៅចោមព័ទ្ធព្រះនគរនៃព្រះរាជកនិដ្ឋា ហើយផ្ញើសារទៅថ្វាយថា សុំរាជសម្បត្តិបើមិនព្រមឲ្យទេ នឹងច្បាំងគ្នា ។

ព្រះកនិដ្ឋាធិរាជបានទ្រង់ជ្រាបសេចក្តីសារហើយ កើតព្រះទ័យសង្វេគតក់ស្លុតថា ឱហ្ន៎! ព្រះជេដ្ឋារបស់អញ ដើមដំបូងមិនព្រម

ទទួលរាជសម្បត្តិតពីព្រះវររាជបិតា លើកប្រគល់ឲ្យអញ្ញហើយចេញទៅគង់នៅចុងកាត់មាត់ញក ដើម្បីឲ្យបានស្ងប់ស្ងាត់ព្រះទ័យ មិនដូច្នោះ បែរជាទៅជឿស្ដាប់ពាក្យសំដីរបស់ពួកមនុស្សអ្នកលោភយសសក្ដិ ប្រាក់មាសទៅវិញ គេទូលឲ្យសុំអ្វី ១ ពីអញ្ញចេះតែសុំតាមតាំងអស់ តាំងពីសុំរបស់តូច ១ រហូតដល់របស់ធំ ១ អញ្ញក៏ចេះតែថ្វាយគ្រប់មុខមិនទទឹងឥឡូវលើកទ័ពមកប្រុងនឹងច្បាំងដណ្ដើមយករាជសម្បត្តិពីអញ្ញទៀត បើអញ្ញច្បាំងក៏អាចយកជ័យជំនះបានដែរ ប៉ុន្តែ ខ្លួនអញ្ញខូចខាតជេដ្ឋាបចាយ-នធម៌ គឺសេចក្ដីគោរពកោតក្រែងចំពោះព្រះជេដ្ឋាធិរាជផង ធ្វើឲ្យអន្តរាយជីវិតមនុស្សជាច្រើនផង ព្រោះតែតណ្ហាជម្រុញអញ្ញឲ្យធ្វើសង្គ្រាម ។ គ្រានោះ ព្រះបរមពោធិសត្វ ឲ្យរាជបុរសទៅអញ្ជើញព្រះជេដ្ឋាធិរាជចូលមកគង់ព្រះបរមរាជវាំងហើយ លើករាជសម្បត្តិថ្វាយឲ្យគ្រប់គ្រងតទៅរួចទ្រង់លាព្រះជេដ្ឋាស្ដេចទៅគង់នៅព្រៃហិមពាន្ត សាងបណ្ណសាលាបួសជាតាបសចំរើនឈានជាសុខសម្រាន្តរៀងទៅ ។

ចំណែកមានៈ គឺសេចក្ដីប្រកាន់ខ្លួនប្រាណ លោកថាត់ជាឧបក្កិលេស តែងធ្វើចិត្តឲ្យសៅហ្មង ឲ្យញាប់ញ័រ ។ បើបុគ្គលណា ចេះតែសន្សំបណ្ដុះបណ្ដាលមានៈឲ្យកើតមានច្រើនឡើងហើយ បុគ្គលនោះតែងមានទុក្ខទោស មានសេចក្ដីវិនាសអន្តរាយជាច្រើនប្រការ តាំងពីខូច

ខាតរបស់បន្តិចបន្តួចរហូតដល់ខូចបង់ជីវិតខ្លួនជាទីបំផុត ដូចអតីតនិទាន
នៃព្រះបរមវង្សសាក្យរាជ ជាព្រះញាតិរបស់ព្រះពុទ្ធជាម្ចាស់នៃយើង
ព្រោះតែមានះប្រកាន់ខ្លួនថាមានជាតិ និងត្រកូលខ្ពង់ខ្ពស់ថ្លៃថ្នូរ បានជានៅ
វេលាដែលវិឌូឌកភជកុមារ ទៅគាល់ស្តេចមហានាមសាក្យរាជ ព្រះមហា
នាមប្រកាន់ព្រះអង្គថាមានជាតិមានត្រកូលខ្ពង់ខ្ពស់ជាសាក្យរាជ សំគាល់
ថា វិឌូឌកភជកុមារនោះមានជាតិថោកទាប ជាបុត្ររបស់នាងវាសភខត្តិយ-
ទេវី ជាធីតារបស់នាងទាសី លុះដល់វិឌូឌកភជកុមារត្រឡប់ទៅវិញ
ព្រះមហានាមសាក្យរាជ ប្រើឲ្យនាងទាសីលាងទីគង់របស់វិឌូឌកភជកុមារ
នឹងទឹកដោះ ៗ នាងទាសីនោះលាងបណ្តើរជេរបណ្តើរថា អញលាង
ក្តារជាកន្លែងអង្គុយរបស់វិឌូឌកភជកុមារ ជាបុត្រនៃនាងវាសភខត្តិយទេវី
ជាធីតារបស់នាងទាសី ៗ ក្នុងពេលដែលនាងទាសីកំពុងតែជេរនោះ
ជួនជាទាហានរបស់វិឌូឌកភជកុមារម្នាក់ភ្លេចអាវុធ ហើយវិលចូលទៅ
យកអាវុធរបស់ខ្លួនវិញ ស្រាប់តែបានឮសំដីនាងទាសី ជេរបណ្តើរ
លាងក្តារបណ្តើរ ទើបពាំនាំយកពាក្យនោះមកប្រាប់ដល់ទាហានទាំងពួង
រឿងនោះល្បីសុះសាយពេញបន្ទាយ ទាល់តែលេចឮដល់វិឌូឌកភជ-
កុមារ ។ ត្រិះរិះថា ឥ ធំ ហេតុ ការដែលពួកសាក្យរាជលាងក្តារ
កន្លែងអញអង្គុយនឹងទឹកដោះនេះលើកទុកសិនចុះ ចាំដល់គ្រាអញបាន

សោយរាជសម្បត្តិហើយ អញនឹងត្រឡប់មកម្តងទៀត អញនឹងលាងក្តារដោយលោហិតបំពង់កនៃសាក្យរាជ គិតដូច្នេះហើយ ក៏ស្ងៀមទុកក្នុងហឫទ័យ ។ អបរភាគេ លុះចំណេរកាលក្រោយមក ព្រះវិឌូឌភរាជកុមារនោះ បានសោយរាជសម្បត្តិហើយ ក៏លើកកងទ័ពទៅធ្វើសង្គ្រាមនឹងស្តេចសាក្យរាជ ប្រាប់ឲ្យពួកយោធាចាប់សាក្យរាជទាំងឡាយសាកសួរ បើសាក្យរាជអង្គណាប្រាប់ថាយើងជាសាក្យរាជ ក៏បង្គាប់ឲ្យទាហានសម្លាប់សាក្យរាជអង្គនោះចោលទៅ ឋបេត្វា វៀរលែងតែពួកសាក្យរាជដែលនៅជិតព្រះមហានាមសាក្យរាជជាព្រះអយ្យកោ ។ មានសាក្យរាជអង្គខ្លះគិតទាន់ ចាប់យកដើមបបុះនឹងបាច់ស្មៅមកទុកនឹងខ្លួន ហើយប្រាប់ថានេះមិនមែនសាក្យរាជទេ នេះជាដើមបបុះ នេះជាបាច់ស្មៅ ។

ពួកយោធាឮដូច្នោះ ក៏មិនសម្លាប់សាក្យរាជទាំងបីពួកខាងដើមនេះ ចំណែកសាក្យរាជទាំងឡាយដទៃដែលឥតធ្វើឧបាយកលអ្វីសោះ ក៏ត្រូវយោធាចាប់សម្លាប់ចោលទាំងអស់ លុះសម្លាប់រួចហើយ បង្គាប់ឲ្យត្រងយកឈាមបំពង់ករបស់សាក្យរាជទាំងអស់ ទៅលាងក្តារដែលព្រះបាទវិឌូឌភគង់ កាលពីព្រះកុមារនោះដូចសេចក្តីប្រាថ្នា ហើយឲ្យអញ្ជើញស្តេចមហានាមសាក្យរាជជាព្រះរាជអយ្យកោមក នឹងឲ្យសោយព្រះស្ងោយក្នុងព្រះសុវណ្ណភាជនៈជាមួយព្រះអង្គ ។

ស្តេចមហានាមសាក្យរាជនោះ មានអស្មិមានៈជាខ្លាំងណាស់ត្រាស់ថា យើងនឹងទៅជម្រះសរីរកាយឲ្យស្អាតបាតសិន ចាំត្រឡប់មកវិញលុះយាងទៅដល់ឆ្នេរស្ទឹងគង្គា ចងផ្នួងព្រះកេសាឲ្យជាប់មាំ ហើយលោតបុះទៅក្នុងទឹក សឹកម្រាមព្រះបាទក្នុងចំណងព្រះកេសា ដោយទ្រង់បំណងនឹងឲ្យអស់ព្រះជន្ម មិនព្រមសោយរួមជាមួយព្រះបាទវិឌូឌភៈជានុវសេរបស់នាងវាសភខត្តិយទេវីជាធីតារបស់នាងទាសី ។

នៅពេលដែលស្តេចមហានាមសាក្យរាជ លោតបុះទៅក្នុងទឹកនោះស្តេចនាគមកទទួលព្រះអង្គនឹងពាររបស់ខ្លួន ហើយនាំយកទៅទុកក្នុងពិភពនាគ ដោយហេតុនាគរាជគោរពក្នុងព្រះពុទ្ធគុណ ។

ម្យ៉ាងទៀត ដោយហេតុកុសលផលបុណ្យដែលស្តេចមហានាមសាក្យរាជនោះ បានធ្វើទុកពីជាតិមុនមក ។

ចំណែកព្រះបាទវិឌូឌភៈនោះ កាលបើធ្វើសង្គ្រាមឈ្នះស្រេចហើយក៏លើកកងទ័ពត្រឡប់ទៅព្រះនគរវិញ ។

៦ទិដ្ឋិ គឺគំនិតគិតឃើញមាន ២ យ៉ាង បើគិតឃើញត្រូវតាមផ្លូវធម៌ ឬតាមក្រសែព្រះពុទ្ធដីកា ហៅថា សម្មាទិដ្ឋិ នេះលោកមិនចាត់ជាឥញ្ចិតធម៌ គឺធម៌ធ្វើចិត្តឲ្យញាប់ញ័រទេ ។ បើគិតឃើញខុសពីគន្លងធម៌ ឬ ខុសពីព្រះពុទ្ធដីកា ហៅថា មិច្ឆាទិដ្ឋិ ។ នេះលោកចាត់ជាឥញ្ចិតធម៌ ប៉ុន្តែហៅកាត់ឲ្យខ្លីត្រឹមតែទិដ្ឋិប៉ុណ្ណោះ គឺលោកសំដៅយក មិច្ឆាទិដ្ឋិនោះឯង ។

បុគ្គលអ្នកមានគំនិតជាមិច្ឆាទិដ្ឋិ រមែងបានទទួលទុក្ខទោសផ្សេង ៗ តាំងពីស្រាល ៗ រហូតដល់ធ្ងន់បំផុតឃាត់សួគ៌ ឃាត់និព្វានដូចមានអតីតនិទានថា ឯកោ កិរ ឧបាសកោ បានឮថា មានឧបាសកម្នាក់ឈ្មោះមហាវេចកឧបាសក ជាអ្នកបាននូវអនុលោមខន្តិ ៗ ឧបាសកនោះខំប្រឹងចំរើនវិបស្សនាកម្មដ្ឋានខ្លាំងណាស់ ដើម្បីនឹងឲ្យបានសម្រេចព្រះសោតាផល ៗ លុះដល់មិនបានសម្រេចឲ្យទាន់តាមចិត្តប៉ុនប៉ង ក៏ត្រឡប់ជាយល់ឃើញខុសទៅវិញថា ព្រះពុទ្ធសាសនានេះមិនមែនជានិយ្យានិកនាំសត្វចេញចាកវដ្តសង្សារទេ មានទិដ្ឋិឃើញវិបលាសដូច្នេះ លុះអស់ជីវិតហើយទៅកើតជាសត្វក្រពើយ៉ាងធំ ៗ នេះជាទោសនៃមិច្ឆាទិដ្ឋិដែលស្រាលល្មម ៗ

មានអតីតនិទាមួយទៀតថា សុនក្ខត្តលិច្ឆវី ចូលបួសក្នុងព្រះពុទ្ធសាសនាហើយបាននូវទិព្វចក្ខុ ខាងក្រោយមកលោកខំធ្វើបរិកម្មភាវនាដើម្បីឲ្យបាននូវទិព្វសោតញ្ញាណទៀត ប៉ុន្តែលោកប្រឹងចំរើនភាវនាអស់រយៈវេលា ៣ ឆ្នាំ ក៏នៅតែមិនបានសម្រេចដូចបំណងសោះ ទើបលោកកំណត់ក្នុងចិត្តថា ព្រះពុទ្ធអង្គបានតែទិព្វចក្ខុម្យ៉ាងប៉ុណ្ណោះ គ្មានទិព្វសោតញ្ញាណទេ យល់វិបលាសខុសដូច្នេះហើយ ក៏ហេសិក្ខាបទសឹកចេញពី

ព្រះពុទ្ធសាសនា ទៅចូលសិក្សាលទ្ធិនៃអន្យតិរ្ថិយ៍ពួកនិគ្រន្ថនាដបុត្រទៅវិញ ។ សុនក្ខត្តលិច្ឆវី លុះអស់ជីវិតហើយទៅកើតក្នុងនរកអស់កាលជាយូរអង្វែង ។ ជនទាំងឡាយដែលតាំងនៅក្នុងមិច្ឆាទិដ្ឋិនោះ បើលះបេញមិនបានទេ ក៏មានទោសឃាត់សួគ៌និងឃាត់និព្វាន ។

ហេតុនេះ បានជាព្រះអរហន្តមិនស្ថិតនៅក្នុងឥញ្ជិតធម៌ ។ ធ្វើចិត្តឲ្យញាប់ញ័រ គឺតណ្ហា មានៈ និងទិដ្ឋិ ដែលមានទោសដូចបានពណ៌នារួចមកហើយ ។

សំដែងមកក្នុងគម្ពីរព្រះកថាវត្ថុដោយសង្ខេបត្រឹមប៉ុណ្ណេះ ។ គម្ពីរព្រះកថាវត្ថុនេះ សម្តេចព្រះមានព្រះភាគទេសនាដប់បី (១៣) ថ្ងៃទើបចប់ គឺជាព្រះធម្មក្ខន្ធប្រាំពីរពាន់មួយរយ (៧.១០០) ព្រះធម្មក្ខន្ធ, កាលទ្រង់សំដែងចប់ហើយ ទេវតាទាំងឡាយបានសម្រេចព្រះអរិយមគ្គព្រះអរិយផលបូករួមបានប្រាំពីរ (៧) កោដិដោយប្រមាណ ព្រះអាចារ្យកំណត់ទុកដូច្នេះ ។

ចប់ គម្ពីរព្រះកថាវត្ថុ តែប៉ុណ្ណោះ

---

( នៅមានត )

## មធុរសវាហិនី

# សម្ដេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង

ព្រះញាណកោសល ញាណ-ឈឹន ពិនិត្យ

(តមក)

---

បុរសកំសត់ក៏ញាំងចិត្តជ្រះថ្លាឲ្យកើតឡើងហើយពោលថា: ការឲ្យសំពត់នេះ សូមឲ្យសំរេចប្រយោជន៍ដល់អ្នក ដើម្បីប្រើប្រាស់ជាសុខសប្បាយចុះ ពោលយ៉ាងនេះហើយក៏ឲ្យសំពត់នោះដល់ចោរ ហើយលះបង់ចោលផ្លូវធំ វេះគេចដើរទៅតាមផ្លូវតូចដទៃល្មមដើរបានតែជើងមួយ សឹងចង្អៀតគាន់គាប់ដោយស្មៅជាដើម ហេតុតែសេចក្ដីភិតភ័យខ្លាចចោរ ព្រោះខ្លួនស្លៀកសំពត់ពីរជាន់នោះឯង ។ លុះបុរសនោះដើរតាមផ្លូវទៅ ក៏ប្រទះនឹងពស់វែកមួយពេននៅជិតផ្លូវ ពស់ពុចឹកបុរសនោះដកបដល់ក្សិណក្ស័យជីវិតទៅ បន្ទាប់ពីនោះ បានអន្ទោលទៅកើតជាទេវពជមួយអង្គមានស្រីទេពអប្សរមួយពាន់ចោមរោមជាបរិវារ ស្ថិតនៅក្នុងវិមានមាសមានកំពស់ប្រមាណ ១២ យោជន៍ ក្នុងព្រៃហិមពាន្ត មានដើមកប្បព្រឹក្សដុះព័ទ្ធជុំវិញវិមានមាសនៃទេវបុត្រនោះ ក្នុងទីប្រមាណ ៣០ យោជន៍ សឹងប្រកបដោយសម្បត្តិទាំងពួងមានសំពត់ទិព្វជាដើម កើតឡើងដោយផលានិសង្សដែល ទេវបុត្រនោះនៅជាបុរសកំសត់ បានឲ្យទានសំពត់សាដកមួយដល់ចោរនោះឯង ។

ឯទេវបុត្រនោះសោត កាលបើបានសោយនូវទិព្វសម្បត្តិដ៏ប្រសើរយ៉ាងនេះហើយ ក៏ពោលនូវព្រះគាថាជាអាទិ៍ដូច្នេះថា: "បរិណាមិត មត្តេន ធានស្ស សកាសត្តគាំ" ជាដើម ។ អធិប្បាយថា ខ្ញុំបានឲ្យសំពត់ជារបស់ខ្លួនដល់ចោរគ្រាន់តែបង្អោនចិត្តឲ្យជាទានប៉ុណ្ណោះ សឹងមានឥស្សរិយយសដ៏ប្រសើរ មានវិមានផុសឡើងកំពស់ ១២ យោជន៍ ជាទីកំបាំងភ្នែក គឺបុគ្គលឃើញបានដោយក្រ សឹងប្រដាប់ដោយផ្ទះកំពូលដ៏ល្អប្រសើរមានពណ៌មាសសុទ្ធ បង្កើតឡើងដោយបុណ្យរបស់ខ្ញុំ មានប្រដាប់ដោយទង់ជាយទង់ជ្រុងដ៏ច្រើន ប្រកបដោយពិតានដ៏បរិសុទ្ធក្នុងព្រហ្មពានូនោះឯង ។ ហើយមានសំពត់ទិព្វសុំយុងចុះ នៅចុងសស្សរនៃប្រាសាទដោយជុំវិញ នឹងសំយុងចុះមកក្រោមដេរដាសលើផែនដីល្អរុងរឿងក្រៃពេក ។

ម្យ៉ាងវិញទៀត ក្នុងទីបរិវេណប្រមាណ ៣ យោជន៍ដោយជុំវិញនៃប្រាសាទនោះ មានដើមកប្បព្រឹក្សជាច្រើនទៀតអាចឲ្យសម្រេចលទ្ធផលតាមតែចិត្តនឹក បើនឹកចង់បានវត្ថុណា ៗ នឹងបាននូវវត្ថុនោះ ៗ តាមប្រាថ្នាពិត ។

ឯខ្ញុំសឹងមានចិត្តរីករាយក្នុងគតរបស់ខ្ញុំ ដោយស្រីទេពអប្សរប្រមាណមួយពាន់ ចោមរោមបំរើដោយល្បែងរាំច្រៀងផ្គុំមកូតប្រគំភ្លេងតូរ្យតន្ត្រីក្នុងវិមាននោះឯង ។

ផលដែលប្រាកដយ៉ាងនេះ មិនមែនជាផលដែលខំឲ្យទានសំពត់ដោយសទ្ធាល្អឡើយ គ្រាន់តែជាផលដែលបានឲ្យទានសំពត់ដល់ចោរមិនមែនជាស្រែបុណ្យល្អប៉ុណ្ណោះឯង ៗ ប្រសិនបើបុគ្គលបានឲ្យទានដោយប្រណីតបញ្ចង់ ដល់បុគ្គលអ្នកមានសីលជាស្រែបុណ្យល្អហើយ នរណាមួយអាចនឹងពណ៌នាសរសើរ នូវផលានិសង្សរបស់បុគ្គលនោះបាន ៗ

ព្រោះហេតុដូច្នោះ ព្រះអរហន្តទាំងឡាយ លោកពោលជាបទព្រះគាថាដូច្នេះថា :

ឯវំ វិធម្បិ កុសលំ មនុជោ ការិត្វា
បប្បោតិ និព្វិករំ មុនិវណ្ណនីយំ
មត្វាន យោ ទទាតិ ទានវរំ សុសីលេ
សទ្ធាយ សុទ្ធមនសា សវិសេសកាតីតិ

អធិប្បាយថា: សត្វដែលបានកើតជាមនុស្ស បានធ្វើនូវកុសលមានប្រការយ៉ាងនេះហើយ រមែងបានដល់នូវសម្បត្តិទិព្វដ៏ប្រសើរ គួរអ្នកប្រាជ្ញពណ៌នាសរសើរដោយពិត បុគ្គលណាបានដឹងផលយ៉ាងនេះហើយបានឲ្យទានដ៏ប្រសើរ ដល់បុគ្គលអ្នកមានសីលល្អបរិសុទ្ធ ដោយចិត្តដ៏ស្អាតដោយសទ្ធាជឿកម្មជឿផលឥតកម្រើក បុគ្គលនោះនឹងមានចំណែកសម្បត្តិទិព្វដ៏វិសេសក្នុងលោក អាចនឹងបាននូវសេចក្តីសុខទាំង ៣ ប្រការគឺសុខមនុស្ស ១, សុខទេវតា ១, សុខក្នុងព្រះនិព្វាន ១ ដោយពិត ៗ

សំដែងរឿងនិទានអញ្ញតរបុរសមានឈ្មោះពុំប្រាកដ ជាគំរប់ពីរក្នុងវគ្គទីពីរ គឺចប់សេចក្ដីជាសង្ខេបតែប៉ុណ្ណោះឯងហោង ។

## វិសមលោមកុមារវត្ថុកថា

សំដែងរឿងនិទានវិសមលោមកុមារតទៅទៀត ដោយបាលីថា: អតីតេ ភិក្ខវេ ជម្ពូទីបេ ដូច្នេះជាដើម ។

អធិប្បាយថា: ភិក្ខុ បានឮរឿង ១ មក នាកាលអតីតកាលកន្លងលើសទៅយូរណាស់ហើយ ក្នុងជម្ពូទ្វីបនេះ មានព្រះសម្មាសម្ពុទ្ធមួយព្រះអង្គទ្រង់ព្រះនាមកស្សប: ព្រះអង្គបានបំពេញព្រះបារមីពេញលេញបរិបូណ៌ហើយ បានដល់នូវសម្បត្តិសព្វញ្ញុតញ្ញាណ ជាអង្គព្រះសម្មាសម្ពុទ្ធត្រាស់ដឹងប្រាកដក្នុងលោក ព្រះអង្គតែងសំដែងធម៌បន្ទោបង់នូវកងទុក្ខទាំងពួងរបស់សត្វលោក ព្រះអង្គនាំមកនូវសេចក្ដីសុខដល់សត្វលោក ហើយញ៉ាំងសត្វលោក ឲ្យស្ថិតនៅក្នុងគុណធម៌សម្រាប់ដល់នូវនគរគឺអមតមហានិព្វានដោយពិត ។

សម័យនោះ មានអញ្ញតរបុរសម្នាក់ បានស្ដាប់ធម៌ទេសនាហើយក៏មានចិត្តជ្រះថ្លាបានថ្វាយទានដល់ព្រះសង្ឃជាច្រើន បានរក្សាសីលប្រាំសីលប្រាំបី តែងប្រព្រឹត្តធ្វើនូវបុញ្ញកម្មទាំងឡាយផ្សេង ១ ដរាបដល់អស់អាយុ ហើយបានទៅកើតក្នុងស្ថានទេវលោកដោយឆាប់រហ័ស បីដូចជា

ភ្ញាក់អំពីដេកលក់ដូច្នោះ សឹងមានស្រីទេពអប្សរមួយពាន់ចោមរោមជាបរិវារ ស្ថិតនៅក្នុងវិមានដ៏សម្រេចដោយកែវ ៧ ប្រការ ជាសុខក្សេមក្សាន្ត ។ លុះស្ថិតនៅក្នុងស្ថានទេវលោកនោះ កំណត់អស់អាយុហើយច្យុតចុះមកអំពីស្ថានទេវលោកនោះ ក្នុងកាលព្រះមានព្រះភាគជាម្ចាស់នៃយើងព្រះអង្គចូលព្រះនិព្វានទៅហើយ បានមកកើតក្នុងផ្ទៃព្រះអគ្គមហេសីនៃព្រះនរិន្ទ្រាធិបតីធម្មាសោកករាជ ជាស្ដេចចក្រពត្តិ សោយរាជ្យក្នុងនគរបាតលីបុត្តព្វដ៏ជម្ពូទ្វីបនេះឯង ។ ព្រះបាទធម្មាសោករាជ ព្រមទាំងព្រះរាជវង្សានុវង្ស បានសន្មតនាមព្រះរាជកុមារថា វិសមលោមកុមារ ព្រោះកុមារនោះ កាលកើតឡើងមានរោមក្រញាញ់ពុំស្មើ តែមានសម្បុររូបរាងល្អពន់ពេក គួរជាទីស្រឡាញ់ពេញចិត្តនៃជនទាំងពួង ។

លុះវិសមលោមកុមារនោះ បានដល់នូវភាវដ៏ចំរើនវ័យធំឡើងជាលំដាប់ហើយ សឹងបរិបូណ៌ដោយកម្លាំងកាយ វិសេសជាងជនទាំងឡាយនានា ដោយផលានិសង្សដែលកុមារបានឲ្យទានគោជនមានបាយទឹកជាដើម អំពីជាតិមុននោះឯង ។

ម្យ៉ាងទៀត កុមារនោះមានកម្លាំងច្រើន មានរូបល្អគួរជាទីជ្រះថ្លាដល់ប្រជុំជន ទាំងគួរដល់កិរិយាគយគន់មើលនៃជនទាំងឡាយ ហើយបរិបូណ៌ដោយបរិវារគាមហែហមគាល់បំរើជាច្រើន ។

លុះដល់សម័យមួយជាខាងក្រោយ សម្ដេចព្រះនរិន្ទ្រាធិបតី ធម្មា-

សោកកជ ដែលមានស្តេចប្រាំបីម៉ឺនបួនពាន់ព្រះអង្គ ហែមកោមជាបរិវារ ព្រមទាំងពួកពលពាហនដ៏ច្រើន ព្រះអង្គប្រាថ្នាចង់ប្រពាតព្រៃកំសាន្តព្រះទ័យ ហើយស្តេចយាងចេញទៅកាន់ព្រៃហិមពាន្ត ដើម្បីក្រសាលសប្បាយដោយសមគួរតាមអភិរម្យហើយ លុះស្តេចត្រឡប់មកវិញបានដល់ស្ទឹងឈ្មោះចន្ទភាគា ឯស្ទឹងនោះសោត មានទទឹងមួយយោជន៍ មានជម្រៅបីគាវុតជាកំណត់ វេលានោះស្ទឹងនោះឯងសឹងមានខ្យល់បក់មកខ្លាំង កើតជារលកទឹកបោកមកផ្ទប់ទីងច្រាំងទាំងសងខាង បែកពពុះទឹកដ៏ ១ មុខគួរខ្លាចពន់ពេក ហើយហូរទៅហ័ស ៗ

កាលនោះ ព្រះបាទធម្មាសោកកជ ទ្រង់បានទតទៅឃើញស្ទឹងនោះហើយ ទ្រង់ត្រាស់សួរថា: បណ្តាបុរសក្នុងចំណោមនេះ មានបុរសណាមួយ អាចហ៊ានហែលឆ្លងស្ទឹងធំមានសភាពយ៉ាងនេះដែរឬ ?

ឯបុរសទាំងឡាយក៏ពុំអាចនឹងហែលឆ្លងបានឡើយ មានតែវិសមលោមកុមារម្នាក់ឯង បានស្តាប់ព្រះរាជឱង្ការត្រាស់សួរដូច្នោះហើយ ក៏ដើរសសៀរចូលមកជិតលើកដៃឡើងប្រណម្យ ក្រាបបង្គំទូលថា: បពិត្រព្រះសម្មតិទេព ! ខ្ញុំព្រះករុណាថ្វីវិសេសអាចហ៊ានហែលឆ្លងស្ទឹងនេះទៅត្រើយខាងនាយ ហើយហែលត្រឡប់មកវិញបាន សូមព្រះអង្គទ្រង់ជ្រាប ។

លុះព្រះបរមក្សត្រិយ៍ ទ្រង់ព្រះសណ្តាប់ហើយក៏ទទួលព្រម ទ្រង់

ត្រាស់ថាសាធុប្រពៃហើយ ៗ ណា! គ្រូវអ្នកឯងហែលធ្លងចុះ យើងនឹងរង់ចាំមើលក្នុងទីនេះឯង ។

កាលនោះ វិសមលោមកុមារ បានទទួលព្រះរាជឧង្ការស្រេចហើយ ក៏ស្លៀកសំពត់គៀតយ៉ាងមាំចងសក់ឲ្យជាប់ ហើយឈរទៀបមាត់ប្រាំងក៏លោតឡើងទៅលើអាកាស កំពស់ ១៨ ហត្ថ ធ្លាក់ចុះទៅក្នុងស្ទឹងមានចម្ងាយអំពីមាត់ប្រាំងប្រមាណមួយឧសភ ហើយប្រារព្ធដើម្បីហែលធ្លងទៅ ។

លំដាប់ដែល វិសមលោមកុមារ ហែលកាត់ខ្សែទឹកដ៏កាចធ្លងទៅធ្លងមក សឹងមានក្រពើ ធ្លាម-មករ កាចសាហាវទាំងឡាយ រហែលដេញតាមមក ដើម្បីចាំចាំនាំយកទៅ ជាចំណីអាហាររ ៗ វិសមលោមកុមារក៏យកដៃប្រហារទះតប់ក្រពើធ្លាម - មករទាំងឡាយឲ្យក្ស័យខ្ទេចខ្ទី ជាកំទេចតូច - ធំ ព្រមទាំងសម្លាប់សត្វដែលមានពិសអស់ជាច្រើន ក៏បានត្រឡប់ឡើងមកកាន់ត្រើយខាងទីគោកវិញ ហើយចូលក្រាបថ្វាយបង្គំព្រះបរមក្សត្រ ឋិតនៅក្នុងទីដ៏សមគួរក្នុងកាលនោះឯង ។

(នៅមានត)

# លោក អ៊ុម-ភន បម្លងពីសាស្ត្រាស្លឹករឹត

ព្រះពុទ្ធវង្ស កិប-តូរ ពិនិត្យ

(តមក)

---

រាជា សេនកំ បុច្ឆិ ។ ព្រះបាទវិទេហរាជ មានព្រះបន្ទូលដណ្តឹងអាចារ្យសេនកថា សេនក ហៃអាចារ្យសេនកអើយ, រីអាថិប្រស្នាអញ តើអាចារ្យដឹងហើយឬនៅឡើយ, អាចារ្យសេនក ទូលថា បពិត្រព្រះមហារាជអើយ, បើអញខ្ញុំមិនដឹងហើយ តើនឹងមានអ្នកឯណាដទៃដឹងក្រៃលែងជាងខ្ញុំវិញ; ស្តេចថា បើអាចារ្យដឹងដូច្នោះ ចូរឆ្លើយមកៗ ទើបអាចារ្យសេនកទូលថា ទេវ បពិត្រមហារាជអើយ, អញ្ជើញព្រះអង្គទ្រង់ព្រះសណ្តាប់ ខ្ញុំនឹងឆ្លើយថ្វាយព្រះអង្គហោង ។ ទើបអាចារ្យសេនកសូត្រនូវបទព្រះគាថា ដែលអាត្មាបានរៀនយកមកអំពីពោធិសត្វនោះថា :

ឧក្កបុត្តរាជបុត្តិយានំ
ឧរត្ថមំសំ បិយំ មនាបំ
ន តេ សុនខស្ស អទេន្តិ មំសំ
អថ មេណ្ឌស្ស សុណេន សំខ្យមស្សាតិ ។

មហារាជ បពិត្រមហារាជអើយ, ឧរត្ថមំសំ រីសាច់ភ្លៅ,

សាច់ព្រាយទាំងឡាយ, ធិរេហិ មនោរំ ជាទីស្រឡាញ់គាប់ចិត្ត, ឧត្តមបុត្តរាជបុត្តិយោហិ នៃកូនព្រះរាជវង្សនិងកូនមន្ត្រីទាំងឡាយ, តេ ឧត្តមបុត្តរាជបុត្តី រីកូនព្រះរាជវង្សនូវកូនមន្ត្រីទាំងឡាយនោះ, ន អវេក្ខិ មិនដែលធី, មំសំ នូវសាច់, សុណខស្ស នៃឆ្កែ; អថ បទដ្ឋានហោង, តាំខ្យំ រីសភាពជាមិត្ត មេណ្ឌស្ស នៃពពែ, សុណខ នូវឆ្កែនោះ, អស្ស ករវេយ្យ គប្បីមានហោង ។

រីអាចារ្យសេនក សូម្បីសូត្រនូវគាថាអម្បាលនោះហើយក្តី ក៏មិនដឹងនូវកាបិសេចក្តីនោះឡើយ ។ រីព្រះមហាក្សត្រ ព្រះអង្គស្តាប់ពាក្យអាចារ្យសេនកទូលឆ្លើយដោះសារាកាចិប្រស្នានូវប្រការអម្បាលនោះក្តី ស្តេចជ្រាបសុភាពដោយនូវហេតុហើយ ស្តេចដណ្តឹងទៅអាចារ្យបុក្កុសថា នែអាចារ្យបុក្កុសអើយ, រីប្រស្នានេះ អាចារ្យសេនកនេះដឹងហើយ, ចុះអាចារ្យឯងតើដឹងឬទេ? ។ អាចារ្យបុក្កុសទូលថា បពិត្រមហារាជអើយ, ខ្ញុំមិនជាអ្នកប្រាជ្ញ ឬ ម្តេចព្រះអង្គ? ទើបអាចារ្យបុក្កុសសូត្រនូវគាថាដែលអាត្មាបានរៀនមកនោះថា :

ចម្មំ វិហានន្តិ ឯឡកស្ស
អស្សបិដ្ឋត្ថរណាំ សុណខស្ស ហោតុ
ន តេ សុណខស្ស អស្សបិដ្ឋត្ថរណាំ
អថ មេណ្ឌស្ស សុណេន សំខ្យាសេវនំ ។

មហារាជ បពិត្រមហារាជអើយ, ជនា រីអ្នកផងទាំងឡាយ, វិហាឧដ្ឋិ សម្លាប់, ឯឡកាសង្ឃ នូវពពែ, ចម្មំ យកស្បែក អស្សបិដ្ឋត្ថរណំ ប្រយោជន៍ជាកំរាលលើខ្នង, សុនខស្ស ហេតុ ព្រោះហេតុនៃឆ្កែ; តេ ជនា រីអ្នកផងទាំងឡាយនោះ, ន វិហាឧដ្ឋិ មិនដែលសម្លាប់, សុនខស្ស នូវឆ្កែ, អស្សបិដ្ឋត្ថរណំ ដ៏ជាកំរាលខ្នងសេះ, អថ បទហេតុដូច្នោះ, សខ្យំ រីសេភាពជាមិត្ត, មេណ្ឌស្ស នៃពពែ, សុនខេន នូវឆ្កែ, អស្ស ករេយ្យ គប្បីមានហោង ។

ស្តេចស្តាប់ហើយ មានព្រះបន្ទូលដណ្តឹងទៅអាចារ្យកាមិន្ទថា រីអាចារ្យបុក្កុសនេះដឹងហើយ, ចុះឯអាចារ្យឯង តើញាំងដឹងហើយឬនៅឡើយ ។ រីអាចារ្យកាមិន្ទសូត្រនូវព្រះគាថាដូចអាត្មាបានរៀននោះថ្វាយព្រះមហាក្សត្រថា :

អាវេល្លិតសិង្គិកោ ហិ មេណ្ឌោ
ន ហិ សុនខស្ស វិសាណកានិ អត្ថិ
តិណភក្ខោ មំសភោជនោ ច
អថ មេណ្ឌស្ស សុណេន សខ្យមស្សាតិ ។

មហារាជ បពិត្រមហារាជអើយ, មេណ្ឌោ រីពពែ, តិណភក្ខោ សីនឹងស្មៅ, សុនខោ រីឆ្កែ, មំសភោជនោ

មានសាច់ជាចំណី, អជ បទហេតុដូច្នោះ, សំឲ្យំ វែសភាពជាមិត្ត, មេណ្ឌស្ស នៃពពែ អស្ស- ករេយ្យ គប្បីមាន, សុឆេទ ដោយឆ្កែនោះហោង ។

ស្តេចស្តាប់ពាក្យនោះហើយដណ្តឹងទៅអាចារ្យទេវិន្ទថា ហៃអាចារ្យទេវិន្ទអើយ, រីអាចារ្យកាមិន្ទនេះដឹងហើយ ចុះអាចារ្យឯង តើញុំងដឹងហើយឬនៅឡើយ ។ អាចារ្យទេវិន្ទសូត្រនូវព្រះគាថាថ្វាយព្រះមហាក្សត្រ ដោយអត្ថាបានរៀននោះថា :

តិណមាសិ បលាសមាសិ មេណ្ឌា
ឆ សុភោ តិណមាសិ ភោ បលាសំ
កណ្ហោយ្យ សុឆេទោ សសំ វិឡារំ
អជ មេណ្ឌស្ស សុភេទ សំឲ្យមស្សក្តំ ។

បពិត្រមហារាជអើយ, មេណ្ឌា រីពពែ, តិណមាសិ គឺស៊ីស្មៅ បលាសមាសិ គឺស៊ីកឈើ, សុឆេទោ រីឆ្កែ កណ្ហោយ្យ ចាប់យក សសំ នូវទន្សាយ វិឡារំ នូវឆ្មា, អជ បទដូច្នោះ, សំឲ្យំ វែសភាពជាមិត្ត មេណ្ឌស្ស នៃពពែ សុឆេទ នូវឆ្កែ អស្ស ករេយ្យ គប្បីមានហោង ។

លំដាប់នោះ ស្តេចស្តាប់ពាក្យអាចារ្យទាំង ៤ រូបដោយខ្លួនទីទៃ ។

ដូច្នោះហើយ, ស្តេចមានព្រះបន្ទូលដណ្តឹងទៅកាន់ពោធិសត្វថា: តាត មហោសថ ម្នាលមហោសថអើយ ! អាថ៌ប្រស្នានៃអញនោះ តើបានដឹងហើយ ឬ នៅឡើយ ? ។ ពោធិសត្វទូលថា បពិត្រមហារាជ ក្សត្រថ្លៃប្រសើរអើយ! ចាប់តាំងពីអវិចិនរក ដរាបដល់ភវគ្គព្រហ្ម បើវៀរតែខ្ញុំឯងហើយ តើមានអ្នកឯណាមួយដទៃ ក៏នឹងអាចដឹងនូវអាថ៌ប្រស្នាព្រះអង្គនោះបាន ? ។ ស្តេចស្តាប់ហើយមានព្រះបន្ទូលថា បើដឹងដូច្នោះ ចូរបាសំដែងមកហោង ។ ពោធិសត្វនឹងសំដែងនូវសភាពប្រាកដនៃអាត្មាបានដឹងកិច្ចការនោះទូលព្រះមហាក្សត្រថា មហារាជបពិត្រមហាក្សត្រថ្លៃប្រសើរអើយ! សុណាថ អញ្ជើញស្តេចស្តាប់ ខ្ញុំនឹងឆ្លើយថ្វាយព្រះអង្គហោង, ទើបពោធិសត្វសូត្រនូវព្រះគាថាពីរបទថា៖

អដ្ឋុប្បាតោ ចតុប្បទស្ស មេណ្ឌោ
អដ្ឋនខោ អធិស្សមានកាយោ
ឆាទិយំ អាហារតិ អយំ ឥមស្ស
មំសំ អាហារតិ អយំ អមុស្ស ។
ឆាសាឧវរកតោ វិទេហសេដ្ឋោ
វីតិហារំ អញ្ញោញ្ញភោជនានំ
អនត្វា ភារ សត្វតំ ជនិន្ទោ
ភោក្កុត្វស្ស បុណ្ណមុខស្ស ចេតន្តិ ។

បពិត្រមហារាជអើយ ! មេណ្ឌា ពពែ, អដ្ឋខុរោ មានជើង ៨ កន្ទុះ, ចតុប្បទស្ស នៃជើង ៤, អដ្ឋនខោ មានក្រចក ៨, អធិស្សមាណកាយោ មានខ្លួនពុំឲ្យប្រាកដកាលយកសាច់នោះ, អយំ មេណ្ឌា ពពែនេះ, អាហរតិ នាំមក, មំសំ នូវសាច់, ឥមស្ស ដល់ឆ្កែនេះ, អាហរតិ នាំមក, តិណំ នូវស្មៅ ឆាធិយំ ដែលគេគ្របទុកក្រោមផ្ទះ ឯទ្យកស្ស ដល់ពពែនេះ ។

មហារាជ បពិត្រមហារាជអើយ ភារៈ ដោយពុមក, ហរិយ្យោ នាំអំពីម្សិលមិញ, ជនិន្ទោ ព្រះមហាក្សត្រដ៏ជាធំក្រៃលែងអ្នកផង, វិទេហសេដ្ឋោ ប្រសើរក្រៃលែងអ្នកស្រុកវិទេហរាស្ត្រទាំងឡាយ, បាសាទវរគតោ ឡើងទៅលើប្រាសាទ, អនគ្ឃ ក៏បានយល់, ឯតំ សង្គតិំ នូវសភាពជាមិត្តនោះ, ទ្វិន្នំ សត្តានំ នៃសត្វទាំងពីរ, រតិហារំ ដ៏រើសអាហារឲ្យគ្នា, អញ្ញោញ្ញភោជនានំ ដ៏នាំអាហារឲ្យគ្នាទៅវិញទៅមក, ភោកុត្តស្ស ច នៃឆ្កែក្តី, បុណ្ណមុខស្ស ច នៃពពែក្តី ។

ស្តេចស្តាប់ហើយ មានព្រះហឫទ័យត្រេកអរសោមនស្សក្រៃ ទ្រង់ព្រះចិន្តាថា ប្រស្នាអញនេះ អ្នកប្រាជ្ញទាំង ៤ ដឹងដោយនូវអំណាចនៃអាត្មាឯង ស្តេចពុំជ្រាបសភាពជាអ្នកប្រាជ្ញទាំង ៤ ទៅអាស្រ័យរៀនអំពីពោធិសត្វឡើយ ហើយស្តេចមានព្រះបន្ទូលថា ហៃអ្នកប្រាជ្ញទាំងឡាយ

អើយ មានសំដីនោះពីរោះអាចដោះនូវអាថ៌ប្រស្នាដ៏ល្អិតកំបាំងជ្រៅ បិតព ដ៏ត្រកូលជាលាភនៃអញ គឺអញអរក្រៃពេក អញឲ្យនូវរាជរថទឹមនូវសេះ អាជានេយ្យនោះមួយម្នាក់ នូវស្រុកប្រសើរមានទ្រព្យច្រើននោះមួយម្នាក់ ហោង, ស្ដេចមានព្រះបន្ទូលដូច្នោះហើយ ព្រះរាជទានឲ្យទ្រព្យនូវស្រុក ទាំងនោះ មកអ្នកប្រាជ្ញទាំង ៤ នោះហោង ។

ទ្វាទសនិបាតេ មេណ្ឌបញ្ហោ និដ្ឋិតោ ។ រីនឹងស្រដី ប្រស្នាក្ដីនឹងពពៃ មានក្នុងទ្វាទសនិបាតនោះមិញ គឺស្រេចនូវប្រការ អម្បាលនោះឯងហោង ។ ឧទុម្ពរទេវី បង បពិត្រអើយ! រីនាង ឧទុម្ពរទេវី នាងដឹងថាអ្នកប្រាជ្ញទាំង ៤ នោះ ទៅអាស្រ័យរៀនអាថ៌ប្រស្នា នោះ អំពីមហោសថប្រាកដដូច្នោះក្ដី នាងលីលាទៅកាន់ព្រះមហាក្សត្រ ហើយទូលដណ្ដឹងថា ទេវ បពិត្រមហារាជអើយ អម្ចាស់ធ្វើ នូវសក្ការបូជាអ្នកប្រាជ្ញទាំង ៤ នោះស្មើគ្នា ប៉ុនគ្រាប់សណ្ដែកមួយនោះ ក៏យល់ពុំគួរឡើយ, គួរតែព្រះអង្គបូជាមហោសថប្អូនខ្ញុំ ឲ្យលើសនោះ ក៏យល់ថាគួរ, រីអាថ៌ប្រស្នាអម្ចាស់នោះ តើអ្នកឯណាឯងអាចឆ្លើយបាន ? ស្ដេចស្ដាប់ហើយថា ភទ្ទេ ម្នាលនាងអើយ ! រីអាថ៌ប្រស្នាអញនេះ គឺអ្នកប្រាជ្ញទាំង ៤ ឯងអាចដឹងឆ្លើយបាន ។ នាងទូលថា បពិត្រមហារាជអើយ ! រីអ្នកប្រាជ្ញទាំង ៤ ដឹងអាថ៌ប្រស្នាអម្ចាស់នេះ, ហេតុអាស្រ័យនឹងអ្នកឯណា ? ។ ស្ដេចថា អញមិនបានដឹងឡើយ ។ ទើបនាងទូល

វិញថា បពិត្រអម្ចាស់ដ៏ជាស្តេចធំឧត្តមប្រសើរអើយ ! អាចារ្យទាំង ៤ នោះដឹងអ្វីព្រះអង្គ, អាថ៌ប្រស្នានេះ គឺមហោសថអ្នកប្រាជ្ញ អាចប្រដៅពុំឲ្យអ្នកកំឡៅទាំងនេះវិនាសចេញអំពីស្រុកឡើយ, ហេតុម្តេចក៏អម្ចាស់ធ្វើសក្ការបូជាអស់អ្នកទាំងនោះស្មើនឹងមហោសថប្អូនខ្ញុំដូច្នេះ អែ-តើនោះយល់ពុំគួរឡើយ, គួរតែអម្ចាស់បូជាមហោសថឲ្យលើស ឲ្យផ្សេងហោង ។

ស្តេចស្តាប់ហើយ មានព្រះទ័យនោះត្រេកអរនឹងពោធិសត្វ ទ្រង់ព្រះចិន្តាគិតថា មហោសថនេះ មានប្រាជ្ញានោះអាចដឹងអាថ៌ប្រស្នាផងទាំងពួងនោះ ឥតទើសទាល់អាស្រ័យនៃអាត្មាឯង ឥតអ្នកឯណាប្រាប់ឡើយ បើដូច្នោះ អ្នកនឹងដណ្តឹងនូវប្រស្នាឈ្មោះ សិរីមេណ្ឌបញ្ហា ឲ្យមហោសថកូនអញឆ្លើយ ហើយអញនឹងបូជាសក្ការៈនោះច្រើន ក្នុងកាលដែលឆ្លើយបាននោះហោង ។

ឯកាធិវសំ មានកាលសម័យថ្ងៃមួយ អ្នកប្រាជ្ញទាំង ៥ ឡើងគាល់អង្គុយនាឋានមួយសមគួរនឹងអាត្មា ហើយ ស្តេចមានព្រះបន្ទូលទៅនឹងអាចារ្យសេនកថា សេនក ហៃអាចារ្យសេនកអើយ អញនឹងដណ្តឹងនូវប្រស្នាមួយ ។ អាចារ្យសេនកថា ចូរអម្ចាស់បន្ទូលដណ្តឹងមកហោង ។

( នៅមានត )

ផ្នែកអក្សរសាស្ត្រ

វប្បធម៌ខ្មែរ

# គុណប្រយោជន៍នៃសារមន្ទីរ

លោក លី · ធាមតេង

សមាជិកក្រុមអភិបាល សមាគមអ្នកនិពន្ធខ្មែរ

រៀបរៀង

នៅក្នុងរាជធានីភ្នំពេញ ដែលជាមជ្ឈដ្ឋានធំបំផុតខាងវប្បធម៌នៃប្រទេសកម្ពុជា យើងឃើញមានសារមន្ទីរ, សាលាវិចិត្រសិល្បៈខេមរៈ, បណ្ណាល័យ, មន្ទីរស្រាវជ្រាវមុខវិជ្ជាផ្សេង ៗលៗ អាគារទាំងនោះហើយ ដែលជាជម្រកនៃវត្ថុជាកស្តុតាងរបស់វប្បធម៌បុរាណយើង ។

វេលានេះ យើងល្បងរែកញែកបន្តិចចុះពីវត្ថុទាំងនោះ ដើម្បីបើកស្មារតីយើងឲ្យឃើញកាន់តែប្រាកដឡើង ។ មើលចុះ នៅក្នុងសារមន្ទីរជាតិ ដែលពាក្យសាមញ្ញខ្លះនិយមហៅថាសាលារចនា យើងឃើញមានវត្ថុបុរាណច្រើនណាស់ ដែលច្រើនតែធ្វើអំពីលោហធាតុ ឬពីសិលាជាតិ ។ ពិតមែនហើយ លោហធាតុនឹងសិលាជាតិទាំងនោះ ពុំចេះបញ្ចេញពាក្យប្រាប់យើងអំពីតម្លៃនឹងរឿងរ៉ាវរបស់ខ្លួនមែន ប៉ុន្តែបើយើងសង្កេតយ៉ាងពិនិត្យឲ្យមែនទែន វត្ថុទាំងនេះច្បាស់ជាចេះញញឹមនឹងនិទានប្រាប់យើងហូរហែពីពតិមាងផ្សេង ៗ ក្នុងប្រទេសជាតិនៅសម័យនិមួយ ៗ ដែលវត្ថុទាំងនោះ ...

តាប់កំណើតឡើង ៗ មើចុះដុំថ្មធំ ១ ដ៏មានផ្ទាក់ជារូបផ្សេង ៗ ដំណាង វប្បធម៌បុរាណខ្មែរ បានតម្រៀបគ្នាជាជួរជាសង្កាត់ ចាំទទួលអស់លោកអ្នកជាអ្នកសិក្សា ពោលគឺជាអ្នកដែលត្រូវការទៅសាកសួរដល់ខ្លួន ៗ រូបជាដំណាងព្រាហ្មណសាសនាក្តី , ជាដំណាងព្រះពុទ្ធសាសនាក្តីសុទ្ធតែជាសក្ខីភាព បង្ហាញយើងអំពីលទ្ធិសាសនានៅសម័យនិមួយ ៗ ព្រោះលទ្ធិសាសនានេះហើយ ជាមេ, ជាទីប្រជុំ, ជាដើមហេតុនាំឲ្យកើតបានជាវប្បធម៌នៃជាតិ ដែលបំបែកទៅជាសាខាយ៉ាងច្រើនបែបច្រើនយ៉ាងទៅទៀត ៗ បានជាយើងហ៊ានថាលទ្ធិសាសនាទាំងនេះ ជាមេគំនិតនឹងជាមូលហេតុរបស់វប្បធម៌យើង ព្រោះដោយសារតែលទ្ធិសាសនាទាំងនេះហើយ ទើបខ្មែរមានទេពកោសល្យជាច្រើន ក្នុងរចនារូបចំឡាក់ក្បាច់ក្បូរពណ៌នាពីរឿងរ៉ាវ ឬ រូបបុគ្គលអស្ចារ្យរបស់សាសនាទាំងនោះ ៗ ដោយសារលទ្ធិសារ លទ្ធិសាសនានេះទៀត ដែលបង្កើតគំនិតខ្មែរពីបុរាណទៀត ឲ្យនិយមចង់ក្រងនូវក្បួនខ្នាតផ្សេង ៗ ដែលចារឹកលើក្រាំង ឬ មួយចារឹកលើផែនសិលាដ៏ធំៗ សំរាប់ឲ្យយើងជាន់ក្រោយបានក្រេបរសជាតិអំពីក្បួនខ្នាតនឹងច្បាប់ទំលាប់ទាំងនោះ ៗ បើនិយាយឲ្យខ្លីថា លទ្ធិសាសនានេះហើយ ដែលមានអានុភាពផ្តល់នូវនិន្នាការផ្សេង ៗ ទៅលើស្ថាបន-កម្មគ្រប់បែបរបស់ខ្មែរយើង ៗ ដោយហេតុ យល់ថាលទ្ធិសាសនាពិតជាគោលគំនិតយ៉ាងធំ ឬ ជាជំនួយស្មារតីពេញលក្ខណៈ ក្នុងការដឹកនាំ

សតិបញ្ញានៃជនជាតិឲ្យមានលក្ខគោលត្រឹមត្រូវក្នុងវប្បធម៌ ទើបបណ្ដាជនខ្មែរនិយមគោរពលទ្ធិសាសនាតាំងពីបូរាណវែងឆ្ងាយ រហូតមកដល់សព្វថ្ងៃនេះយ៉ាងខ្ជាប់ខ្ជួនបំផុត ។ បើយើងពោលតាមហេតុភេទរបស់ស្រុកវិញ ក៏យើងឃើញមានប្រយោជន៍សំខាន់មួយទៀត គឺកាលពីសម័យមានសង្គ្រាមដោយជនបរទេសបានចូលមកកុកកនក្នុងប្រទេសយើង បង្កើតឲ្យមានចលាចល ឬប្រើមធ្យោបាយបន្ទាបបន្ថោកវប្បធម៌ឲ្យបាត់ឈ្មោះសោះសូន្យនោះ ក៏មានខ្មែរមិនបាត់បង់ក្បួនខ្នាតតម្រាប់តម្រារបស់ខ្លួនឡើយ ព្រោះមានទីជម្រកយ៉ាងស្កុកស្កម្ភដោយវត្តអារាមនៃសាសនាយើង ។ មិនតែប៉ុណ្ណោះទៀត តាំងពីសម័យអង្គរៀងមកដល់សព្វថ្ងៃនេះ សាលារៀនដែលជាទីអប់រំកុលបុត្រខ្មែរទាំងបំណេះវិជ្ជាទាំងចរិយា ក៏តែងស្ថិតនៅក្នុងវត្តអារាមដែរ ។ វេលានេះយើងពុំបាច់រ៉ាយរ៉ាប់ពីប្រយោជន៍លទ្ធិសាសនាទៅទៀតទេ ដ្បិតលោកអ្នក គង់សង្កេតឃើញនឹងបានពិចារណារួចមកហើយ ។ យើងសុំពោលបន្តទៅទៀតអំពីគុណសម្បត្តិនៃរូបចំឡាក់ដែលបានរ៉ាយរ៉ាប់មកហើយខាងលើ ។

ក្រៅពីការបង្ហាញឲ្យយើងស្គាល់ពីលទ្ធិសាសនា រូបទាំងនេះបានបង្ហាញឲ្យយើងស្គាល់ថែមទៀតខាងទំនៀមទម្លាប់ស្រុក ដែលជាដើមនៃអារ្យធម៌របស់ជាតិនិមួយ ៗ ព្រោះបើមើលសង្កេតចំពោះរូបពង់ការប្រើសំលៀកបំពាក់ ឬរូបខ្ទះទិទានពីពិធីកម្មរបស់អ្នកស្រុកផង នោះយើង

រឹងរឹតតែឃើញច្បាស់ណាស់ទៅទៀត នូវអារ្យធម៌របស់យើង ៗ តទៅទៀត រូបទាំងនេះ នាំឲ្យយើងស្គាល់ពីប្រវត្តិនៃប្រទេសជាតិយើងទៀត គឺយើងតែងបានដឹងថា នៅសម័យណាប្រទេសយើងមានព្រឹត្តិការណ៍ដូចម្តេច ១ ៗ

បើយើងបែរមកមើលខាងសិលាចារឹកវិញ ក៏ឃើញមានច្រើនសន្ធឹកណាស់ដែរ ខ្លះធំខ្លះតូច ខ្លះបាក់បែកអន្តរាយស្ទើរតែអស់ ខ្លះទៀតក៏នៅគង់វង់ល្អមើលបាន ៗ អក្សរដែលចារឹកលើផ្ទាំងសិលានេះ មិនមានភិនភាគដូចគ្នាទាំងអស់ទេ តួព្យញ្ជនៈតែងប្រែប្រួលប្លែក ១ ពីគ្នាខ្លះ ១ ៗ ព្រោះនេះជាការបញ្ជាក់ប្រាប់យើងឲ្យឃើញថា ការកសាងគោលចារឹកទាំងនេះ មិនមែនក្នុងពេលតែមួយទេ ប្រាកដជាបុព្វបុរសយើងស្វះស្វែងកសាងមកអស់រយៈពេលជាច្រើនសតវត្សរ៍ណាស់ ហើយកិច្ចការនេះត្រូវធ្វើដោយព្យាយាមនឹងដោយផ្ចិតផ្ចង់ជាបំផុត ៗ តួអក្សរទាំងនេះទៀតបានចរចាដ៏ហូរហែប្រាប់យើងឲ្យស្គាល់ពីប្រវត្តិដើម របស់ប្រទេសជាតិនៅសម័យដែលកន្លងមកហួសយូរយារណាស់ហើយ ៗ លក្ខណៈសំខាន់ក្នុងសិលាចារឹកទាំងនេះម្យ៉ាងទៀត ត្រង់ផ្នែកអក្សរសាស្ត្រដែលបុព្វបុរសយើងមិនភ្លេចសោះទេ នូវការលើកដំកើងមុខវិជ្ជាផ្នែកនេះ ឲ្យបានត្រកំត្រកាលឡើងតាំងពីដើមមក ៗ លោកបង់គោលពតិមានប្រាប់យើងលោកធ្វៀតសរសេរជាកំណាព្យកាព្យឃ្លោង ប្រកបដោយសំនួនវោហារ

ល្អងល្អាយបញ្ចូលគ្នានោះផង ។ ហេតុនេះហើយ បានជាអ្នកសិក្សាអក្សរសាស្ត្រទាំងអស់គ្នា អាចរកឃើញនូវគោលចារឹកអក្សរសាស្ត្រពិតប្រាកដ ។

ក្រៅពីនេះ យើងឃើញមានឧបករណ៍តូរ្យតន្ត្រីគ្រប់បែបគ្រប់យ៉ាងទៀត គឺវត្ថុទាំងនេះហើយ ដែលនិទានបញ្ជាក់ប្រាប់យើងអំពីសេចក្តីចំរើនលូតលាស់នៃតន្ត្រីខ្មែរតាំងពីព្រេងនាយរហូតមកដល់បច្ចុប្បន្នកាលនេះ ។ ហេតុម្តេចបានជាយើងលើកយករឿងតន្ត្រីមកពោលក្នុងទីនេះដែរ ? យើងឆ្លើយភ្លាមថា តន្ត្រីជាផ្នែកមួយយ៉ាងសំខាន់ណាស់ក្នុងវប្បធម៌ជាតិ ។ មើលចុះ ការផ្ទេរនិងការផ្សាយនៃវប្បធម៌រវាងប្រទេសមួយនិងប្រទេសមួយក្នុងសម័យឥឡូវនេះ គេច្រើនតែលើកយកផ្នែកតន្ត្រីនេះហើយធ្វើជាត្រីមុខ ៗ ព្រោះតន្ត្រីជាគ្រឿងបំពេអារម្មណ៍ផង, ជាគ្រឿងសំគាល់ពីសិល្បៈសូរសំនៀងរបស់ជនជាតិនិមួយ ៗ ផង ។ ដូច្នេះ បានជាសព្វថ្ងៃនេះមានការប្រកួតប្រជែងខាងតន្ត្រីជាញឹកញាប់ រវាងប្រទេសទាំងឡាយក្នុងសាកលលោក ។

បន្ទាប់ទៀត យើងប្រទះឃើញវត្ថុធ្វើអំពីការសូនដីហើយវិចិត្ររចនាជាច្រើនពណ៌ ព្រមទាំងមានលំនាំជាវត្ថុប្រើប្រាស់ផ្សេង ៗ ពីគ្នា ៗ ក្នុងនោះមានក្បាច់ក្បីវល្លិ៍ឥតខ្ចោះលាយលុកជាមួយពណ៌យ៉ាងភ្លឺត្រចះផង ។ ត្រង់នេះ មិនត្រឹមតែបង្ហាញយើងអំពីសិល្បកម្មក្នុងការឆ្លាក់និងការសូនរូប

តាំងនេះទេ គឺជាកស្តុតាងជាក់ស្តែងមួយ ខាងផ្នែកវិទ្យាសាស្ត្រដែលជាមេកជាងយ៉ាងធំក្នុងវប្បធម៌ទំនើប ។ បានជាបែរគេគិតទៅរកវិទ្យាសាស្ត្រវិញ ព្រោះឃើញថា បើសិល្បករខ្មែរធ្វើតែនេះពុំបេះក្បួនខាងគណិតជាក់ប្រាកដទេ ពុំអាចលាយវត្ថុធាតុឲ្យកើតបានជាគ្រឿងរលោង ឬ ជាពណ៌ឆ្អិនឆ្អៅជាប់លាប់យ៉ាងយូរដូចនេះបានទេ ។

សេចក្តីបរិយាយខាងលើនេះ គ្រាន់ជាការពណ៌នាត្រួស ៗ ចំពោះប្រយោជន៍នៃអាគារដ៏វិចិត្រមួយ ដែលយើងហៅថា សារមន្ទីរ បានន័យថា "កន្លែងដែលប្រកបដោយខ្លឹមសារ" ។ ឥឡូវយើងគ្រាន់តែក្រឡេកមើលហើយល្បងពិចារណាបន្តិចមើលក៏ឃើញថា ត្រូវតាមន័យរបស់ពាក្យជាឈ្មោះរបស់អាគារនេះមែន ។ តែប្រើនិយាយឲ្យខ្លីងាយយល់ថា សារមន្ទីរជា ឃ្លាំង ឬជាជង្រុក នៃវប្បធម៌ក៏បាន ។ ដូចនេះ ការទស្សនារបស់កុលបុត្ត-កុលធីតាខ្មែរនៅក្នុងមន្ទីរនេះ ពិតជាការគ្រប់ជញ្ជាក់នូវវប្បធម៌ជាតិខ្លួនយ៉ាងជាក់ច្បាស់ជាមិនខាន ។

---

# ពាក្យខ្មែរប្រែចេញពីបរទេស

## ដោយគណៈកម្មការវប្បធម៌

(តមក)

| | | |
|---|---|---|
| Communion | *n. f.* | អាកន្លមកម្ម |
| Excommunication | *n. f.* | និក្ខន្លទកម្ម |
| Thallophytes | | សត្តភូគាម |
| Algue | *n. f.* | សារាយ |
| Lichen | *n. m.* | ករកាប្យ |
| Muscinées | | សេវាលជាតិ |
| Mousse | *n. f.* | ស្លែ |
| Hépatique | *n. el a.* | យក្រឹត |
| Cryptogames vasculaires | | បដិច្ឆន្នជាតិ |
| Fougère | *n. f.* | បណ្ណង្គជាតិ |
| Licopode | *n. m.* | លីកូបាទ |
| Gymnosperme | *n. m.* | អច្ឆន្នបុប្ផាទជាតិ |
| Angiosperme | *n. m.* | ឆន្នបុប្ផាទជាតិ |
| Conifère | *n. m.* | សរលជាតិ |
| Cotylédon | *n. m.* | ពីជបត្រ |
| Dicotylédone | *n. m.* | ទិពីជបត្រជាតិ |
| Monocotylédone | *n. m.* | ឯកពីជបត្រជាតិ |
| Graminée | *n. f.* | ឃាសជាតិ |
| Bruine | *n. f.* | រលឹមត្រដាក់ |
| Pluie | *n. f* | ភ្លៀង |
| Ondée | *n. f.* | ភ្លៀងរត់ |

(នៅមានត)

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

ព្រះមហា ប៉ាង - ខាត់ រៀបរៀង

( តមក )

អតិប្រវេគ បុំ. កិរិយាចូលក្រៃលែង, កិរិយាចូលលាយឡំក្រៃលែង ។

អតិប្រសំស ធាតុ សរសើរក្រៃលែង ។

អតិប្រគាឡ្ហ គុ. ដែលសាន្តព្រោះក្រៃលែង ។

អតិប្រជ្ញ បុំ. ប្រាជ្ញាក្រៃលែង, ប្រាជ្ញាពិបាក ។

អតិប្រសក្ត គុ. ដែលជាប់គ្នាក្រៃលែង; អតិប្រសក្តិ ស្រី,
កិរិយាជាប់គ្នាក្រៃលែង ។

អតិប្រសង្គ បុំ. កិរិយាជាប់ក្រៃលែង ( កាមារម្មណ៍ ) ការញៀន,
កិរិយាប៉ះទង្គិចក្រៃលែង ។ អតិប្រសង្គិន គុ. ដែលពោទន់
( ទៅរកកាមារម្មណ៍ ) ។

អតិប្រសន្ធ ធាតុ. តម្កើង, លើកតម្កើង ។ អតិប្រសន្ធ គុ. ដែលថ្កុំថ្កើង,
ដែលថ្លៃថ្លា ។

អតិប្រហារ បុំ. ប្រហារក្រៃលែង ។

អតិប្រាក្ឫត គុ. ដែលនៅប្រក្រតីក្រៃលែង ។

អតិប្រាណម៑ ក្រិ. វិ. ដោយប្រាណក្រៃលែង ។

អតិប្រិយ គុ. ប្រិមប្រិយក្រៃលែង ។

(នៅមានត)

# រឿងសាមកុក

## កណ្ឌទី ៤៤

ឧកញ៉ាវិបុលរាជសេនា ង៉ូ-កន ប្រែរៀបរៀង

( តមក )

| |
|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ<br>អ្នកវាងវៃឆ្លាតបើបានអាន<br>នឹងបេះឧបាយកលបំណាន<br>ទាំងមានសន្តានស្នេហាជាតិ ។ |

តាំងពីហោយិន ហោហង ធ្វើឧបាយរត់ចោលស្រុកឡាំកុន ដីវយី ត្រូវព្រួញធ្វើជាស្លាប់ ។ ហោយិនត្រឡប់ចាញ់ទ័ពដីវយី ។ ខុងបេង ផ្តើមយកស្រុកឡាំកុនបាន, ទៀតពី វាយយកស្រុកឡេងឡេងបាន ហើយឲ្យជូឡុងទៅវាយយកស្រុកហ៊ុយអៀងបានទៀត ។

---

បើឃើញដីវយីលើកទាហានចូលមក ក៏ឲ្យបង្ហាំងកំផែងក្លាម ។ បើឮសំឡេងផាវវេលាណា ត្រូវឲ្យទាហានធ្នូបាញ់ព្រួញគ្នាប្រមះចូលទៅឲ្យមាំមួន លុះបង្គាប់ធ្វើស្រេចហើយ ហោយិន, ហោហងក៏នាំទាហានដែលស្ពាយស្បៀងនោះ ធ្វើជារត់ចេញចោលស្រុកទៅ ។

ឯដីវយីក៏ឡើងមើលលើសើនបន្ទាយ មិនបានឃើញទាហាននៅក្រុងបន្ទាយក្នុងស្រុក ឃើញតែហោយិន ហោហងនាំទាហានស្ពាយរែកស្បៀងអាហារចេញពីស្រុកទៅប្រពាក់ប្រពូនក៏នឹកថា ហោយិន ហោហង

រត់ចោលស្រុកហើយ ជីវយីក៏ចុះពីលើសើនបន្ទាយ ហើយបង្គាប់ទាហាន
កងមុខឲ្យចូលច្បាំងនឹងចោយិន, ចោហង ឲ្យប៉ែកឆ្វេង-ស្តាំ ចូលប្រសព្វ
គ្នាច្បាំងជាជ្រួលច្របល់ ឯខ្លួនយើងនឹងលើកទាហានជាទ័ពជំនួយទៅជួយ
បើកងមុខឮសំឡេងឃ្មោះហើយ ឲ្យបង្ខំស្រួតបំពារចូលទៅ ៗ ឯទាហាន
កងមុខនឹងប៉ែកឆ្វេង-ស្តាំ ក៏លើកចូលទៅប្រយុទ្ធគ្នានឹងចោយិនចោហង
ជាច្រឡំបល់ ៗ ជីវយីក៏ឲ្យជីវថាយ បរសេះចេញទៅច្បាំងនឹងចោយិនបាន
១០ កួន មិនចាញ់មិនឈ្នះ ជីវយីក៏ប្រើហ័នគុងឲ្យជិះសេះចូលទៅតនឹង
ចោហងបាន ៣០ កួន ៗ ចោយិនចោហងធ្វើជាថយរត់ទៅទិសខាងជើង
មិនបានចូលស្រុកឡាំកុន ៗ ជីវថាយ ហ័នគុងឃើញដូច្នោះក៏បរសេះ
ដេញតាមទៅ ៗ ជីវយីក៏ដេញទាហានជំនួយទៅផុតជើងកំពែងស្រុក
ឃើញទ្វារបើកចំហ ក្រឡេកមើលទៅ មិនឃើញមានមនុស្សម្នានៅក្នុង
បន្ទាយនោះសោះ ជីវយីក៏នាំទាហានប្រហែល ៥០ នាក់ ចូលទៅតាមទ្វារ
ដល់ក្នុងស្រុក ៗ

ឯគ័នកៀវក៏និយាយថា គំនិតដែលរិះគិតរបស់មហាឧបរាជឲ្យសំបុត្រ
នោះល្អណាស់ ឧបមាដូចទេពតាមកបញ្ចូលចិត្ត ទទួលព្រួសម្ទេងផាវ
ក៏ឲ្យទាហានបាញ់ធ្នូចម្រុះចូលទៅជាច្រើន, ឯគ័នកៀវក៏បាញ់តម្រង់ទៅ
ត្រូវជើងឆ្វេងជីវយីធ្លាក់ពីលើសេះ ៗ នឹងឃើមឃើញដូច្នោះ ក៏លើកទាហាន
ចូលទៅនឹងចាប់យកជីវយី ៗ ទទួលឈឺសេង, គេងហងចូលមកទាន់

ក៏ជួយគ្នាការពារជីវយីបាន ហើយគ្រាហ៍ឡើងសេះថយចេញមកពីស្រុក ៗ
ឯតន់កៀវក៏បរពលចូលច្បាំង ៗ ពួកទាហានជីវយីក៏រត់ទៅធ្លាក់អន្លង់ជា
ច្រើន ៗ តន់កៀវក៏ចាប់បានសម្លាប់ខ្លះចេញ ៗ ឈីសេង, តេងហង
ខំការពារជីវយីនាំចេញទៅក្រៅបាន ៗ ទៀកៅ ឃើញជីវយីថយមក
ក៏វាយឃ្មោះជាសញ្ញា ប្រាថ្នានឹងហៅទាហានឲ្យថយមកកល់គ្នា ៗ ឯ
ជីវយីនឹងហ័នតុង លុះឮសម្លេងឃ្មោះក៏នាំទាហានថយមកតាមសញ្ញា ៗ

ចោយិន, ចោហងឃើញដូច្នោះ ក៏លើកទាហានញែកគ្នាជាពីរកង
តាមវាយដូចប្រសព្វចូលទៅ ៗ ជីវយីនឹងទាហានក៏ថយចូលទៅក្នុងបន្ទាយ
វិញ ៗ ជីវយីក៏កន្ត្រាក់ដកព្រួញចេញបាន ហើយឲ្យពេទ្យថែរក្សាបួស
តែនៅឈឺចាប់ក្នុងបួសនោះម្ដង ១ ៗ ពេទ្យក៏និយាយថា ព្រួញនេះដាក់
ថ្នាំពិស សុំឲ្យលោករម្ងាប់កំហឹងក្នុងខ្លួនកុំឲ្យមាន បើកាលណាមានកំហឹង
ហើយ ពិសថ្នាំក៏នឹងកំរើកឡើងវិញ ៗ ទៀកៅ ក៏បង្គាប់ទាហានទាំងពួង
ឲ្យត្រួតត្រារក្សាបន្ទាយឲ្យមាំមួន កុំឲ្យទីប្រឹក្សានឹងទាហានទាំងពួងយកការ
អ្វីចូលទៅនិយាយនឹងជីវយីឲ្យសោះ បើឮពីការអ្វី ក៏ឲ្យនាយទ័ព
នាយកងជួយគ្នារិះគិតការឲ្យបានសម្រេច កុំឲ្យអន្តរាយទំរាំតែបួសជីវយី
នោះសះជា ៗ

ឯចោយិន, ចោហង ក៏ឲ្យងីវឃឹមលើកទាហានទៅស្រែកជេរជីវយី
នៅមុខបន្ទាយ ជាពាក្យអសុរោះគ្រប់ ៣ ថ្ងៃ ៗ ទៀកៅ ក៏ហាមប្រាម

ទាហានទាំងពួងមិនឲ្យចេញច្បាំង ហើយប្រឹក្សានឹងនាយទ័ពនាយកងថា គ្រានេះ ជីវយីឈឺត្រូវតែយើងរិះគិតឧបាយ ឲ្យជីវយីលើកកងទ័ពត្រឡប់ទៅវិញ ដើម្បីនឹងឲ្យស៊ុនគួនជ្រាបកិច្ចការ រួចសឹមលើកកងទ័ពមកធ្វើសង្គ្រាមវិញ នាយទ័ពនាយកងទាំងពួងក៏នៅស្ងៀម មិនថាប្រការម្ដេច ។

ខណៈនោះ ជីវយីបានឮសម្លេងទាហានតោយ៉ិនមកស្រែកជេរដៀមដាម ជីវយីខំអត់សង្កត់ចិត្តកុំឲ្យកំហឹងកើតឡើងបាន ព្រោះខ្លាចពិសថ្នាំកំរើកឡើងវិញ ។ ថ្ងៃមួយតមក តោយ៉ិនក៏លើកទាហានទៅដល់មុខបន្ទាយជីវយី ហើយឲ្យពួកកងស្គរស្រែកហ៊ោកញ្ច្រៀវអឺងកង ដើម្បីផ្ដើនចំអកជីវយី ។ ជីវយីឮហើយ ក៏បណ្ដាលចិត្តគិតចង់ដឹង ទើបសួរពួកមនុស្សដែលនៅបំរើថា សម្លេងអ្វីឮសន្ធឹកសន្ធាប់នោះ? ។ ពួកអ្នកបំរើឆ្លើយថា ទាហានកងទ័ពយើងកំពុងហ្វឹកហាត់ គ្រឿងសាស្ត្រាវុធ ។ ជីវយីឮដូច្នោះខឹងណាស់ ទើបថាសម្លេងនេះ គឺទាហានតោយ៉ិនមកស្រែកជេរដៀមដាមច្រើនថ្ងៃហើយ, យើងក៏ដឹងដែរ ទើបឲ្យហៅទៀកៅមក ហើយនិយាយថា ខ្លួនយើងជាមេទ័ពដេកឈឺ គួរឬ? ខ្លួនអ្នកជាបាឡាក់ទ័ពនៅស្ងៀមព្រងើយ មិនដឹងជាតោយ៉ិនវាប្រើទាហានមកស្រែកជេរដៀមដាម ៣-៤ ថ្ងៃហើយ ហេតុអ្វីក៏មិនប្រាប់យើងឲ្យដឹងផង ។ ទៀកៅឆ្លើយថា បានជាខ្ញុំបាទមិនជំរាបលោកឲ្យជ្រាបនោះ ព្រោះតែក្រែងលោកជ្រាបទៅហើយ នឹងបណ្ដាលឲ្យមានចិត្តខឹងឡើង របួសព្រួញដែលមានក្នុងខ្លួន

លោកនឹងកំរើកពិសឡើងវិញ ។ ជីវយីថា បើអ្នកនៅស្ងៀមមិនចេញច្បាំងដូច្នេះ តើគិតដូចម្ដេចទៅវិញ ? ។ ទៀកៅថា ខ្ញុំបាទនឹងទាហានទាំងពួងប្រឹក្សាគ្នាទៅឃើញថា ខ្លួនលោកនៅឈឺដូច្នេះ ខ្ញុំបាទចង់អញ្ជើញលោកលើកទ័ពត្រឡប់ទៅស្រុកកាំងតាំងស៊ិន បើលោកគ្រាន់បើថ្ងៃណាសឹមលើកទ័ពមកធ្វើសង្គ្រាមនឹងហោយិនវិញ ។ ជីវយីឮដូច្នោះ ស្ទុះក្រោកឈរឡើងហើយថា ខ្លួនយើងនឹងអស់អ្នកពល់គ្នា សុទ្ធតែជាទាហានស៊ីបៀវត្សរ៍ ត្រូវតែគិតតបស្នងសងគុណចៅហ្វាយនាយ បានជាខំមកធ្វើការប្ដូរសេះប្ដូរស្លាប់ ទោះបីក្ស័យជីវិតក្នុងសង្គ្រាម គឺឲ្យគេយកអានសេះបិទបាំងសាកសពទៅចុះ ដែលនឹងកថយដោយញញើតខ្លាចនោះមិនគួរសោះឡើយ ត្រូវតែខំស្រូតទៅខាងមុខ ហេតុអ្វីអស់អ្នកពល់គ្នាសុទ្ធតែជានាយកងនាយទ័ព នាំគ្នាមកកើតទុក្ខធុញថប់ដល់យើងដែលឈឺប៉ុណ្ណេះ ហើយមិនគិតលើកកងទ័ពចេញទៅច្បាំងនឹងសត្រូវ ថាហើយជីវយីតែងខ្លួនពាក់គ្រោះកាន់លំពែងឡើងសេះ ។ ទាហានទាំងពួងឃើញដូច្នោះ នាំគ្នាតាមជីវយីចេញទៅដល់ទ្វារបន្ទាយ ។

ឯហោយិនក៏ប្រើទាហានចេញទៅស្រែកដេរថា អាជីវយីនោះ អាយុវានៅក្មេងនៅឡើយ តែចិត្តគំនិតវាក្លើតក្លើនខ្លាំងណាស់ ជីវិតវានឹងស្លាប់ក្នុងកណ្ដាលសង្គ្រាមឥឡូវហើយ ។ ជីវយីឮដូច្នោះ ក៏បរសេះចេញទៅក្រៅបន្ទាយហើយស្រែកថា ខ្លួនអញនេះ ទោះបីអាហោយិននឹងចេញមក

គស្វិប្រទល់ខ្លួនក៏អញមិនខ្លាចដែរ អាឯងកល់គ្នាកុំមកដេរប្រមាថអញឡើយ ។ និយាយរួចក៏ប្រើក្បូរដៀង ឲ្យបរសេះចេញទៅច្បាំងនឹងចោយិន ហើយបន្ទុំដេញទាហានជាជំនួយតាមទៅ, លុះនិយាយអស់ពាក្យកាលណា ថ្មាំពិសក៏កំរើកឡើងក្នុតឈាមធ្លាក់មកពីលើខ្នងសេះ ។ ចោយិនឃើញដូច្នោះ ក៏លើកទាហានចូលទៅប្រយុទ្ធគ្នា, ពួកទាហានដីវឃើក៏ពារប្រទល់គទៅវិញ ហើយគ្រាហ៍យកដីវឃើ ចូលទៅក្នុងបន្ទាយ ខ្លះរត់រត ខ្លះគក់ប្រហាច់។ ដីវឃើក៏ក្លាក់ស្មារតីដឹងខ្លួនឡើងវិញ ។ ឯចោយិនបានលើកទ័ពចូលស្រុក ។

ទៀកៅសួរដីវឃើថា បើលោកកំពុងឈឺដូច្នេះ តើគិតជាយ៉ាងម្តេចទៅទៀត ។ ដីវឃើក៏ទទួលប្រាប់ថា អ្នកកុំព្រួយឡើយ យើងគិតការឃើញស្រួលហើយ ហើយប្រាប់ទៀកៅថា យើងត្រូវប្រើទាហាននឹងមនុស្សទំនុកទុកចិត្តចេញទៅនិយាយថា យើងដល់នូវសេចក្តីស្លាប់ទៅហើយ ដែលនឹងនាំគ្នានៅជាមួយនាយទ័ពនាយកងនោះមិនស្រួលគិតនាំគ្នាទៅចូលខាងចោយិន ។ ក៏នឹងមានចិត្តក្អែតក្អេងលើកទ័ពមកវាយបន្ទាយយើងជាប្រាកដ រួចយើងត្រូវដោះខ្លួនចេញពីបន្ទាយឲ្យអស់នាំទាហានយើងនៅបង្កប់ទុកជា ៤ កង ហើយឲ្យវាយខ្ទប់គ្រឡប់មកវិញនឹងចាប់យកខ្លួនចោយិនបានដោយងាយ ។ ទៀកៅស្តាប់ហើយក៏យល់ត្រូវផង ដីវឃើក៏ប្រើទាហានទាំងពួងឲ្យដើរចេញទៅស្រែកយំថា ដីវឃើស្លាប់ទៅហើយ

ឲ្យយកទង់សជោតនៅមុខបន្ទាយ ទាហានទាំងឡាយក៏ឲ្យស្លៀកសពាក់សទាំងអស់ ហើយបង្គាប់ទាហានឲ្យធ្វើការតាមគំនិតដែលគិតនោះ ។

ឯចៅយិនក៏ប្រឹក្សានឹងទាហានទាំងពួងថា យើងឲ្យទៅស្រែកជេរជីវយីជាពាក្យអសុរោះមើលងាយ ជីវយីខឹងចេញមកតច្បាំង ក៏ធ្វើអ្វីយើងមិនបាន ឈឺចិត្តណាស់ទាល់តែក្អួតធ្លាក់ឈាមចេញមក យើងយល់ថាជីវិតជីវយីក្នុងគ្រានេះ មុខជាស្លាប់ពិតប្រាកដណាស់ ។ ទទួលទាហានចូលមកប្រាប់ថា ឥឡូវទាហានជីវយី១២នាក់ចូលមករកលោក ។ ចៅយិនក៏ឲ្យហៅចូលមកហើយសួរថា អ្នកឯងកល់គ្នាចូលមកនេះមានធុរៈអ្វី ? ។ ទាហានទាំង ១២ នាក់ក៏ឆ្លើយព្រមគ្នាថា ទាហាន ១០ នាក់ជារបស់ជីវយីឯទាហាន ២ នាក់ជាទាហានចួច្ច ដែលជីវយីចាប់បានមក កាលជីវយីចេញមកច្បាំងនឹងលោកនោះ ជីវយី ក៏ក្អួតធ្លាក់ឈាមចេញមក ហើយត្រឡប់ចូលទៅក្នុងបន្ទាយវិញបានមួយស្របក់ក៏ដាច់ខ្យល់ស្លាប់ ឥឡូវទៀតៅជាមេទ័ពបង្គាប់បញ្ជាពុំត្រឹមត្រូវ ធ្វើតែតាមអំពើចិត្ត យើងខ្ញុំទាំងអស់ទ្រាំមិនបាន ទើបនាំគ្នារត់មកប្រាថ្នានឹងជ្រកកោននៅនឹងលោកតទៅ ។

ចៅយិនឮដូច្នោះ ក៏ពិនិត្យមើលទាហានទាំង១២នាក់នោះ ក៏ចាំបានថាជាទាហានចួច្ច ទើបប្រឹក្សានឹងទាហានទាំងពួងថា ឥឡូវជីវយី ស្លាប់ហើយ យប់នេះយើងត្រូវលើកទាហានទៅលុកបន្ទាយទៀតៅ ដណ្តើម

យកសពដីវយើឲ្យបាន ដើម្បីកាត់យកក្បាលបញ្ជូនទៅឲ្យចូចូឯស្រុកក្រុង ៗ ទាហានទាំងពួងក៏យល់ឃើញត្រូវផង ៗ ហោយ៉ិន ក៏ប្រើគ័នគៀវ ឲ្យនៅរក្សាបន្ទាយស្រុក, ឲ្យងីវយ៉ឹម លើកទាហានចេញទៅជាទ័ពស្រួច, ឲ្យហោយ៉ិនលើកទ័ពជាកងហ្លួង, ឲ្យហោហងនឹងហោស៊ុន លើកទាហានជាកងក្រោយ ៗ លុះពេលយប់ប្រហែលជាយាមមួយប្លាយ ក៏លើកទ័ពចេញទៅដល់មុខបន្ទាយទៀកៅ មិនឃើញមានមនុស្សនៅក្នុងបន្ទាយសោះ ៗ ហោយ៉ិន ក៏គិតពិកល់ក្នុងចិត្តថា ប្រហែលជាដីវយើ ធ្វើកលឧបាយទេដឹង គិតហើយក៏ឲ្យលើកទ័ពចេញមកវិញនឹងចូលទៅក្នុងស្រុក, ទទួលឮស្គរផាវនឹងមាត់ទាហានស្រែកហោហ៊ុះចេញមកពីទិសទាំង ៤ ហើយឃើញទិសខាងកើតនោះ ហ័នតុងនឹងដីវយ៉ឹមលើកទាហានចូលមកទិសខាងលិចឃើញក្លូជៀង នឹងដីវថាយវ៉ាខ្លួបចូលមកទៀត ឃើញឈីសេងនឹងគេង-ហង លើកទាហានចេញមកពីទិសខាងត្បូង ឃើញគ័នប៊ូនឹងលីបង លើកទាហានចេញមកពីទិសខាងជើង ប្រជុំគ្នាជុំវិញជាប្រឡំបល់, កងទ័ពដីវយើ ក៏ព្រួតគ្នាកាប់សម្លាប់ទាហានហោយ៉ិន ស្លាប់ច្រើនណាស់ ៗ ហោ-យ៉ិន នឹងទាហានទាំងពួងតទល់ពុំបាន ក៏នាំគ្នាបាក់រត់ចេញទៅជា ៣ ផ្លូវ ហោយ៉ិន សល់តែទាហាន ២០ នាក់ ៗ លុះដល់យាម ៣ ប្លាយ ទទួលប្រទះគ្នានឹងទ័ពហោហង គិតគ្នាថានឹងចូលទៅក្នុងស្រុក, ឃើញឡេងថងលើកទាហានមកស្កាត់នៅពីមុខ ហោយ៉ិន ក៏នាំហោហងរត់ទៅដល់មាត់ផ្លូវ

ប្រទះនឹងកាំភ្លើង ស្ទាក់នៅពីមុខទៀត ដោយមិននឹងដោហាន បញ្ជាំងគ្នា នឹងកាំភ្លើងជាពន្លឹក ទប់កម្លាំងទ័ពរបស់កាំភ្លើងមិនបាន ក៏នាំទាហាន ប្រហែល ២០ នាក់ រត់តម្រង់ទៅស្រុកសុងយ៉ុង ។ លុះពេលព្រឹកឡើង នាយទាហានទាំងពួងក៏នាំគ្នាទៅរកដីវយី ។ ក៏នាំទាហានទាំងអស់ចូលទៅ ស្រុកឡាំកុន ។

កាលដែលដីវយីលើកកងទ័ពទៅវាយយកស្រុកឡាំកុននោះ ឡេវពី នឹងខុងបេង ក៏នាំគួនអ៊ូ ទៀវហ៊ុយ ជូឡុងនឹងឡេវគី នូវទាហានទាំងពួង លើកទ័ពតាមដីវយី ទៅបង្កប់នៅកណ្ដាលផ្លូវ ។ ខុងបេង ក៏ឲ្យបំរើសេះ ទៅលបចាំមើលហេតុការណ៍ ដែលដីវយីនឹងដោយមិនបញ្ជាំងគ្នា ។ បំរើសេះ ក៏ត្រឡប់មកប្រាប់ខុងបេងថា ឥឡូវ ដីវយីស្លាប់ទៅហើយ ។ ខុងបេង ឮដូច្នោះក៏ដឹងថា គំនិតដីវយីក្លែងកលឧបាយ ទើបនាំឡេវពីនឹងសេនា ទាហានកាត់ផ្លូវទៅបង្កប់ក្បែរស្រុកឡាំកុន មិនឲ្យដីវយីដឹងសោះ ។ លុះដោយមិន លើកទ័ពទៅប្លន់យកបន្ទាយដីវយី, ខុងបេងក៏ឲ្យទាហាន ស្រែកប្រាប់ទៅអស់ពួកអ្នកស្រុកថា ឥឡូវទ័ពដោយមិនបែកមកហើយ ឲ្យ ប្រញាប់បើកទ្វារទទួល ។ តាំនកៀវគិតថាប្រាកដមែន ក៏ឲ្យទាហានបើក ទ្វារទទួល ។ ឡេវពីនឹងខុងបេងក៏ចូលទៅព្រមទាំងសេនាទាហានទាំងពួង ហើយឲ្យជូឡុងនឹងទាហានទាំងពួង ឡើងរក្សាទាទីសើនបន្ទាយជាមាំមួន ជុំវិញ ។

ឯជូឡុង កាលបើឃើញជីវយីលើកទាហានចូលមកដល់ជើងកំពែងបន្ទាយស្រុក ក៏ស្រែកប្រាប់ទៅថា ខ្ញុំបាទសូមអភ័យទោសនឹងជីវយីចុះ ដ្បិតខុងបេងប្រើខ្ញុំបាទលើកទាហានមកវាយយកស្រុកឡាំកុន បានមុនទៅហើយ ជីវយីឮដូច្នោះក៏ខឹងណាស់ ប្រើទាហានទៅតបាំងវាយទំលាយទ្វារនឹងកំពែង ជូឡុងឃើញដូច្នោះ ក៏ឲ្យទាហានបោលដុំថ្មបាញ់ធ្នូចម្រុះទៅជាខ្លាំងណាស់ ជីវយីឃើញថា ទាហាននឹងចូលដណ្ដើមយកកំពែងមិនបាន ក៏ថយទាហានត្រឡប់ទៅបន្ទាយវិញ ហើយប្រឹក្សានឹងទាហានទាំងពួងថា ឥឡូវខុងបេង នាំឡៅពីទៅដណ្ដើមស្រុកឡាំកុនបានហើយ ឯស្រុកកេងជីវនឹងស្រុកស៊ុងយ៉ុងនោះ បើនឹងបង្អង់ទុកឲ្យយូរមិនលើកទ័ពទៅវាយយកឲ្យបានមុនទេ មុខជាខុងបេងនឹងលើកទាហានទៅវាយដណ្ដើមយកទៀត តទៅមុខយើងក៏គង់នឹងបានសេចក្ដីទញ់ទាល់ចង្អៀតនឹងធ្វើការ ទីប្រឹក្សាទាំងពួងយល់ឃើញត្រូវផង ជីវយីក៏ប្រើកាំឡេងឲ្យលើកទាហាន ៣ ពាន់ទៅវាយយកស្រុកកេងជីវ ឲ្យឡេងថងលើកទាហាន ៣ ពាន់ ទៅវាយយកស្រុកស៊ុងយ៉ុង ។

កាលដែលជីវយីចាត់ប្រើកាំឡេង, ឡេងថងនោះ ទទួលបំរើសេះមកប្រាប់ជីវយីថា ឥឡូវខុងបេងឲ្យទាហានបន្លំជាទាហានបោយមិនកាន់ត្រានឹងទន់សម្រាប់ហៅទាហានក្នុងស្រុកកេងជីវ អ្នករក្សាស្រុកមិនបានដឹងកលឧបាយ ក៏ចាត់ទាហានបញ្ជូនទៅឲ្យហើយ ទៀវហ៊ុយលើកទៅវាយ

យកស្រុកគេដដែរ ឯស្រុកសុងយ៉ុង ក៏ខុងបេងឲ្យទាហានបន្ទំទៅនិយាយដូចគ្នា ទាល់តែហែហួទុនលើកទាហានមកឲ្យស្រុកសុងយ៉ុងនោះ គឺគួនអ៊ូលើកទ័ពទៅវាយ ជីវយីឮដូច្នោះក៏ភ័យស្លុតស្មារតីនិយាយថា ចុះខុងបេងបានគ្រាប់ផ្ទង់ជ័យពីណាមក ទៀតសោតថា កាលវាយបានស្រុកឡាំកុននោះ តនគៀវក៏នៅក្នុងកណ្ដាប់ដៃគេ ខុងបេងក៏ហៅយកគ្រាប់ផ្ទង់ប្រើឲ្យគួនអ៊ូ នឹងទៀវហ៊ុយទៅធ្វើការយ៉ាងនេះ ជីវយីឮដូច្នោះ ក៏រឹតតែតូចចិត្តទោមនស្សទ្រាំងខ្លាំងណាស់ ស្រែកដោយសំឡេងយ៉ាងខ្លាំងថា ខ្លួនអញជាជាតិទាហានបានមកធ្វើការដល់ប៉ុណ្ណោះហើយ មិនគួរខុងបេងមកដណ្ដើមយកស្រុកទាំង ៣ អន្ទើនេះសោះ អញត្រូវតែគិតសម្លាប់ខុងបេងចេញឲ្យបាន ហើយនឹងដណ្ដើមយកស្រុកទាំង ៣ ទៅឡើងស្ដាប់បង្គាប់ស្រុកកាំងតាំងឲ្យបានវិញ ឯពិសថ្នាំនោះក៏បណ្ដាលកំរើកឡើង ជីវយីក៏ដួលសន្លប់ចុះ មនុស្សក្នុងទីនោះក៏នាំគ្នាកែខៃឲ្យដឹងខ្លួនឡើងវិញ ជីវយីក៏ឲ្យទៅហៅឡោសុកចូលមកប្រឹក្សាថា ឥឡូវខុងបេងគិតការត្បុតដណ្ដើមយកស្រុកបានដល់ ៣ ដំបន់ហើយ យើងត្រូវតែលើកកងទ័ពទៅកំចាត់ឡើតពី, ខុងបេងចេញឲ្យបាន អ្នកនឹងយល់ឃើញប្រការម្ដេច ? ។

ឡោសុកថា ដែលចូច្នបែកទ័ពទៅគ្រានេះ មិនមែននឹងស្ងៀមព្រមបាញ់តែម្ដងទេ មុខជានឹងរិះគិតសងសឹកវិញជាប្រាកដ ឯស៊ុនគួនទៅហាយយើងឥឡូវនេះ ក៏លើកទ័ពទៅវាយយកស្រុកហាំបប៉ា យើង

ក៏មិនទាន់បានដឹងដំណឹងយ៉ាងណានៅឡើយ វេលានោះឡៅពីនឹងយើង គឺធ្វើដូចជាពួកក្រុមជាមួយគ្នា ដែលលោកនឹងលើកកងទ័ពទៅវាយកំចាត់ឡៅពី, ខុងបេងចេញនោះ ខាងចក្រែងបួនដឹងទៅនឹងលើកទ័ពមកវាយយកស្រុកកាំងគាំងវិញ យើងក៏នឹងបានសេចក្ដីព្រួយការជា ២ ចំណែកប្រការ ១ ទៀត ឡៅពីក៏ជាមនុស្សធ្លាប់ស្គាល់រាប់អានគ្នាមកពីដើម ខាងឡៅពីនឹងនាំយកស្រុកទាំង ៣ ដំបន់នេះ ទៅប្រគល់ឲ្យបួន ហើយខ្លួនឡៅពី, ខុងបេង ក៏នឹងចូលគំនិតគិតទៅធ្វើការសង្គ្រាមនឹងបួនវិញ ស្រុកកាំងគាំងក៏នឹងអន្ដរាយជាប្រាកដ ។

ជីវយីគបថា ដែលយើងធ្វើការសង្គ្រាមនឹងបួនគ្រានេះ យើងក៏បានខូចខាតសោហ៊ុយ ចំណាយជាមាសប្រាក់ស្បៀងអាហារ នឹងឲ្យបំណាច់រង្វាន់ទាហានជាច្រើន ហើយក៏បានលើកមកធ្វើការគេប្រាំងនឹងពោយ៉ិនដល់ស្រុកឡាំកុនទៀត ឯឡៅពីនឹងខុងបេងមិនបានខូចខាតរបស់ទ្រព្យសព្វសារពើអ្វីឬទាហានដល់ម្នាក់សោះ មកជាំតែលានដៃទទួលយកស្រុកទាំងបីដំបន់នោះដោយងាយ មុខគួរឲ្យយើងមានសេចក្ដីខឹងខ្ញាំងណាស់ឡោស៊ុកថា លោកមានសេចក្ដីខឹងនេះក៏គួរហើយ តែសុំបង្គំឲ្យខ្ញុំទៅនិយាយនឹងឡៅពី ខុងបេងដោយល្អសិន បើឡៅពីខុងបេងរឹងទទឹងប្រការម្ដេច សឹមរិះគិតគទៅទៀត ។

( នៅមានត )

# តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

## រឿងព្រេងទាក់ទងដោយការស្ថាបនាប្រាសាទអង្គរវត្ត

### លោក ញ៉ែម-ខឹម រៀបរៀង

(តនិងចប់)

នាងទិព្វសុតាចន្ទក៏ហុចក្រមាទៅឲ្យព្រះពិស្ណុការផ្លាស់ រួចនាងលើកពបុត្រឡើង ហោះកាត់អាកាស ៗ នាងយកបុត្រទៅឲ្យមុជទឹកក្រអូប, នាំចូលក្នុងលំនៅនាង, នាងយកសំលៀកបំពាក់ស្អាត ៗ មកស្លៀកពាក់ឲ្យ, យកម្ហូបសួគ៌មកឲ្យបុត្រញុំា រួចនាំចូលទៅក្នុងមហាប្រាសាទព្រះឥន្ទ្រ ៗ ព្រះវិស្ណុការក៏កើតសេចក្ដីសប្បាយអស្ចារ្យណាស់, ប៉ុន្តែ លុះដល់កុមារចូលទៅក្នុងបន្ទប់សម្រាប់ចូលជួបនឹងព្រះឥន្ទ្រ, អ្នកក៏មានសេចក្ដីចាប់អារម្មណ៍ជាក្រៃលែងចំពោះលំអនៃបន្ទប់នោះ ជាហេតុនាំឲ្យកុមារទៅជាញ័រដៃជើង ( ចាញ់បុណ្យ ) ហើយដួលសន្លប់នៅទីនោះ ៗ នៅខណៈដែលព្រះឥន្ទ្រាធិរាជយាងចេញមកតាមនោះ ទ្រង់ទតឃើញកុមារ ទ្រង់សួរទៅនាងទិព្វសុតាចន្ទថា: "តើមនុស្សនេះជានរណា បានជាឯងនាំមកដល់ក្នុងប្រាសាទយើង?"

– ជាបុត្រខ្ញុំម្ចាស់ កាលដែលខ្ញុំម្ចាស់បានចុះទៅនៅឯស្ថានមនុស្សលោក រៀបការជាមួយនឹងលោកតាលឹម-សេង (នាងទិព្វសុតាចន្ទទូល)ៗ

– នែកុមារដ៏ប្រសើរ ចូរឯងក្រោកឡើង (ព្រះឥន្ទ្រមានព្រះបន្ទូល)ៗ

ព្រះពិស្ណុការក៏បានដឹងស្មារតីឡើង, ទន្ទលុតជង្គង់នៅចំពោះព្រះភក្ត្រនៃស្ដេចទេវតា ។ ព្រះឥន្ទ្រក៏នាំកុមារចូលទៅក្នុងបន្ទប់ប្រាសាទព្រះអង្គ, ហើយទ្រង់ត្រាស់សួរកុមារជាច្រើនបញ្ហា អំពីស្ថានមនុស្សលោកដែលកុមារបាននៅ ។ ចម្លើយនៃព្រះពិស្ណុការ បានធ្វើឲ្យព្រះអង្គសព្វព្រះទ័យពន់ពេក ។ នៅពេលនោះ នាគទិព្វសុគាចន្ទ បានទូលព្រះឥន្ទ្របន្ថែមថា : បុត្រខ្ញុំម្ចាស់មានការប៉ិនប្រសប់ណាស់ គឺចេះគូរ, ចេះឆ្លាក់, ចេះសង់ប្រាសាទ, សង់បន្ទាយយ៉ាងល្អៗ នាំឲ្យមនុស្សលោកមានសេចក្ដីកោតសរសើរស្ញប់ស្ញែងជាក្រៃលែង ។ ប៉ុន្តែ, ទាល់តែកូនខ្ញុំម្ចាស់ចេះចំណេះទាំងនេះដោយឥតបានរៀនពីគ្រូណាសោះ គឺវាចេះដោយសារគំនិតវាតែម្ដង ។ ព្រះឥន្ទ្រឆ្លើយថា: " មែនហើយ, មនុស្សណាដែលចេះវិជ្ជាអ្វីឥតគ្រូ លោកប្រដូចទៅនឹងមនុស្សឆ្កួត ។ បើដូច្នេះ ចូរឯងនាំកុមារទៅជួបនឹងទេវបុត្រ ដែលជានាយកេងជាងយើង, គេនឹងបង្រៀនកុមារឲ្យចេះមុខវិជ្ជាផ្សេងៗ សិន រួចសឹមឲ្យកុមារ ត្រឡប់ចុះទៅស្ថានមនុស្សលោកវិញ, ព្រោះកុមារមានសញ្ញាតិជាមនុស្សលោក ពុំអាចមករស់នៅក្នុងទីនេះរហូតបានទេ " ។

ព្រះពិស្ណុការក៏ទៅនៅជាមួយនឹងពួកទេវបុត្រ ដែលជាអ្នកបច្ចេកទេសខាងវិជ្ជាសិល្បៈនឹងខាងសំណង់ ។ យុវជននោះខំរៀនគូរ, រៀនឆ្លាក់, រៀនលេងភ្លេងពីសំណាក់ទេវបុត្រជាគ្រូទាំងនោះ បានចេះទាំ

ស្ទាត់សព្វគ្រប់ទាំងអស់ គឺចេះសង់ទាក់អាចបើកបរលើគោកបាន, ចេះធ្វាក់ប្រាក់, ធ្វាក់មាស, ចេះស្លូដែកគ្រប់យ៉ាង ចេះវិជ្ជាលាយទឹក ហើយទឹកនោះ បើកាលណាគេចាក់ពយលើដីឥដ្ឋ ដីនេះនឹងក្លាយទៅជាថ្ម ។ សរុបសេចក្តីទៅ គឺកុមារបានចេះចាំទាំងអស់ នូវមុខវិជ្ជាទាំងឡាយណា ដែលទេវបុត្របានបង្រៀន ហើយទេវបុត្របាននិយាយលើកទឹកចិត្តកុមារដូច្នេះទៀតផងថា: " កិច្ចការដែលឯងបានចេះធ្វើទាំងប៉ុន្មាននេះ អាចគង់ស្ថិតថេរ នៅបានអស់ពេលជាច្រើនពាន់ឆ្នាំ ។ ចំណែកឯការងាររបស់ខ្ញុំវិញ អាចមានជីវិតតែត្រឹមមួយរដូវកាលស្តេចមួយព្រះអង្គ ។ ប៉ុណ្ណោះទេ, ឧបមាថា បើមហាក្សត្រអង្គណាមួយបានឡើងសោយរាជសម្បត្តិ ហើយទ្រង់សព្វព្រះរាជហឫទ័យ ឲ្យខ្ញុំសង់ប្រាសាទថ្វាយ, ខ្ញុំអាចសង់ថ្វាយបានមួយរំពេច ប៉ុន្តែនៅថ្ងៃណាមួយ ដែលព្រះមហាក្សត្រអង្គនោះទ្រង់សោយព្រះទិវង្គតទៅ, ប្រាសាទនោះក៏ត្រូវរលាយបាត់ក្នុងពេលនោះដែរ, ដូច្នេះឃើញថាឫទ្ធិអំណាចរបស់ឯង មានអានុភាពខ្លាំងលើសលុបលើឫទ្ធិអំណាចរបស់យើង ។

ទេវបុត្រក៏នាំសេចក្តីទៅក្រាបទូលព្រះឥន្ទ្រាធិរាជ អំពីលទ្ធផលដ៏ប្រសើរក្រៃលែង ដែលកើតមានមកអំពីការអប់រំព្រះពិស្ណុការ ។ ព្រះឥន្ទ្រក៏ទ្រង់សព្វព្រះទ័យជាខ្លាំង ហើយទ្រង់ទទួលស្គាល់ថា ព្រះពិស្ណុការនឹងទៅជាអ្នកអប់រំ ជាអ្នកបង្ហាត់បង្រៀនមនុស្សលោកទាំងអស់ ដែលកាន់

លទ្ធិពុទ្ធសាសនា ។ បន្ទាប់មកព្រះឥន្ទ្រក៏មានព្រះពជុង្ការថា :

" ជាងសំណង់ទាំងអស់ ដែលជាតិជាមនុស្សលោកមុននឹងកសាងអ្វីៗ ត្រូវតែរៀបដង្ហាយថ្វាយព្រះពិស្ណុការសិន ។ ឯប្រដាប់ដង្ហាយមានដូចតទៅនេះ គឺស្រា ១ ដប, ប្រាក់ ១ បាទ (១ រៀល), ដើមចេក ៤ គល់, មានដោតម្ជុលនឹងស្លាលើនោះផង, សំពត់ស ៤ ហត្ថ, អង្ករ ១ ផ្តិលនឹងទៀន ១ បើជនណាមួយចាប់ធ្វើកិច្ចការអ្វី ៗ មិនបានរៀបដង្ហាយនេះថ្វាយព្រះពិស្ណុការទេ អ្នកនោះឯងនឹងបើកភ្នែកពុំរួចឡើយ កាលបើឃើញពន្លឺថ្ងៃ; ដោយសារពពិកភ្នែកគ្របភ្នែក ( ភ្នែកអៀស៊ី ) ។

កាលបើព្រះឥន្ទ្រមានបន្ទូលមកដល់ត្រង់នេះ ព្រះអង្គនឹកឃើញដល់ព្រះកេតុមាលា ។ ព្រះអង្គក៏ទ្រង់ហោះចុះមកកាន់ប្រទេសកម្ពុជា ។ ពេលនោះជារាត្រីកាល មនុស្សលោកទាំងឡាយ មានសេចក្តីភ្ញាក់ផ្អើលជាខ្លាំងដោយឃើញពន្លឺភ្លឺត្រចះត្រចង់នៅលើមេឃ ហើយក៏ដណ្តឹងសួរគ្នាថាតើនរណាធ្វើអ្វីឲ្យរំដួលនៅលើមេឃ ។ ព្រះឥន្ទ្រក៏បានចុះមកដល់ក្នុងប្រាសាទស្តេច ។ ពួកអ្នកយាមក៏រត់ទៅទូលព្រះបាទទេវង្សអស្ចារ្យថា:

" មានសត្វលោកពុំដែលស្គាល់ចុះមកពីស្ថានទេវតា, មានរបៀបហាក់ដូចជាមនុស្សលោក, ប៉ុន្តែ មានពណ៌ខៀវ, មានពន្លឺចាំងដូចជាភ្លើង, បានចុះមកក្នុងប្រាសាទ " ។

ព្រះបាទទេវង្សអស្ចារ្យ យាងប្រញាប់តម្រង់ទៅប្រាសាទព្រះអង្គ

ហើយទ្រង់បានស្គាល់ថាជាព្រះឥន្ទ្រ, ព្រះរាជាទ្រង់ទុនលុតជង្គង់ថ្វាយបង្គំព្រះឥន្ទ្រ ។ ទ្រង់សួរថា: តើព្រះអង្គមានស្គាល់ព្រះរាជបុត្រខ្ញុំឬទេ ?

- ទូលព្រះបង្គំពុំដែលស្គាល់ទេ ។

- តើព្រះគេគុមាលាមានកំណើតយ៉ាងដូចម្ដេច ?

- ពន្លឺទៀវមានលាតសន្ធឹងនៅលើមេឃ រូបស្រាប់តែមានកម្រង់ផ្កាធ្លាក់មកលើអគ្គមហេសីទូលព្រះបង្គំ ហើយតមកមហេសីទូលព្រះបង្គំមានផ្ទៃពោះ ឥឡូវប្រសូតមកមានវ័យចម្រើនហើយ ។

- ហ្នឹងហើយ! គឺកូនខ្ញុំ ជាចុះមកចាប់បដិសន្ធិ ។

ឮដូច្នោះ ព្រះបាទទេវង់អស្ចារ្យ ក៏ទ្រង់ត្រាស់ហៅ ព្រះគេគុមាលាឲ្យចូលមក ។ ព្រះឥន្ទ្រក៏ចាប់លើកព្រះរាជកុមារ ឲ្យអង្គុយលើព្រះឧរូ(ភ្លៅ) រួចទ្រង់មានព្រះបន្ទូលថា "ពីដើមខ្ញុំឈ្មោះហៅថា មឃមាណព ។ ខ្ញុំបានសង់ផ្លូវថ្នល់ សង់ទំនប់ទឹក, សង់សាលា, សង់ស្ពាន, ខ្ញុំបានធ្វើបុណ្យដាក់ទានដល់អ្នកក្រីក្រលំបាក ដោយផលនេះ ខ្ញុំបានកើតទៅជាព្រះឥន្ទ្រ ។ ដូច្នេះ ខ្ញុំមានចិត្តនឹកអាណិតមកដល់ប្រទេសកម្ពុជាណាស់ ព្រោះជាប្រទេសទើបនឹងកកើតឡើងថ្មី ។ ហើយតាំងពីពេលនោះ មកទល់ឥឡូវនេះ គ្មានមនុស្សខ្លាំងពូកែណាម្នាក់ មកសោយនៅនគរនេះសោះដូច្នេះ, យើងនឹងជួយធ្វើឯងឲ្យបានសប្បាយ ហើយឲ្យ-នអាយុវែងផងផ្សេងអី, មនុស្សលោកសម័យនេះអាយុខ្លីណាស់, កម្រមាននរណាអាយុ

បានមួយរយឆ្នាំ ។ យើងនឹងនាំឯងយកទៅក្នុងប្រាសាទយើង ហើយឲ្យឯងចុះមុជទឹកក្នុងអាងមួយ ដើម្បីឲ្យបានអាយុវែង " ។

ព្រះឥន្ទ្រក៏លើកពព្រះកេតុមាលា ហោះទៅកាន់ស្ថានទេវតា ។ នៅក្នុងសួនច្បារព្រះឥន្ទ្រមានអាងទឹកមួយ, ព្រះឥន្ទ្រក៏យកព្រះកេតុមាលាទៅឲ្យមុជទឹកក្នុងអាងនោះមួយថ្ងៃ ៧ ដង លុះគ្រាតែគ្រប់ ៧ ថ្ងៃ ។ បន្ទាប់មក ព្រះឥន្ទ្រនាំព្រះកេតុមាលាចូលទៅក្នុងប្រាសាទព្រះអង្គ រួចព្រះឥន្ទ្រអញ្ជើញព្រាហ្មណ៍ ៧ នាក់ឲ្យមកសូត្រសែកមន្តគាថា និងប្រោះព្រំទឹកមន្តទៅលើព្រះកេតុមាលា ដើម្បីឲ្យបានអាយុមួយរយឆ្នាំ ។

កាលបើពិធីនេះ បានចប់សព្វគ្រប់ហើយ ព្រះឥន្ទ្រក៏ទ្រង់បង្គាប់ឲ្យគេទឹមព្រះកជវថបញ្ជិះព្រះកេតុមាលា បរហោះព័ទ្ធជុំវិញប្រាសាទព្រះអង្គ ដើម្បីឲ្យព្រះកេតុមាលាអាចមើលឃើញលំអប្រាសាទសព្វគ្រប់ទាំងអស់ ។

កាលបើព្រះកេតុមាលា បានសង្កេតមើលប្រាសាទព្រះឥន្ទ្រសព្វគ្រប់អស់ហើយ, នាយសារថីក៏នាំព្រះកេតុមាលាទៅមើលក្រោលគោសួគ៌ទៀត ។

ព្រះឥន្ទ្រក៏សួរទៅព្រះកេតុមាលាថា: " អ្នកពេញចិត្តនឹងវត្ថុអ្វីៗ ដែលអ្នកបានឃើញឬទេ ? "

– ខ្ញុំមានសេចក្តីសប្បាយសែងណាស់ !

– ដូច្នេះ. ខ្ញុំប្រគល់អាណាចក្រកម្ពុជានេះឲ្យឯង ។ ហេតុនេះ

បើឯងពេញចិត្តនឹងប្រាសាទណាមួយដែលឯងបានឃើញ ហើយចង់សង់ប្រាសាទមួយនៅប្រទេសកម្ពុជាឲ្យល្អដូច្នេះ, ចូរឯងគ្រាន់តែសំដែងទឹកចិត្តឡើង, យើងនឹងបញ្ជូនស្ថាបនិកម្នាក់ ឲ្យទៅសង់ឲ្យឯងនៅក្នុងនគរឯងមួយរំពេច ៗ នៅពេលនោះ ព្រះកេតុមាលាទើបតែនឹងមានអាយុ១៤ ឆ្នាំ ៗ ដូច្នេះ កុមារមានសេចក្ដីតក់ស្លុតខ្លាចព្រះឥន្ទ្រពន់ប្រមាណ ហើយបានគិតឃើញដូច្នេះថា "នៅក្នុងនគរអញ, អញពុំត្រូវធ្វើអ្វីឲ្យល្អជាងប្រាសាទព្រះឥន្ទ្រទេ បើសិនជាអញចង់ធ្វើអ្វីឲ្យល្អជាង ប្រហែលព្រះអង្គនោះព្រះអង្គមុខជាអាក់អន់ព្រះទ័យពុំខាន " ៗ

គិតដូច្នេះហើយ ព្រះកេតុមាលាឆ្លើយថា " ទូលព្រះបង្គំចង់ឲ្យគេសង់ប្រាសាទមួយ ដែលមានលំអប្រហែលគ្រោលគោព្រះអង្គ " ៗ

ព្រះឥន្ទ្រក៏ទ្រង់ព្រះសម្រួលថា:

" គ្រោលនេះជារបស់ល្អចំពោះភ្នែកចៅឯងហើយឬ ?

ហើយទ្រង់មានព្រះបន្ទូលថា:

" ចៅឯងជាជាតិមនុស្សលោក ពុំអាចស្ថិតនៅក្នុងស្ថានលើនេះបានរហូតទេ យើងនឹងបញ្ជូនចៅឯងចុះទៅកាន់នគរកម្ពុជា ហើយត្រូវឯងសង់ប្រាសាទឲ្យព្រះរាជបុត្រយើងមួយ ឲ្យមានសោភណភាពល្អជាងគ្រោលគោយើង, កាលបើចៅឯងសង់រួចស្រេចហើយ យើងនឹងចុះទៅធ្វើជាអធិបតីក្នុងពិធីរៀបចំអភិសេកព្រះរាជបុត្រយើងឲ្យឡើងសោយរាជ្យ " ៗ

កាលបើព្រះពិស្ណុការ បានពិនិត្យមើលគ្រោលគោព្រះឥន្ទ្រសព្វគ្រប់ហើយ, ព្រះឥន្ទ្រក៏ទ្រង់ព្រះរាជបញ្ជា ឲ្យគេរៀបចំទឹមព្រះរាជរថព្រះអង្គបញ្ជូនព្រះកេតុមាលា នឹងព្រះពិស្ណុការចុះមកកាន់ផែនដីនឹងនគរកម្ពុជា ។

ព្រះពិស្ណុការក៏ចាប់សង់ប្រាសាទភ្នំ គឺនៅ ព.ស. ៦២០ ។ លោកបានបង្គាប់ឲ្យជីកស្នាមគោះ យកអាចម៍ដីចាក់គរលើគ្នាយ៉ាងខ្ពស់ រួចទើបព្រះពិស្ណុការយករូបចម្លាក់ផ្សេង ៗ ទៅបិតលើដីនោះគ្រប់ទិសទាំងអស់ ។

ដំណាលពីកូនមេកូម្នាក់ឈ្មោះសុវណ្ណ ។ អ្នកកម្លោះបានចូលធ្វើជាកម្មករព្រះពិស្ណុការ ។ លុះសុវណ្ណបានយល់ការយ៉ាងថ្មីកលម្អធ្វើការខ្លួនឯងកើត, ព្រះពិស្ណុការក៏ជិះទូកទៅកាន់សមុទ្រ ដើម្បីរកសម្បកខ្យងមកដុតធ្វើជាកំបោរដើម្បីបូកប្រាសាទ ។ លុះត្រឡប់មកវិញ, មកដល់ត្រង់សំពេងសែន ស្រុកកំពង់លែង, ទូកក៏ត្រូវលិចទឹក ។ ព្រះពិស្ណុការក៏បានស្តារជំនិះនោះឡើង ប៉ុន្តែឥតកើបយកសម្បកខ្យងវិញទេ ។ អាស្រ័យហេតុនោះហើយ បានជាសព្វថ្ងៃនេះ គេឃើញមានសម្បកខ្យងជាច្រើនគរកប់នៅក្នុងដីក្នុងភូមិសំពេងសែន ។ ចាប់តាំងពីច្រើនឆ្នាំណាស់មកហើយ, អ្នកស្រុកក្នុងភូមិនោះ តែងបបួលគ្នារើសយកសម្បកខ្យងនោះមកដុតធ្វើជាកំបោរ, ប៉ុន្តែសម្បកខ្យងនៅតែមានចំនួនជាច្រើនក្រៃលែងរហូតមកដល់សព្វថ្ងៃនេះ ។

ថ្ងៃក្រោយមកទៀត ព្រះពិស្ណុការក៏ធ្វើដំណើរទៅកាន់សមុទ្រ ដើម្បី

រើសសម្បកខ្យងទៀត ។ ប៉ុន្តែមួងនេះ មានទូកសំពៅច្រើនណាស់ ហើយ ក៏បានសម្បកខ្យងមកជាច្រើនក្រៃលែង ។ បន្ទាប់មកទៀត, ព្រះពិស្ណុការក៏ចេញសំពៅបីដើម្បីទៅរកគ្រាប់ល្ង, ប៉ុន្តែ លុះត្រឡប់មកមានខ្យល់ព្យុះបោកបក់សំពៅមួយលិចទៅត្រង់កោះកំញាន ខាងលិចជូនទ្រើ ។ ព្រះពិស្ណុការក៏ចាក់គ្រាប់ល្ងក្នុងសំពៅនោះចោលទាំងអស់ រួចក៏ធ្វើគ្រាប់ល្ងនោះឲ្យរឹងក្លាយទៅជាកោះមួយ ។ ហេតុនោះហើយ, បានជាសព្វថ្ងៃនេះ គេសង្កេតឃើញក្នុងកោះកំញានមានពណ៌ខ្មៅ ដូចជាគ្រាប់ល្ង, គ្មានដីអ្វីទៀតនៅលាយជាមួយឡើយ ។

បំណែកឯគ្រាប់ល្ងនៅក្នុងសំពៅពីរទៀត, ព្រះពិស្ណុការក៏យកទៅលាយបូកពីលើប្រាសាទដី ដែលលោកបានសង់នោះ ។ ដីនោះក៏បានក្លាយទៅជាថ្មួយរំពេច ។ ដើម្បីនឹងសង់ប្រាសាទ ព្រះពិស្ណុការឥតចាំបាច់ចងរន្ទា, ដាំសសរមួយម្តង ៗ ដូចជាយើងទេ គឺលោកយកដីមកសង់ជាប្រាសាទ ៥ ជាន់តែម្តង ទើបយកទឹកថ្នាំលាយទៅលាបពីលើតួប្រាសាទដីទាំងមូលតែម្តង ៗ ប្រាសាទនោះក៏ក្លាយទៅជាថ្ម ។

អាស្រ័យហេតុនេះហើយ បានជាយើងឃើញត្រង់ៗកោងនៃដំបូលប្រាសាទឥតមានរនូតឬសសរទ្រពីក្រោមទេ ។

លុះការស្ថាបនាបានរួចស្រេចកាលណា, ព្រះពិស្ណុការក៏លាបថ្នាំលើរូបចម្លាក់ទាំងនោះ, តម្រូវទៅតាមពណ៌ផ្សេងៗ ធ្វើឲ្យប្រាសាទមាន

លំអឡើងយ៉ាងគ្រប់គ្រាន់ គឺល្អដូចជាក្រោលគោព្រះឥន្ទ្រ ។

ព្រះកេតុមាលាពេញចិត្តនឹងប្រាសាទនោះណាស់, បានពោលសរសើរព្រះពិស្ណុការជាច្រើន ហើយបានសុំឲ្យព្រះពិស្ណុការសង់ប្រាសាទឯទៀតជាច្រើនតាមដោយរូបចម្លាក់យ៉ាងធេតធាយ ។

ព្រះឥន្ទ្រាធិរាជដោយមានពួកទេវតាជាច្រើនតាមដង្ហែផង បានយាងចុះមកស្ថានក្រោម ប្រសិទ្ធិពរអភិសេកព្រះរាជបុត្រព្រះអង្គ ហើយព្រះអង្គក៏ថ្វាយព្រះនាមថា អរិដ្ឋពលពាហនោ (ព្រះកេតុមាលា) រួចទ្រង់ហៅឈ្មោះប្រទេសខ្មែរយើងថា កម្ពុជាដូចសព្វថ្ងៃនេះ ។

នៅពេលក្រោយមក, ព្រះកេតុមាលាទ្រង់បានសង្កេតឃើញកំពូលប្រាសាទមួយពុំសូវត្រង់ ទ្រង់ក៏មានបន្ទូលប្រាប់ព្រះពិស្ណុការឲ្យឡើងតម្រង់កំពូលនោះ ។ ព្រះពិស្ណុការបានឆ្លើយថា "សូមព្រះអង្គទ្រង់ប្រើស្រីម្នាក់ ឲ្យយកផ្លែឃ្លោកទុំទៅរាយកំពូលនោះៗនឹងងើបត្រង់ឡើងវិញ" ។

ទ្រង់ព្រះសណ្ដាប់ដូច្នេះ ព្រះកេតុមាលាក៏ទ្រង់ព្រះពិរោធជាខ្លាំង ។ ព្រះអង្គទ្រង់បានបញ្ចេញនូវព្រះសូរសៀងយ៉ាងខ្លាំងៗថា "តើឯងចង់និយាយយ៉ាងម៉េច, កំពូលប្រាសាទធ្វើសុទ្ធតែអំពីថ្ម, ឯងប្រាប់ឲ្យយកផ្លែឃ្លោកទុំទៅរាយតម្រង់?" ។ ចំណែកឯព្រះពិស្ណុការក៏ខឹងនឹងព្រះរាជាដែរ ហើយបានឆ្លើយថា :

បើព្រះអង្គមិនទ្រង់ជឿទូលព្រះបង្គំទេ សូមឲ្យកំពូលប្រាសាទស្អិត

នៅតែទ្រេតដូច្នេះទៅ ។ ហើយតទៅមុខទៀត, សូមឲ្យកុំពួលប្រាសាទដូចជាប្រាសាទអង្គរនេះទ្រេតដូចជាប្រាសាទនេះដែរ ៗ

ពេលក្រោយបន្តិចមកទៀត, ព្រះកេតុមាលាបានប្រគល់ដែកទម្ងន់បីហាប, ដើម្បីឲ្យព្រះពិស្ណុការធ្វើព្រះខ័នមួយ ជានិមិត្តរូបនៃតេជានុភាពព្រះអង្គថ្វាយព្រះអង្គ ៗ ព្រះពិស្ណុការបានយកដែកនោះទៅសូរំលាយនៅសល់តែល្មមធ្វើព្រះខ័នតូចមួយ, មានមុខស្តើងជាងស្លឹកស្រូវទៅទៀត ប៉ុន្តែមុតជាក្រៃលែង គឺថាបើគេយកព្រះខ័ននេះទៅកាប់ខ្លួនមនុស្សជាពីកំណាត់, គេពុំអាចមើលដឹងជាខ្លួនមនុស្សដាច់ឡើយ, គេស្មានថាគេកាប់ឥតត្រូវខ្លួនទេ, មនុស្សនោះប្រហែលជានៅនិយាយបានដូចពីដើម, ប៉ុន្តែបើគេយកដៃទៅប្រាន, ខ្លួនមនុស្សនោះនឹងដាច់ធ្លាក់ជាពីរភ្លាម ៗ ម្យ៉ាងទៀត, បើគេយកពាងមួយធ្វើអំពីដីមានដាក់ទឹកពេញ គេអាចកាប់ពាងនោះឲ្យដាច់ជាពីរបាន ដោយឥតធ្វើឲ្យទឹកហូរចេញបានឡើយ លុះតែគេយកដៃទៅពាល់ពាងនោះ ទើបពាងបែកដាច់ជាពីរហើយ ទឹកក៏កំពប់ចេញ ៗ

ព្រះពិស្ណុការបានយកព្រះខ័នដែលទើបនឹងធ្វើហើយ ទៅលត់ទឹកយ៉ាងត្រឹមត្រូវ រួចក៏យកទៅថ្វាយព្រះកេតុមាលា ៗ ព្រះកេតុមាលាកាលបើទតឃើញទំហំព្រះខ័នភ្លាម ក៏ទ្រង់ក្រោធជាខ្លាំងក្រៃលែង, ព្រមទាំងទ្រង់បន្ទោសព្រះពិស្ណុការយ៉ាងគំរោះគំរើយ នៅចំពោះមុខនាហ្មឺនសព្វ

មុខមន្ត្រីទាំងអស់ថា " អ្នកឯងបានលួចដែកខ្ញុំ យកទៅប្រើជាប្រយោជន៍ផ្ទាល់ខ្លួន បានជាអ្នកឯងធ្វើព្រះខ័នឲ្យយើងតូចដូច្នេះ! ។ ព្រះពិស្ណុការក៏ខឹងប្រទេ្បាតតូងតាងដែរ ហើយឆ្លើយថា "ខ្ញុំលែងនៅប្រទេសកម្ពុជាទៀតហើយ, ខ្ញុំនឹងត្រឡប់ទៅនៅឯប្រទេសចិននោះវិញ " ។

ថាដូច្នេះហើយ, ព្រះពិស្ណុការក៏ក្រោកដើរចេញ ដោយបង្ហួសមុខព្រះខ័នលើក្តារ ។ លុះព្រះពិស្ណុការចេញផុតទៅ, គេសង្កេតឃើញក្តារដាច់ជាពីរដោយអំណាចមុខព្រះខ័នដែលព្រះពិស្ណុការបានអូសពីលើ ។ ទ្រង់ទតឃើញដូច្នោះ, ព្រះកេតុមាលាក៏ត្រាស់បង្គាប់ឲ្យគេរត់តាមស្រែកហៅព្រះពិស្ណុការ ហើយទារយកព្រះខ័នមកថ្វាយព្រះអង្គវិញ ។ ប៉ុន្តែព្រះពិស្ណុការប្រកែកពុំព្រមឲ្យ ហើយគ្រវែងចោលទៅកណ្តាលទន្លេសាប រួចក៏ចុះសំពៅបើកក្តោងសំដៅទៅស្រុកចិន ដែលជាស្រុកកំណើតរបស់គាត់ ។

នេះហើយជារឿងព្រះពិស្ណុការ ដែលមនុស្សភាគតិចណាស់បានដឹង, ហើយដោយសារការពុំដឹងនេះហើយ បានជាមនុស្សភាគច្រើនបានយល់ខុសថា គឺទេវតាដែលបានកសាងប្រាសាទអង្គរ ។

---

# រឿងព្រេងប្រទេសចិន

# បែងអំពីបព្វជិតនឹងដើមព័រ

### ភិក្ខុ ម៉ែន-វៀម

*សិស្សពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ*

ប្រែចាកភាសាអង់គ្លេស

---

នៅក្នុងទីផ្សារនៃភូមិមួយ, ថ្ងៃមួយមានកសិករម្នាក់ ដែលមានរទេះផ្ទុកពេញទៅដោយផ្លែព័រដ៏ល្អ ៗ ។ មនុស្សទាំងឡាយ បានមកបោមមើលផ្លែព័រនោះ ជិតជុំវិញរទេះគាត់ ព្រោះគេទាក់ចិត្តចំពោះផ្លែព័រទាំងនោះជាខ្លាំង ។ ម្ល៉ោះហើយ កិត្តិស័ព្ទរបស់គាត់ ត្រូវតែផ្សាយទៅក្នុងទីកប់ម៉ៃល៍ ដោយសារតែគុណភាពនៃផ្លែឈើរបស់គាត់នោះ ។

លាយជាមួយគ្នានឹងកិត្តិស័ព្ទចំពោះគុណភាពនៃផ្លែឈើ, កសិករបានទទួលនូវកិត្តិនាមខាងសេចក្តីកំណាញ់ស្វិតស្វាញ នឹងខាងការព់យតម្លៃផ្លែឈើរបស់ខ្លួនយ៉ាងខ្ពស់ថែមទៀត ។

កាលដែលហ្វូងមនុស្ស កំពុងតែឈរជិតជុំវិញរទេះគាត់តាមរបៀបនេះ ស្រាប់តែមានបព្វជិតចរាចរ រខេករខាកចាស់ក្រទ្រុបមួយអង្គ និមន្តដែកគេ-ឯង មកទតផ្លែព័រនោះដែរ ៗ ដោយការកំសត់អត់ឃ្លានខ្លាំង; ស្រមណ៍អង្គនេះ បានសុំបិណ្ឌបាតផ្លែព័រមួយពីកសិករ ។ ប៉ុន្តែ កសិករជាអត្តទត្តបុគ្គលប្រកបដោយសន្តានចិត្តអាក្រក់ បានប្រកែកមិនព្រម

ប្រគេនសោះ ៗ បព្វជិតកំសត់ ដោយគ្មានសេចក្ដីនឿយណាយចំពោះចម្លើយដ៏គ្រោតគ្រាត ដែលលោកបានទទួល, មិនសុខចិត្តនិមន្តចេញពីមុខរទេះ នឹងការសំឡឹងមើលនូវផ្លែឈើនោះសោះឡើយ ៗ

កសិករ ទៅជាក្ដៅក្រហាយចំពោះអាកប្បកិរិយាបែបនេះជាខ្លាំង, ថែមទាំងដេរប្រទេចលោក ហៅលោកតាមឈ្មោះដែលមិនជាទីគាប់ចិត្តជាច្រើនបែបទៀត ៗ តែស្រមណ៍ នៅតែឈរតាមរបៀបដដែល ហើយមានថេរដីកាថា: "ម្នាលអ្នកជនបទ ផ្លែព័ររបស់អ្នកមានចំនួនជាច្រើនរយ, តាមពិត បើអ្នកប្រគេនអាត្មាតែមួយមក ក៏អ្នកគ្មានបង់ខាតអ្វីដែរ!" ៗ

ជនខ្លះនៅក្នុងហ្វូងនោះ និយាយឡើងនៅពេលនោះថា: "យី! ម៉េចអ្នកមិនប្រគេនលោកមួយទៅ? បើមិនឲ្យលោកអាល្អទេ ក៏គួរឲ្យអាណាមួយដែលទន់ទៅ អ្នកមិនខាតទេ!" ៗ

កសិករ ដោយរឹតតែក្ដៅខ្លាំង ព្រមទាំងមុខរឹងផងនោះ ក៏បររទេះទៅមុខទៀត, គាត់ពោលថា៖ "មិនលេងទេណា៎! ខ្ញុំដែលដាំដើមឈើនេះនឿយណាស់, ខំធ្វើការណាស់, ខ្ញុំគ្មានធនុះ នឹងដឹកយកផ្លែព័រនេះមកកាន់ទីផ្សារ ដើម្បីចែកដោយសប្បុរសនោះទេ!" ៗ

មនុស្សដទៃទៀតក្នុងទីផ្សារ ក៏ចាប់និយាយអ៊ូអរឡើង, ខ្លះកាន់ជើងកសិករ ខ្លះកាន់ជើងបព្វជិត ៗ សំឡេងមនុស្សទាំងនោះ បានខ្សៀវខ្សួរ

អឺងកងឡើង, មានការពិភាក្សា មានការតំហកដាក់គ្នា ៗ សួរអ្វីអែរេះ តែខ្លាំងឡើង ៗ ៗ ទីបំផុត ស្រាប់តែមានជនម្នាក់ដើរចូលទៅ ហើយយកប្រាក់មួយហ៊ន (Coin) ហុចទៅអ្នកស្រែ ដោយពោលថា: " អ្នកឯងគាប់ចិត្តនឹងទិដ្ឋភាពដ៏អាប់អួរ ចំពោះកុសលកម្មដ៏តូចតាចនេះឬ ? ហ៊ឺ ! នេះប្រាក់, ប្រគេនផ្លែព័រទៅលោកមួយទៅ ! " ។

កសិករបានហុចផ្លែព័រមួយទៅបព្វជិត ហើយលោកបានទទួលយកនូវអំណោយនេះ ដោយអាការទុនយ៉ាងខាប ៗ រួចហើយ លោកមានថេរដីកាទៅកាន់ប្រជុំជននោះថា " អាត្មាមានការស្តុគ្រស្តាញពិបាកចិត្តខ្លាំងណាស់ ចំពោះមនុស្សដែលមានក័ព្វសំណាងល្អ ដូចជាអ្នកលក់ផ្លែព័រនេះ ហើយត្រឡប់ជាអ្នកកំណាញ់ស្វិតរំគៀត មិនព្រមចំណាយសូម្បីតែផ្លែព័រមួយយ៉ាងនេះ; អាត្មាដែលមកសុំបិណ្ឌបាតផ្លែព័រមួយនេះ បានបរិច្ចាគតែគ្រប់យ៉ាងអស់រលីង នៅពេលដែលអាត្មាមកបួស; អាត្មាគ្មានបច្ច័យទេ, គ្មានផ្ទះទេ, គ្មានគ្រួសារទេ, ប៉ុន្តែអ្វីដែលអាត្មាមានអាត្មាតែងយកចែកដល់អ្នកដទៃទៀត ដោយសោមនស្ស; ដើម្បីជាតឹកតាងអាត្មាមានដើមព័របរិបូណ៌ដោយផ្លែមួយដើម, អាត្មាសុំឲ្យអស់អ្នកឈររង់ចាំមួយភ្លែត ដើម្បីអាត្មានឹងចែកឲ្យអ្នកគ្រប់គ្នា ជាមួយនឹងអាត្មា ។

ពួដូច្នេះ, បុរសម្នាក់សួរថា " ចុះបើលោកតា មានផ្លែព័រច្រើន

មើចកំតាំបាច់មកសុំគេ ? ។ "ទេ ! ដំបូងអាត្មាត្រូវដាំក់សិន !" (បញ្ជិតឆ្លើយ) ។

ក្នុងនោះ ព្រះសង្ឃអង្គនេះ បានឆាន់ផ្លែពីរដែលគេប្រគេននោះ រួចបន្ទេចគ្រាប់មួយចេញមក ។ លោកជីករណ្ដៅមួយទៅក្នុងដី ហើយដាក់គ្រាប់ទៅក្នុងរណ្ដៅ, រួចលុបដីដោយធូរ ៗ ឲ្យពេញរណ្ដៅនោះ ។ លុបដីរួច លោកមានថេរដីការថា "អាត្មាត្រូវការទឹក" ។ ឃើញដូច្នោះ, មនុស្សក្នុងហ្វូង នាំគ្នាសើចហោរឡើង, ប៉ុន្តែមានកុមារម្នាក់បានរត់យកក្អមទឹកមួយមកប្រគេនលោក ហើយលោកក៏ស្រោចទៅលើកន្លែងដាំនោះ ។

តែមួយភ្លែតប៉ុណ្ណោះ, គេបានឃើញពន្លកខៀវតូចមួយ ទំលុះស្រទាប់ដីចេញមកក្រៅ ។ ពន្លកបានចាប់លូតលាស់ខ្ពស់ឡើង ៗ យ៉ាងរហ័ស ។ សាខាទាំងឡាយ ក៏ប្រាកដលើក្នុងវត្តជាតិ ហើយស្លឹកទាំងឡាយ ក៏ចេញពីមែកទាំងនោះមក ។ ពន្លក បានក្លាយទៅជាដើមឈើ រួចចេះតែងើបខ្ពស់ឡើង ១ ។ ស្លឹកដ៏ខៀវងងឹត ចេះតែលេចចេញមក, រួចចេញត្រួយ . . . បន្ទាប់មកចេញជាផ្កាពីរ ។ ផ្កាបានជ្រុះអស់ ក្ដិបពីរក៏ជាក់ស្ដែងឡើង ។ ហើយក្ដិបចេះតែរីកធំឡើង ដកបដល់ពេញរូបរាង ។ ផ្លែដ៏ល្អស្រស់ បានទម្ងន់ធ្ងន់មែកឲ្យទោរទន់ចុះ ដោយសារចំនួនច្រើនរៃខ្លួន ។

ឃើញយ៉ាងនេះ ហ្វូងមនុស្សបានទះដៃឡើង ដោយសោមនស្ស

ចិត្ត ៗ បព្វជិតដែលមានព្រះកត្រ្គីគេថ្វាដោយសេចក្ដីសប្បាយ បានបេះផ្លែព័រមួយម្ដង ៗ ចែកទៅក្រុមប្រជាជន តាមរបៀបអំណោយ ៗ

កសិករលក់ផ្លែព័រ ដែលកំណាញ់មិនព្រមប្រគេនអ្វីទៅព្រះសង្ឃនោះ ក៏ឈរមើលប្រហមាត់ធុង ៗ ទីបំផុត, ព្រះសង្ឃបានបេះផ្លែព័រចុងក្រោយមួយ អំពីរុក្ខជាតិដ៏អស្ចារ្យហើយចំណាយចេញទៅ ៗ អស់ផ្លែហើយ លោកទាញយកពូថៅដៃមួយពីចង្កេះលោក ទៅកាប់រំលំឈើនោះ ៗ លោកលំឈើនោះ និមន្តចេញពីផ្សារ, ចេញពីហ្វូងមនុស្ស ដែលកំពុងតែទំពាស៊ីផ្លែព័រ ៗ

កសិករលក់ផ្លែព័រ ក៏ដូចជាអ្នកដទៃទៀតដែរ បានឈរមើលបព្វជិតកំសត់ លុះគ្រាលោកនិមន្តផុតពីកន្ទុយភ្នែក លែងមើលឃើញ ៗ ពេលនោះ គាត់ងាកត្រឡប់មកមើលរទេះគាត់វិញ ស្រាប់តែទៅជារន្ធត់ញាប់ញ័រ ដោយឃើញរទេះខ្លួនទទេស្អាត, បាត់ផ្លែព័រអស់ សូម្បីតែមួយក៏មិនសល់! ៗ

ក្នុងពេលភ្លាម ៗ នោះ គាត់បានយល់នូវហេតុការណ៍ ដែលកើតឡើងថា ផ្លែព័រដែលលោកតាកញ្ចាស់យកមកចែកដោយសប្បុរសចិត្តនោះ គឺបានមកពីក្នុងរទេះគាត់ ៗ ផ្លែឈើទាំងនោះ សុទ្ធតែជារបស់គាត់ ៗ

កាលគាត់ឈរពិចារណាអំពីព្រឹត្តិការណ៍ នៃហាយនភាពក្នុងទីនោះ, កសិករបានឃើញថា ទូករទេះរបស់គាត់ បាត់ម្ខាងទៅហើយ ៗ គាត់រក

មើលដោយពិនិត្យពិច័យទៅ ក៏បានកត់សំគាល់ថា ទូករទេះនោះ ត្រូវបញ្ឆិតកាប់ពោលដោយពូថៅដៃលោកទៅហើយ ។ ដូច្នេះ គឺជាទូករទេះនេះហើយ ដែលបញ្ឆិតបានក្របែលរំលំពោល នៅពេលមុនពេលលោកនិមន្តចេញពីប្រជុំជន ។

កសិករលក់ផ្លែព័រ ទៅជាប្រឡាតខឹងយ៉ាងពន្លឹក, គាត់តែចេញពីផ្សារ ទៅតាមបញ្ឆិត, តែគាត់ឥតជួបលោកឡើយ គាត់បានឃើញទូករទេះបាក់បែកមួយ នៅតាមផ្លូវក្បែរចិញ្ចើមថ្នល់ ។

កាលដែលមហាជននៅទីផ្សារ បានយល់ច្បាស់នូវការកំផ្លែងសួតនៃបញ្ឆិតចកបរនេះហើយ ក៏កើតមានការច្រួលច្របល់យ៉ាងខ្លាំង មានតែអ្នកស្រែលក់ផ្លែព័រតែម្នាក់ឯងប៉ុណ្ណោះទេ ដែលមិនអាចហាមាត់សើចជួបគេបាន ។

ចំណែកលោកតាចាស់ គ្មានអ្នកណាឃើញ – ជួបក្នុងចំណែកណាមួយនៃស្រុកស្រែនោះទៀតឡើយ ។

រដ្តើ ៗ ធ្វើឲ្យចាស់គោអស់

# លោក ញុង·សឿង រៀបរៀង

ពូប្រេស មីង ប្រែង គាត់មានកូនតែពីរនាក់ប្រុស ១ ស្រី ១ ។ គាត់បានរៀបចំកូនប្រុសឲ្យមានប្រពន្ធ នៅភូមិឆ្ងាយបន្តិចពីភូមិរបស់គាត់ ព្រមទាំងបានចែកកេរ្តិ៍មរតកមានស្រែនិងគោជាដើម ឲ្យកូនប្រុសគាត់តាមសមគួរដល់ធនធានដែលគាត់មាន ។ កាលកូនប្រុសបែកផ្ទះសម្បែងទៅនៅខាងប្រពន្ធគេទៅ ពូ-មីង គាត់នៅតែ ៣ នាក់និងកូនស្រី ។

លំដាប់តមក មិនយូរប៉ុន្មាន, មានគេចូលមកគិតគូរដណ្ដឹងកូនស្រីគាត់ ៗ ក៏ព្រមព្រៀងឲ្យហើយក៏បង្គាប់ឲ្យខាងប្រុសធ្វើផ្ទះមួយខ្នង ដើម្បីនឹងរៀបចំមង្គលការ ។

នៅពេលដែលកូនប្រសាបានសង់ផ្ទះរួចស្រេចហើយ កិច្ចអាពាហ៍ពិពាហ៍ ក៏ផ្ដើមឡើងយ៉ាងអឹកអធឹកតាមគន្លងប្រពៃណី ។ លុះរៀបមង្គលការកូនស្រីហើយបានប្រហែលកន្លះឆ្នាំ, ពូ ប្រេស មីងប្រែង ក៏លក់ផ្ទះថ្មីដែលកូនប្រសាសង់ជូននោះទៅ ដើម្បីយកប្រាក់កាសវិញគោមួយនឹមឲ្យកូនធ្វើស្រែ ផ្សំនឹងគោគាត់មួយនឹមដែលមានស្រាប់ពីមុនមកនោះឲ្យបានជាពីរនឹម ហើយគាត់ឲ្យកូនមកនៅផ្ទះចាស់ជាមួយ, គាត់នៅល្វែងខាងមុខ កូនប្រសានៅល្វែងខាងក្រោយ ។ ឯផ្ទះចាស់គាត់នោះ មិនសូវជាមាំមួនប៉ុន្មានទេ ជើងសសរខ្លះដីស៊ីពុកអស់ហើយ តែគាត់បាន

ទល់ទ្រនៅជាបណ្ដោះអាសន្នសិនទៅ គាត់ថាចាំរកស៊ីធូរធារបន្តិច សឹមលៃលកធ្វើផ្ទះថ្មីមួយទៀតឲ្យបានសុកសុម ។

វេលាសម័យថ្ងៃមួយ ពូប្រេស មឹង ប្រែង ភ្ញាក់ឡើងពីព្រលឹមស្រាងៗ ក្រឡេកមើលក្រោមផ្ទះ ស្រាប់តែបាត់គោអស់ទាំងពីរនឹម គាត់នឹកស្រណោកចិត្តជាខ្លាំង បានស្រែកហៅកូនយ៉ាងឡោឡោសាកសួរពីរឿងនេះ ។ អ្នកទាំងអស់គ្នា មានសេចក្ដីស្ដាយក្រៃលែង ព្រោះជិតដល់រដូវធ្វើស្រែផង ។ ពួកអ្នកភូមិជាមួយ កាលបានដឹងដំណឹងនេះហើយ ក៏នាំគ្នាមកសួរគាត់ ជាការជួយព្រួយនឹងជួយស្ដាយជាមួយផង ។ គ្រានោះ ពូប្រេស បានប្រើកូនប្រុសឲ្យទៅប្រាប់ ពូជ្រា សំឡាញ់គាត់ ដែលនៅភូមិមួយឆ្ងាយពីភូមិនោះ ដើម្បីឲ្យជួយស៊ើបសួររកគោពីរនឹម ដែលចោរបានលួចបាត់ពីយប់មិញ ព្រោះ ពូជ្រា ជាមនុស្សម្នាក់ដែលធ្លាប់ស្គាល់ដើងចោរស៊ើរគ្មានសល់ចន្លោះ ។ កូនប្រុសកាលបានទទួលពាក្យឪពុកគេកហើយ ក៏ប្រញាប់ប្រញាល់ស្រូតរូតទៅដល់ផ្ទះ ពូជ្រា ហើយប្រាប់អំពីរឿងបាត់គោតាមដំណើរ ។ ពូជ្រា បន្ទោស: " ក្មួយឯងប្រហែសណាស់! ចុះនាំគ្នាដេកទ្រមក់អីខ្លាំងម្ល៉េះ ទាល់តែចោរគាស់រនុកយួងក្រោមផ្ទះលួចគោបាត់អស់រលីងយ៉ាងនេះ ? " ។ បុរសតប: " ទេពូ! ពូថាប្រហែសក៏បានដែរ តែពេលនោះ ដូចជាសិយតែម្ដង កុំអីមិនបាត់សោះទាស់តែ..." ។ ពូជ្រា: "រឿងនោះយ៉ាងម៉េច ទាស់តែ... ស្អី?" ។

កូនប្រសាពូប្រេស (ញញឹមខ្លីប)៖ "ខ្ញុំស្ទើរមិនហ៊ានដំណើរពូទេ ក្រែងពូឯងមាត់មិនជិត" ។ ពូជ្រា៖ "ព្រើល ១ ! ជាតិមនុស្សគ្មានអ្នកណាមាត់ជិតជាងពូទៀតទេ រឿងយ៉ាងម៉េច និយាយទៅមើល ឲ្យគ្នាបានដឹងផងក្រែងលោគ្រាន់បានជាគ្រឿងបំភ្លឺខ្លះ ដល់ការលៃលកកេគោនោះ" ។ កូនប្រសាពូប្រេស (ខ្សឹប ១) "ខ្ញុំស្ដាយណាស់ពូអើយ ! ស្ដាយហើយស្ដាយទៀត ស្ដាយលែងឃុំទបាយតែម្ដង ! ពាក់កណ្ដាលអធ្រាត្រយប់មិញ គឺពេលដែលចោរលួចគោនោះ ខ្ញុំក៏បានដឹងដែរ តែទាស់មកពីស្មានខុសស្រឡះ គុំអើមិនបាត់សោះ, មុនដំបូង រនេ្តី ១ រញ្ជួយ ១ អស់ទាំងល្វែងផ្ទះ ខ្ញុំក៏ភ្ញាក់ព្រើតឡើងនឹកថា យី ! រនេ្តីស្អីអេះ ? ផ្ទៀងត្រចៀកស្ដាប់បន្តិចទៅទៀត នៅតែរនេ្តី ១ ដដែល ខ្ញុំក៏គិតថា ន ! ប្រហែលរនេ្តីល្វែងខាងឪពុកក្មេកពីរឿងនុះដូចធម្មតាមុនៗទេមើលទៅ" ។ និយាយដល់ត្រង់នេះ ពូជ្រាគាត់អត់ទ្រាំមិនបាន ក៏ធ្លាយសំណើចយ៉ាងខ្លាំងលាន់ឮហាះ ១ ហើយគាត់សួរថា រួចពីនេះយ៉ាងម៉េចទៅទៀត ។ កូនប្រសាពូប្រេសក៏បានបន្តរឿងទៅទៀតថា រួចពីនេះ ខ្ញុំក៏សម្ងំដេកលក់ទៅវិញទៅ លុះព្រលឹមឡើង ស្រាប់តែឮមាត់ឪពុកក្មេកនឹងម្ដាយក្មេកខ្ញុំ គាត់ស្រែកឡូឡាឆោឡោថាបាត់គោពីក្រោមផ្ទះអស់រលីងទៅហើយ ខ្ញុំប្រហោងពោះធុនតែម្ដង ទើបខ្ញុំនឹកឃើញច្បាស់

ថា ៗ ! រឿងរន្ធើ ១ ពីយប់មិញនោះ គឺរន្ធើមកពីចោរវាររន្ទៀកដកស្នៀត
ទុកឃ្នងក្រោមផ្ទះសោះទេតើ ! រឿងហ្នឹងគឺមកពីខ្ញុំស្មានខុសយ៉ាងនេះ
ឯងណាពូ កុំអីគោទាំងនោះ មិនបាត់សោះ, ឥឡូវឪពុកក្មេកខ្ញុំនឹងខ្ញុំមាន
សេចក្ដីសង្ឃឹមទុកចិត្តលើពូទាំងអស់ សុំពូអាណិតជួយខ្នះខ្នែងយ៉ាងណា
រកគោទាំងនោះឲ្យឃើញវិញកុំខានណាពូ ព្រោះរដូវស្រូវឆ្នាំនេះ បើ
រកគោមិនឃើញទេមុខជានឹងខកខានធ្វើស្រែហើយ, តែទីបំផុត ខ្ញុំសុំ
ចិត្តពូថា រឿងរន្ធើដែលខ្ញុំបានជំរាបពូអម្បាញមិញនេះ សុំពូអាណិតកុំមាត់
កឲ្យលេចឮឲ្យសោះ តិចលោដឹងដល់ឪពុកក្មេក ឆាប់ខ្ញុំតែម្ដងហើយ ៗ
ពូជ្រាតប : " ពូមិនងាយឲ្យលេចឮផ្ដេសផ្ដាសទេ ចំណែករឿងគោនោះ
ពូនឹងជួយស៊ើបដឹងការមើលតាមដំណើរការណ៍តទៅ " ៗ កូនប្រសា
ពូប្រុសបានជំរាបលាពូជ្រាវិលត្រឡប់ទៅផ្ទះវិញ ទៅដល់ហើយក៏ពឹង
ពាក់ញាតិមិត្រជិតខាងភូមិផងរបងជាមួយឲ្យជួយស្កាត់រកមួយប៉ែកខាងនេះ
ដែរ ស៊ើបសួរគ្រប់ច្រកល្ហកអស់ ៣-៤ ថ្ងៃតែគ្មានឮដំណឹងអ្វីសោះ ៗ

វិលមកមួយអាទិត្យ, វេលាព្រឹកថ្ងៃមួយ ស្រាប់តែលេចពូជ្រាជិះ
សេះធ្លក់ ១ មកដល់មុខផ្ទះពូប្រុស ៗ កាលចងសេះក្រោមម្លប់ដើមស្វាយ
ក្បែរផ្ទះរួចស្រួលបួលហើយ ពូជ្រាក៏ឡើងទៅលើផ្ទះ ៗ ម្ចាស់ផ្ទះទាំង
ប្ដីប្រពន្ធ បានទទួលភ្ញៀវដោយសេចក្ដីរីករាយ ព្រមទាំងសួរភ្លាមអំពី
ដំណើររកគោនោះ តើបានការយ៉ាងណាខ្លះ ៗ សំឡាញ់តបវិញថា

“ ស្ងាត់សូន្យដូចចោរលួចគោតែម្តងហើយរុំអាសំឡាញ់ ពួកចោរជាន់នេះស្ទើរតែដើរឯកហើយ បានជាគ្មានលេចឮដំណឹងល្ហិចល្ហៀងបន្តិចបន្តួចសោះ” ។ ពូប្រុស : “ ខ្ចាបអាចោរគេកាប់អម្បែងក្បាល ! អញពីងម្តងដូចខ្យល់កកអាចម៍ ! មកនិយាយលេងព្រើល ៗ ផ្តេសផ្តាស ! ” ។ មីងប្រែងបន្ទោសថែម : “ អ្នកជ្រាងឯងបើគេឯទៀតដែលបាត់គោពីមុន ៗ ចេះតែជួយរកទាល់តែឃើញ គ្រង់ខ្ញុំវិញពីងម្តងគ្មានបានការសោះ” ។ កៀវ “ ខ្ញុំខិតខំរកអស់ប៉ុណ្ណឹងហើយអ្នក តែពេលនេះគឺរាបប់គ្នាត្រឹមស្ងាត់សូន្យឈឹងហ្នឹងឯង មិនដឹងជាលែលកទៅតាមប្រកណាទៀតទេ ” ។ មីងប្រែង ក៏ចូលដើរក្រានដាំបាយធ្វើម្ហូប ដើម្បីទទួលកៀវ ។ ពូប្រុសនៅជជែកលេងជាមួយមិត្រ ទំរាំដល់ពេលបាយឆ្អិន, គាត់និយាយតែរឿងបាត់គោនោះឯងដដែល ៗ ។ ពូជ្រាបន្ទោស : “ អាឯងនេះបានជាចួស់ក្លាយបាត់ទ្រព្យរបស់យ៉ាំងនេះ មកពីដេកទ្រមក់ពេក មិនប្រតិបត្តិតាមដំបូន្មានចាស់ទុំសោះ, សាស្ត្រាច្បាប់ប្រុសដែលយើងធ្លាប់បានរៀនសូត្រតាំងពីក្មេងមកនោះ អាឯងនៅចាំបានខ្លះឬទេ ? លោកថា . . . នឹងដេកកុំទ្រមក់ ឲ្យលង់លក់ក្រៅពីក្បួន បើភ្ញាក់ឲ្យដឹងខ្លួន ឡើងអង្គុយកុំមាត់ខ្ទាំង; ប្រែប្រាណរាប្រុងវិញ្ញាណ ខ្វាចក្រែងមានចោរចិត្តខ្លាំងប្រញាប់ប្រាណប្រយ័ត្នជញ្ជាំង ជញ្ជូនទ្រព្យលួចយកចេញ; បើឥតមោះមន្ទិលកុំឲ្យខ្ជិលដេកទៅវិញ ភ្ញាក់ហើយឲ្យក្រោកចេញ រកជក់ថ្នាំស៊ីម្លូស្លា ...។

ប្រែស : "អាចោលម្សៀត ! ច្បាប់នេះអញក៏នៅចាំដែរ អញមានដេក ថ្ងៃមក់កាលណា គឺពេលយប់នោះអញភ្ញាក់ឡើងដឹងខ្លួនដែរ តែមកពីអញ ស្មានខុសស្រឡះ កុំអីមិនបាត់សោះ ! អញនឹកឡើងក្ដៅក្រហាយស្ដាយ ក្រោយស្ទើរតែបោកក្បាលបំបែកនឹងសសរទ្រូងផ្ទះហ្នឹងឥឡូវ " ។ ពូជ្រា នឹកតែក្នុងចិត្តថា អានេះធ្លាក់គន្លងកូនប្រសារទៀតហើយ ទើបបញ្ជាក់ ថា : " ស្មានខុសយ៉ាងម៉េច ? " ។ ប្រែស ( ខ្សឹបបណ្ដើរ ញញឹមបណ្ដើរ ) : " រឿងនេះមិនគួរនិយាយទេ វាជ្រុលហួសអស់ទៅ ហើយ តែថា ណ្ហើយ ! និយាយប្រាប់អាឯងបន្តិចទៅចុះ ពាក់ កណ្ដាលអធ្រាត្រយប់នោះ អញភ្ញាក់ឡើងស្រាប់តែរង្គើ ៗ អស់ទាំង ល្វែងផ្ទះ អញក៏បង្ហើបក្បាលពីខ្នើយបន្តិចចំផ្ទៀងស្ដាប់មើលតើរង្គើស្អី ពេលនោះនៅតែរង្គើ ៗ ដដែល អញនឹកស្មានថាប្រាកដជារង្គើខាងល្វែង កូនប្រសាពីរឿងអ្វី ៗ ហើយមើលទៅ អញសម្ងំដេកលក់ទៅវិញទៅ " ។ ពូជ្រា ខំទប់សំណើចយូរណាស់ហើយ តាំងពីផ្ដើមរឿងបន្តិចមកម្ល៉េះ ដល់ត្រង់នេះគាត់សើចឃឹក ហើយគាត់ដេរប្រែសថា " ខ្មោចអាកំពូជរង្គើ! រឿងអាឯងនេះវាអស្ចារ្យចំឡែកណាស់ ! អាកូនស្មានថារង្គើខាងល្វែង ឪពីរឿងនុង ចំណែកអាឪថារង្គើខាងល្វែងកូនប្រសា ពីរឿងអី ៗ នុងដែរ គិតទៅពួកអាឯងនេះសុទ្ធតែអារង្គើទាំងអស់គ្នា រង្គើទាំងឪ រង្គើទាំងកូន រង្គើប្រណាំងគ្នាហ៊ោងហ្នឹង បានជាវានាំឲ្យគ្នាច្រឡំ ទាល់តែបាត់គោអស់

ឡើង! ថាអាកូនប្រសាចុះគ្នានៅក្មេង គួរតែរង្គើរឿយ ៗ ទៅចុះ , បំណែកការឯងក្បាលកញ្ចាស់ឯណោះ សក់ល្បាយកាចម៍ខ្វាទៅហើយ ក៏នៅតែប៉ូលចិត្តលេងល្បែងរង្គើប្រណាំងដេញដើងនឹងកូនប្រសាធ្វើអីដែរ ៗ

ពេលនោះ ពូប្រុស ដេញដាក់ពូជ្រាំ រត់រង្គើពេញទាំងផ្ទះ ហើយជេរថែមទៀត " អាចោររន្ទះដើមឆ្នាំបាញ់! អាឯងហាឡើងជេរពូជអម្បូរអញ ថាសុទ្ធតែអាកំពូលរង្គើ! អាឯងប្រហែលរង្គើជាងអញទៅទៀត! " ៗ ជ្រាំ: " បើទុកជារង្គើក៏អញរង្គើតែម្នាក់អញ ឥតមានប្រឡំនឹងរង្គើអ្នកណា នាំឲ្យបង់ខាតទ្រព្យរបស់ដូចអាចង្រៃឯងនេះអី " ៗ គ្រានោះ មីងប្រែង លបស្ដាប់ពីក្ដ្រៈជើងក្រានមកត្រុខ្ទះទេខ្ទះ គាត់ក៏ស្រែកថា " ហៅសែនស្អប់អស់យ៉ាងហើយអញ! ស្អប់មនុស្សនិយាយខ្សិបៗ ហើយស្រាប់តែសើចក្អុ, ក្បាលកញ្ចាស់ហើយ នៅតែប្រឡែងគ្នាដូចកូនក្មេង រឿងបាត់គោឯណោះមិនគិតទេ ទៅគិតតែរឿងផ្ដេសផ្ដាសឯណាទៅវិញ " ៗ ជ្រាំតប " ទេអ្នក! គ្មាននិយាយរឿងអីក្រៅពីរឿងចោរលួចគោនោះទេ! អាប្រុស វាកំពុងតែរៀបរាប់ប្រាប់ខ្ញុំពីរឿងហ្នឹងហើយតើ! " ៗ ជ្រាំបន្តសំដី : " ឥឡូវអាឯងបន្តរឿងទៅទៀតមើលតើវាយ៉ាងម៉េចទៀត? " ៗ ប្រុស : " រួចពីនោះអញសម្ងំដេកលក់ទៅវិញទៅ ភ្ញាក់ព្រលឹមឡើងឈ្ងោកមើលក្រោមផ្ទះ ស្រាប់តែបាត់គោអស់រលីង អញហួសចិត្តតែម្ដង ទើបនឹកឃើញថា នុ! រឿង

រង្គើៗ នោះគឺចោរហ៊ានឡើងកដកស្មៀតទុកឃ្លាំងក្រោមផ្ទះសោះ" ។ ពេលកំពុងសន្ទនាគ្នានោះ កូនប្រសាពូប្រេស ត្រឡប់មកពីផ្សារព្រៃវែងស្រែជាមួយប្រពន្ធ មកពួនលបស្តាប់នៅក្រោមផ្ទះ បានឮរឿងនោះសព្វគ្រប់ ក៏នឹកអៀនខ្មាសជាខ្លាំង នឹកមួម៉ៅនឹងពូជ្រាណាស់ទៅទៀត ដោយដឹងថាគាត់បាននិយាយរឿងផែបេខ្លួនរៀបរាប់ពីថ្ងៃមុននោះ ប្រាប់ឪពុកក្មេក ។ បុរសនេះ ក៏គេចខ្លួនដើរទៅលេងផ្ទះគេនៅបុងភូមិបាត់ទៅ ។ ពេលដើរទៅនោះ បុរសពោលរអ៊ូតែម្នាក់ឯងថា " បង់គំនិតតែម្តងហើយអញ ! គិតទៅមនុស្សឈ្មោះជ្រាចង្រៃមែន ! ឯងខំអង្វរគាត់ជាច្រើនដង អង្វរហើយអង្វរទៀតថាសុំឲ្យគាត់លាក់រឿងនេះឲ្យជិត គាត់ថាគ្មានអ្នកណាមាត់ជិតជាងគាត់ទេ ឯងខំជឿគាត់ស្តាប់បិត្តស្លូក ! តាមក្តៅអញចង់តែកាប់ ពូជ្រាចោលឲ្យងាប់ស្រឡះឥឡូវហ្នឹង . . ." ។ ឯកូនស្រីពូប្រេសឡើងតាមជណ្តើរផ្ទះបាយ ទៅជួយដោះដួសបាយនឹងម្ហូបលើកយកមកជូនកៀវនឹងឪពុករបស់ខ្លួន ។ លុះបរិភោគបាយរួចហើយ, ពូជ្រា ផ្តើមនិយាយទៀតថា " អាប្រេស ! ណ្ហើយ ! អញនិយាយម្តងលេងម្តងមែនឥឡូវ អាឯងហៅប្រពន្ធកូនឲ្យជួបជុំមកមើល អញនឹងជួយលៃលកឲ្យបានស្រួល បើអាឯងនៅសល់ប្រាក់កាសខ្លះល្មមទិញគោមួយនឹមទៀតបាន ត្រូវទិញទៅ ដើម្បីធ្វើស្រែក្នុងរដូវវស្សានេះ តែបើទិញបានមកម្តងនេះ ចូរអាឯងប្រុងប្រយ័ត្នឲ្យមែនទែនពីរឿងរង្គើនោះទើបបានស្រួល ។

ប្រុស : “ អាចំកួត ! ព្រើល ៗ ! រឿងគោនោះ មុខតែត្រូវទិញ ហើយ បើមិនទិញបានអ្វីភ្ជួរស្រែ ” ។ ជ្រា “ អើបើដូច្នោះ តទៅមុខទៀត អាឯងធ្វើតាមរបៀបអញបានឬទេ ? ។ ប្រុស : “ ធ្វើយ៉ាងម៉េច ! ” ។ ជ្រា បឺតបារីបង្ហុយផ្សែងទ្រលោមរួចហើយតបថា : “ តាមយោបល់អញថា តទៅត្រូវអាឯងលែលករៀបចំចែករឿងរង្គើនោះឲ្យវាដាច់ស្រឡះពីគ្នាទៅ គឺរបៀបរង្គើលើផ្ទះនោះ មានបែបដូច្នេះ ឬដូច្នោះ ពុំនោះសោតទេ ត្រូវសន្មតគ្នាទៅថា រង្គើល្វែងខាងអាឯងគឺវាយ៉ាងនេះ ឯរង្គើខាងល្វែងកូនប្រសាគឺវាយ៉ាងនោះ ដូច្នេះទៅ ដើម្បីឲ្យស្រណុកបំណាំ កុំឲ្យវាប្រឡំនឹងរង្គើរឿងចោរគាស់ទុកឃ្នងគោក្រោមផ្ទះនោះ, យ៉ាងនេះទើបលែងបាត់គោតទៅទៀត ព្រោះពីមុនវាបានជាឆ្លោយអស់ទៅហើយ ឪពុកក្មេកថារង្គើខាងកូនប្រសា ៗ ថារង្គើខាងឪពុកក្មេក ទាល់តែបាត់គោអស់រលីង, ម៉េចស្ដាប់អញបានទេ អាប្រុស” ។ ពូប្រុស ក្រោកឡើងដាក់ពូជ្រាពីរបីជើង ត្បូកក្បាលពីរបីក្រញាហើយជេរ: “ ខ្មោចអានេះ ! ឯងប្រឹងស្ដាប់ស៊ីកត្រចៀកខ្ទប់ វាទៅតែនិយាយលេងដដែល ៗ ! ” ។ ជ្រា : ” ទេ អញនិយាយនេះសុទ្ធតែមែន ៗ ទាំងអស់ ព្រោះអញចង់ឲ្យអាឯងការពារកុំឲ្យបាត់គោដូចមុនទៀត, តែបើអាឯងមិនស្ដាប់ពាក្យអញ ហើយចូលចិត្តប្រព្រឹត្តតែលេងល្បែងរង្គើ ៗ ឲ្យប្រឡំគ្នាយ៉ាងនេះដដែលទេ អាឯងមុខជាខ្វះគោភ្ជួរស្រែជាប្រាកដពុំខាន” ។

មុននឹងលាសំឡាញ់ត្រឡប់ទៅផ្ទះវិញ, ពូជ្រាបានបន្ថែមសំដីថា ''អាប្រេស ! អញតាំងពីតូចក្រចធារមកដល់ចំណាស់ប៉ុណ្ណេះហើយ មិនដែលបានដឹងឮរឿងផុតកក្ដេក នឹងកូនប្រុសាប្រឡែងគ្នាពាល់តែបាត់គោអស់រលីងយ៉ាងនេះសោះ, ទើបតែមកដល់ពេលនេះ អញបានជួបប្រទះនឹងរឿងអាឯងនេះតែម្ដង អញសុំផ្ដាំក្រោយបង្អស់ថា តទៅថ្ងៃមុខអាឯងត្រូវរៀបចំកែប្រែរបៀបលេង ដូចអញបានប្រាប់ខាងដើមមកហើយអម្បាញមិញនេះ ឲ្យបានស្រួលបួលកុំខាន ដើម្បីចៀសកុំឲ្យបាត់ទ្រព្យរបស់ដូចគ្រានេះទៀត ឥឡូវនេះ អញសុំបញ្ចប់រឿងអាឯងត្រឹមនេះចុះថា '' លេង ១ ធ្វើឲ្យបាត់គោអស់ពីរនឹម '' ។

---

អធិប្បាយសុភាសិត

# ចូលស្ទឹងតាមបត់ ចូលស្រុកតាមប្រទេស

លោក ញ៉ែម - ទឹម រៀបរៀង

---

សុភាសិតទាំងឡាយរបស់ខ្មែរ សុទ្ធតែកើតឡើងដោយស្នាដៃបុព្វបុរសខ្មែរយើងបានបង្កើតទុកមក ព្រោះលោកបានពិសោធឃើញ ឬក៏បានជួបប្រទះនូវឧបសគ្គអ្វីមួយក្នុងការបំពេញបេសកកម្ម ឬ អនុវត្តន៍គោលបំណងអ្វីមួយពុំបានសម្រេច, ពុំបានល្អសមរម្យ ៗ អាស្រ័យហេតុផ្សេង ៗ នេះហើយ ទើបលោករិះគិតបង្កើតជាសុភាសិតនេះឡើងទុកទូន្មានជាស់តៀនក្រើនរំលឹកយើងជាកូនចៅក្រោយ ៗ តមក ឬក៏ទុកជាបទសម្រាប់ពិចារណា ដើម្បីកុំឲ្យប្រព្រឹត្តអ្វីខុសឆ្គង ដែលនាំឲ្យខាតពេល ខាតប្រយោជន៍ ឬអាប់ឱនកេរ្តិ៍ឈ្មោះក៏សឹងមាន ៗ

ដូច្នេះ សុភាសិតថា ចូលស្ទឹងតាមបត់ ចូលស្រុកតាមប្រទេស នេះក៏ជាដំបូន្មានមួយបទ ដែលលោកអ្នកមានការពិសោធន៍ច្រើន បានតែងទុកមក ដើម្បីទូន្មានប្រាប់ផ្លូវដល់បុគ្គលណាដែលទៅកាន់បរទេស ឬដែលធ្វើបេសកកម្មទៅកាន់ស្រុកដទៃផ្សេង ៗ នឹងដល់ជនដែលត្រូវការទៅចាប់ភូមិករនៅកន្លែងថ្មី ក្រៅពីស្រុកកំណើតរបស់ខ្លួន ៗ

ពាក្យទាំងពីរឃ្លាក្នុងសុភាសិតនេះ មានន័យស្រដៀងគ្នា គេអាចប្រៀប

រួមតែមួយឃ្លាបាន ដ្បិតឃ្លាទីមួយគ្រាន់តែជាឧទាហរណ៍នៃអាថ៌របស់ឃ្លាទីពីរប៉ុណ្ណោះ ។

"ចូលស្ទឹងតាមបទ..." ការចូលស្ទឹងគេតែងចូលទៅតាមទំនងតាមរបត់ពត់ពែនរបស់ស្ទឹង ។ ពាក្យនេះរំលឹកដល់នាយនាវិក អ្នកបើកបរទូកកប៉ាល់, សំពៅកេត្រាទាំងឡាយ ឲ្យប្រយ័ត្នចំពោះរបត់ប្រាំង, របត់ខ្សែទឹកឲ្យឈ្លាសវៃរំពៃស្មានថា ត្រង់នេះមានថ្ម ត្រង់នេះមានគល់ដង្គត់ ដែលជាឧបសគ្គពង់កល្បៀននាវាមិនឲ្យទៅមុខរួច ។ ដូច្នេះ អ្នកបើកបរនាវាមិនគេចតាមរបត់ក្រងិបក្រងក់នៃប្រាំងស្ទឹងទេ នោះនាវាមុខជាទៅមុខពុំរួច ឬប៉ះទង្គិចខូចខាតបាក់បែកអសារឥតការ ឬក៏គៀងទៅណាមកណាលែងរួច ។ ពាក្យមួយឃ្លាខាងដើម មានន័យត្រង់ ។ ដូច្នេះឯង គឺជាឧទាហរណ៍ ឬ ជាបទប្រៀបធៀបដល់ពាក្យមួយឃ្លាខាងចុង ញ៉ាំងពាក្យមួយឃ្លាខាងចុងឲ្យច្បាស់ប្រាកដឡើង ។

ចូលស្រុកតាមប្រទេស ស្រុកក្នុងទីនេះ បានន័យថា ទីដទៃក្រៅពីស្រុកកំណើត, ភូមិលំនៅរបស់ពួកមនុស្ស, (ជំនុំចំណោម ឬពិធីបុណ្យអ្វីមួយ)។ ប្រទេស បានន័យថា ទីលំនៅរបស់ជនជាតិសាសន៍ណាមួយ ។ បើតាមសេចក្ដីក្នុងសុភាសិតនេះបានសេចក្ដីថា ទំនៀមទម្លាប់; ច្បាប់, អារ្យធម៌សុជីវធម៌ប្រពៃណី ជាដើម ។ ដូច្នេះ ចូលស្រុកតាមប្រទេស បានន័យថា បើយើងបានទៅកាន់ទីដទៃ, កន្លែង

ដទៃណា ត្រូវយើងប្រព្រឹត្តតាមទំនៀមទម្លាប់ ឬច្បាប់ដែលគេនិយម គេប្រតិបត្តិនៅទីនោះ កន្លែងនោះ ប្រទេសនោះ ព្រោះទំនៀមទម្លាប់ ឬច្បាប់តែងមានសណ្ឋានមានការនិយមខុសគ្នាពេងទីកន្លែង ឬ ប្រទេសមួយនឹងប្រទេសមួយ, ឬដំបន់មួយនឹងដំបន់មួយ ៗ ច្បាប់ខ្លះឬទំនៀមខ្លះដែលយើងយល់ថាប្រសើរថាល្អនៅក្នុងស្រុកយើង ពុំអាចយកទៅអនុវត្តនៅប្រទេសដទៃបានដូចគ្នាទេ ព្រោះមនុស្សយើងមានអធ្យាស្រ័យ, ចរិត, ឬកពាលក្ខណៈខុសគ្នា ។

ដូច្នេះ បើយើងត្រូវការធ្វើដំណើរទៅកាន់ទីណា ប្រទេសណា យើងត្រូវប្រព្រឹត្តឲ្យស្របទៅតាមប្រពៃណីនិយមរបស់ទីនោះ ប្រទេសនោះ យើងត្រូវធ្វើយ៉ាងណាកុំឲ្យឆ្គងខុសពីគេពេក ៗ បើមិនដូច្នោះទេ គេមុខជាសើចតិះដៀលនិន្ទាឲ្យយើង នាំឲ្យយើងអាម៉ាសមុខជាខ្លាំង ចូលរួមសមាគមជាមួយនឹងគេមិនបាន ។

ឧទាហរណ៍ ដូចជាទេសចរទៅលេងប្រទេសអង់គ្លេស ប្រទេសសៀម យើងត្រូវគោរពតាមច្បាប់ប្រទេសនោះ គឺថាយើងត្រូវការដើរ ឬបើករថយន្តប្រកាន់យកខាងឆ្វេង ព្រោះច្បាប់ចរាចរនៅស្រុកគេ ៗ និយមឆ្វេងជាត្រូវ ខុសពីស្រុកយើងយកខាងស្តាំជាត្រូវ ។ ហេតុនេះ បើយើងហើយមិនប្រកាន់យកឆ្វេងតាមច្បាប់ស្រុកគេទេ នោះយើងមុខជាបើកបររថយន្តទៅប៉ះទង្គិចគេ បណ្ដាលឲ្យយើងសងគេឥតគំពើ ហើយក្រុម

កម្រគេនឹងពិន័យធ្វើទោសយើងពុំខាន ។

ឧទាហរណ៍មួយទៀត ដូចជាយើងត្រូវការទៅនៅប្រទេសជ្វា ឬអារ៉ាប់, យើងត្រូវដឹងថា សាសន៍ជ្វាឬអារ៉ាប់ គេកាន់សាសនាខុសពីជាតិយើង ដូច្នេះ,ដើម្បីធ្វើឲ្យគេស្រឡាញ់រាប់អានយើង ហើយយើងក៏អាចស្ថិតនៅក្នុងទីនោះបានសុខផង យើងត្រូវតែនិយមធ្វើតាមគេ ។ បើយើងមិនព្រមធ្វើតាមគេ នោះខ្លួនយើងហាក់ដូចជារស់នៅកណ្តាលព្រៃតែម្នាក់ឯង ។

តើយើងត្រូវប្រតិបត្តិតាមសុភាសិតនេះទាំងស្រុងឬ? ការ ចូលស្រុកតាមប្រទេស មិនមែនបេះតែអាចប្រព្រឹត្តទៅបានស្រួល ៗ ដោយគ្មានការរុញរាក្នុងចិត្ត ឬគ្មានឧបសគ្គខ្លះនោះទេ ប៉ុន្តែ ចូរយើងយល់ថា ធម្មតាសុភាសិតទាំងឡាយ ច្រើនមានគុណសម្បត្តិច្រើនជាងគុណវិបត្តិ ។ ការ ចូលស្រុកតាមប្រទេស នោះនាំមកនូវគុណប្រយោជន៍ដល់ខ្លួនយើងច្រើនជាងគុណវិបត្តិ យើងត្រូវតែធ្វើតាមសុភាសិតនេះ ។ ឧទាហរណ៍ ដូចជាសមណនិស្សិតយើងដែលនិមន្តទៅសិក្សានៅប្រទេសជប៉ុន ត្រូវលាចាកភេទពីបព្វជិតមកជាគ្រហស្ថ ទើបអាចនៅបន្តការសិក្សាតទៅទៀតបាន បើមិនដូច្នោះទេ មានតែនិមន្តត្រឡប់មកស្រុកយើងវិញ ព្រោះនៅគេហស្ថានដែលគេទទួលសមណនិស្សិតយើង ឲ្យនៅសំណាក់អាស្រ័យ, ម្ចាស់ផ្ទះគេពុំយល់នូវសិក្ខាបទរបស់ព្រះសង្ឃខ្មែរយើងទេ ។ ដូច្នេះ នៅពេលឆាន់គេរៀបចង្ហាន់ប្រគេនព្រះសង្ឃយើងឆាន់

ជាមួយនឹងគ្រួសារគេដែលមានប្រុស-ស្រី ហើយសុទ្ធតែគ្រហស្ថទាំងអស់គ្នាតែម្ដង ៗ ហេតុនេះ ដើម្បីចូលរួមរស់ក្នុងគ្រួសារគេបាន ព្រះសង្ឃយើងត្រូវលាចាកសិក្ខាបទ បើមិនដូច្នេះទេ ឃើញថាទាស់ខុសនឹងវិន័យក្នុងព្រះពុទ្ធសាសនា នឹងការរៀនសូត្រ ៗ

ផ្ទុយទៅវិញ បើសិនជាការ ប្រួលប្រកាតាមប្រទេស នោះធ្វើឲ្យយើងទើសទាល់ក្នុងចិត្តខ្លាំងពេក យើងក៏មិនគួរអនុវត្តតាមដែរ បើជាការមិនអនុវត្តតាមនោះគ្មានទោសពៃរ៍ដល់យើងទេ ដូចជានៅក្នុងតំបន់មួយនៃប្រទេសឥណ្ឌូណេស៊ី ហៅតេណាកន់ (ស្រុកលើព្រៃភ្នំ) មានគេជំណាលថា ភ្ញៀវដែលជួយហែសពទាំងឡាយ ត្រូវតែទទួលទានបាយដែលគេដាំដោយទឹក ដែលគេបានយកទៅស្រោចពីលើសាកសពដែលកំពុងរលួយហើយដែលគេត្រងយកពីក្រោមក្ដារមឈូសមកវិញ ព្រោះទំនៀមគេយល់ថា ការធ្វើដូច្នេះ នឹងនាំឲ្យអ្នកដែលនៅរស់អាចទទួលយកគុណសម្បត្តិប្រសើរពីបុគ្គលស្លាប់បាន ៗ ចំពោះឧទាហរណ៍ត្រង់នេះតាមយោបល់ខ្ញុំយល់ថា បើយើងគ្រាន់តែទៅលេងស្រុកនោះ ចំនួនតែ ៤-១០ ថ្ងៃប៉ុណ្ណោះទេ, យើងពុំចាំបាច់ប្រតិបត្តិតាមសុភាសិតនេះទេ ព្រោះការប្រព្រឹត្តខុសនឹងទំនៀមទម្លាប់ គ្មានទោសធ្ងន់ដូចជាការប្រព្រឹត្តខុសនឹងច្បាប់សម្រាប់ជាតិទេ ៗ ប៉ុន្តែទៀតដោយយើងខ្លាចមានជម្ងឺធ្ងន់ព្រោះអំពើដែលធ្វើដូច្នេះ នាំឲ្យទាស់ខុសនឹងក្បួនអនាម័យផង ៗ បើ

បុគ្គលអ្នកស្លាប់នោះ ស្លាប់ដោយពេគធម្មតានោះមិនជាការខាសខុស ប៉ុន្មានទេ ប៉ុន្តែបើបុគ្គលអ្នកស្លាប់នោះ ស្លាប់ដោយជម្ងឺធ្ងន់វិញ ដូចជា អាសន្នរោគ, អុត, របេងជាដើម នោះយើងប្រាកដជាកើតជម្ងឺធ្ងន់ជា ពុំខាន, នាំឲ្យស្លាប់ខ្លួនអសារឥតការ ។ ប៉ុន្តែបើសិនជាយើងបម្រុង ទៅតាំងភូមិលំនៅជាប់រហូតនៅត្រង់នោះ យើងត្រូវតែប្រតិបត្តិតាមសុភាសិតនេះ ។

ជាទីបញ្ចប់ សុភាសិត " ចូលស្ទឹងតាមបត់ ចូលស្រុកតាមប្រទេស" នេះ មានប្រយោជន៍សំខាន់ណាស់ដល់អ្នកទេសចរទៅកាន់ប្រទេសនានាក្នុងលោកនេះ ព្រោះនៅក្នុងកាលៈទេសៈបច្ចុប្បន្ននេះ ដែលប្រទេសយើងកំពុងមានកិត្តិនាមល្បីខ្ទរខ្ទារនេះ, ប្រទេសឯទៀតគេចង់ស្គាល់ប្រជាជនខ្មែរយើងណាស់ ។ ដូច្នេះហើយ បើយើងបានប្រព្រឹត្តអំពើអ្វីពុំគប្បីខុសអំពីទំនៀមទម្លាប់ច្បាប់ស្រុកគេនោះ គេមុខជាពេបជ្រាយ មើលងាយដល់ខ្លួនយើង នឹងដល់ប្រទេសជាតិយើងទាំងមូលទៀត សមដូចសុភាសិតមួយទៀតពោលថា " សំដីសរជាតិ មារយាទសរពូជ" ។

## ផ្នែកកំណត់ដំណើរប្រវត្តិការណ៍

# កំណត់ហេតុមហាសន្និបាតលើកទី ៩

### នៃពុទ្ធិកសមាគម មជ្ឈមណ្ឌលកម្ពុជ

ពុទ្ធសករាជពីរពាន់ប្រាំរយបី ឆ្នាំជូតទោស័ក ខែបុស្ស ថ្ងៃពុធ ៣ កើត ត្រូវនឹងថ្ងៃទី ៤ មករា ១៩៦១ ម៉ោង ១៦ ។

នៅមន្ទីរសំណាក់ការនៃពុទ្ធិកសមាគមកម្ពុជរដ្ឋ សមាជិក-សមាជិកា ទាំងពីរប្រភេទ បាននិមន្ត-អញ្ជើញមករួមប្រជុំ ដើម្បីធ្វើមហាសន្និបាតប្រចាំឆ្នាំគំរប់ទី ៩ ក្រោមអធិបតីភាពនៃលោក ប៉ែយ-ល្ហុត ដើម្បីពិភាក្សារបៀបវារៈដែលបានកំណត់ទុកក្នុងលិខិតនិមន្ត-អញ្ជើញជាមុន ។

របៀបវារៈ

១- ស្ដាប់សេចក្ដីរាយការណ៍របស់គណៈកម្មាធិការនាយក អំពីសកម្មភាពក្នុងឆ្នាំដែលកន្លងទៅហើយ;

២-អំពីស្ថានភាពហិរញ្ញវត្ថុ ក្នុងឆ្នាំ ១៩៦០;

៣-បោះឆ្នោតជ្រើសរើសក្រុមអភិបាលសម្រាប់ឆ្នាំ ១៩៦១;

៤ ការផ្សេង ៗ ។

ដល់ម៉ោង ១៦ និង ៣០ នាទី មានការរាប់ចំនួនសមាជិក-ជិកា តាមប្រការ ៣០ នៃលក្ខន្តិកៈគឺៈ

ក ផ្នែកខាងព្រះសង្ឃ មានសម្ដេចព្រះមហាសុមេធាធិបតី ជ. ណ.

ភោគញាណោ ជាប្រធានចំនួន . . . . . . ៣៧ អង្គ

១ - ផ្នែកខាងគ្រហស្ថមានចំនួន . . . . . ១០៦ រូប

រួមសមាជិកទាំងពីរប្រភេទ . . . . . . . . ១៤៣ រូប

បន្ទាប់មក ដោយឃើញថា សមាជិក-ជិកា បាននិមន្ត-អញ្ជើញ មកកាន់មហាសន្និបាតគ្រប់អង្គប្រជុំ តាមប្រការ ៣៥ នៃលក្ខន្តិកៈហើយ នឹងតាមប្រការ ២ នៃបទបញ្ជា; លោក ព៉យ-ល្អុត ប្រធានគណៈកម្មការ បានប្រកាសសុំបើកពេលប្រជុំ នឹងថ្លែងអំណរគុណចំពោះសមាជិកមហា-សន្និបាត រួចហើយថ្លែងសេចក្តីរាយការណ៍រៀបរាប់អំពីសកម្មភាពដោយ សង្ខេបដែលគណៈកម្មាធិការនាយកសម្រាប់ឆ្នាំ ១៩៦០ បានបំពេញរួច មានសេចក្តីជាអាទិ៍ថា :

១ បានជួយចេញថ្លៃកុសថប្រគេនលោកគ្រូអនុគណ ខេត្តកោះកុង ចំនួនបច្ច័យមួយពាន់រៀល (១០០០៛០០;)

២ បាននិមន្តព្រះសង្ឃ ៦៦ អង្គ ស្វាធ្យាយសត្តប្បករណ៍ ឧទ្ទិស ព្រះរាជកុសលថ្វាយចំពោះព្រះវិញ្ញាណក្ខន្ធ ព្រះករុណាព្រះមហាកាញ្ចន-កោដ្ឋ ដោយមានគ្រឿងបរិក្ខារផ្សេង ៗ ប្រគេនព្រះសង្ឃបំណាយបច្ច័យ ចំនួន ៣ ៧៦២ រៀល;

៣-បានរួបរួមជាមួយព្រះរាជរដ្ឋាភិបាល ព្រមទាំងពុទ្ធបរិស័ទធ្វើបុណ្យ នមស្ការព្រះសក្យមុនីចេតិយ ដាក់បាត្រព្រះសង្ឃប្រហែល ២.០០០ អង្គ;

៤ បានចំរុះខ្ទង់ សុំឲ្យព្រះរាជរដ្ឋាភិបាលទទួលស្គាល់ ពុ.ម.ក. ថាជាសមាគមមានប្រយោជន៍សាធារណៈ ដែលបានសម្រេចដោយព្រះរាជក្រឹត្យលេខ ៤៤៤ ក.ប.វ. ចុះថ្ងៃទី ៣ មិថុនា ១៩៦០;

៥- ក្នុងឱកាសព្រះរាជពិធី បុណ្យថ្វាយព្រះភ្លើង ព្រះករុណាព្រះមហាកាត្ញូនកោដ្ឋ បានបោះពុម្ពព្រះបរមធាយាល័ក្ខណ៍របស់ព្រះអង្គ ចំនួន ៥.០០០ ច្បាប់ ចែកជូនជាសាធារណៈអស់ប្រាក់ ៦.០០០ រៀល;

៦- បានបង្កើតគណៈកម្មការទស្សនាវដ្តី " ពន្លឺពុទ្ធចក្រ " ចេញផ្សាយរាល់ត្រីមាស ចាប់ចេញលេខ ១ នៅថ្ងៃទី ១ មករា ១៩៦១ នេះតទៅ;

៧- បានចូលធ្វើព្រហ្មទាន ប្រគេនសមណនិស្សិតដែលប្រឡងចេញពីសាលាពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ១.០០០ រៀល;

៨- បានផ្តើមធ្វើអង្គកឋិនទាន ដង្ហែទៅវេរប្រគេនសង្ឃដែលគង់ចាំវស្សាក្នុងវត្តលំពង់ឈូក ឃុំកាហែង ស្រុកសំរោងទង (កំពង់ស្ពឺ); ក្រោមការឧបត្ថម្ភនៃសម្តេចព្រះមហាសុមេធាធិបតី ជ. ណ. ព្រះតេជព្រះគុណព្រះពោធិវង្ស ហ - គាត និងព្រះតេជព្រះគុណព្រះឧបាលីវង្ស កៅ - ពន់ ចំណាយប្រាក់ថវិកា ពុ ម. ក. ចំនួន ១០.០០០ រៀល សូមបញ្ជាក់ថា ក្នុងពិធីបុណ្យកឋិនទាននេះ បានបច្ច័យសង្កត់ត្រៃចំនួនជាង ៣០ ០០០ រៀល;

៩- បានធ្វើបុណ្យទក្ខិណានុប្បទាន ឧទ្ទិសកុសលប្រគេនចំពោះ

វិញ្ញាណក្ខន្ធ ព្រះសពព្រះតេជព្រះគុណព្រះសាសនមុនីនាម មាស-កង
ចៅអធិការវត្តពិកទ្វេវង្ស ក្រុងភ្នំពេញ មាននិមន្តព្រះសង្ឃបំរើនព្រះបរិត្ត
ទេសនា វេរកត្ត . . . (ល) ចំណាយបច្ច័យចំនួន ១.០០០ រៀល ដោយ
មានពុទ្ធបរិស័ទជាច្រើន មានសេចក្តីជ្រះថ្លាបានជួយឧបត្ថម្ភផង នៅសល់
បច្ច័យបានចូលក្នុងបេឡាបំរុងនៃវត្តនេះចំនួន ២ ០៥០ រៀលថែមទៀត;

១០- បានរៀបចំផ្គត់ផ្គង់បង្ហាន់ក្នុងឱកាសបុណ្យ អនុសំវច្ឆរមហា-
សន្និបាតលើកទី ១៧ នៃមន្ត្រីសង្ឃចំនួនបច្ច័យ ១០ ០០០ រៀល;

១១- ពុ.ម.ក. បានទទួលអំណោយពីមូលនិធិអាស៊ី ជាប្រាក់
ចំនួន ៩៨.៤០០ រៀល មកបញ្ចូលគ្នានឹងប្រាក់ ពុ.ម.ក. ចំនួនទាំងអស់
៣៦.១៨១ រៀល ៦៨ សេន បូករួមត្រូវជាប្រាក់ចំនួន ៩៣៥ ០៨១ រៀល
៦៨ សេន សម្រាប់ចេញថ្លៃអាហារូបករណ៍ប្រគេនសមណនិស្សិត ៦ រូប
ដែលនិមន្តទៅនៅសិក្សាបន្តវិជ្ជាឯបរទេស,

១២- បានប្រាស្រ័យទាក់ទងជាមួយនឹងព្រះសង្ឃពីរអង្គ នឹងគ្រ-
ហស្ថមួយរូប ជាដំណាងនៃពុទ្ធសមាគមស្រុស៊ី;

១៣- បានប្រាស្រ័យទាក់ទងជាមួយនឹងលោកបណ្ឌិត វិហ្សារដ៍
អាគ្គារដ៍ ជាតិអាមេរិកកាំង ហើយជាសាស្ត្រាចារ្យបង្រៀនខាងផ្នែកពុទ្ធ-
សាសនានៅមហាវិទ្យាល័យ យ៉ាល៍ (University yalle);

១៤- ក្នុងកិច្ចការពារព្រះពុទ្ធសាសនា, ពុ.ម.ក. បានប្រឆាំងនឹងសៀវភៅមួយរបស់ឈ្មោះ គឹម-សែត ដែលមានចំណងជើងថា "ការកែងសេចក្ដីខ្មែរ" មានអត្ថបទប៉ះពាល់ជាខ្លាំងដល់លទ្ធិពុទ្ធសាសនា ។

ដទៃពីនេះ សឹងមានសេចក្ដីសព្វគ្រប់ក្នុងសេចក្ដីថ្លែងការណ៍សម្រាប់ឆ្នាំ ១៩៥០ ដែលឲ្យដំកល់ទុកជាឯកសារស្រាប់ ។ បន្ទាប់មក លោកសេ-ហែម អគ្គហេរញ្ញិកបានថ្លែងពយការណ៍អំពីស្ថានភាពហិរញ្ញវត្ថុក្នុងឆ្នាំ ១៩៦០ ដែលបានបម្លងសេចក្ដីដូចខាងក្រោមនេះ៖

### អំពីប្រាក់ចំណូល

ប្រាក់សល់ត្រឹមថ្ងៃទី ៣១. ១២. ៥៩ ចំនួន . . . ១០១.០៣៩,៥២

- ភាគទាន ក្នុងឆ្នាំ ១៩៦០ „ . . . ៦៤.៧៦៩,០០
- ប្រតិលាភ „ ១៩៦០ " . . . ២៥.២០០,០០
- អំណោយមូលនិធិអាស៊ី „ . . . . ៩៨.៩០០,០០
- អំណោយពីពិធីបុណ្យទមស្តាព្រះសក្យមុនីចេតិយ ១.៧៦៧,៥០
- ឈ្នួលផ្ទះ ពុ.ម.ក. . . . . . . ២៤.០០០,០០

បូករួម . . . . . . ៣១៥.៦៧៦,០២

### អំពីប្រាក់ចំណាយ

- បៀវត្សរ៍បុគ្គលិកពីររូប . . . . . ៤៤.៤០០,០០
- ថ្លៃអាហារូបករណ៍សមណនិស្សិត ៦ រូប . . ១៣៥.០៨១,៦៨

- បោះពុម្ពព្រះបរមធាយាលក្ខណ៍ . . . . . ៦.០០០,០០
- ធ្វើអន្តិកជិនទាន . . . . . . ១០.០០០,០០
- ប្រគល់ឲ្យគណៈកម្មការទស្សនាវដ្តីពន្លឺពុទ្ធចក្រ . ៥០.០០០,០០
- ទទួលបដិសណ្ឋារកិច្ចចំពោះមន្ត្រីសង្ឃ . . . . . ១០ ០០០,០០
- ទិញសម្ភារៈផ្សេង ១ នៅការិយាល័យ . . . . . ៦៥៤,០០
- ទិញទឹកក្រូចទឹកកកប្រគេនមន្ត្រីសង្ឃ . . . . ១.៧៩៩,០០
- ជួយលោកគ្រូអនុគណខេត្តកោះកុង . . . . ១.០០០,០០
- កម្រងផ្កាដង្ហែព្រះសពព្រះមុនីកោសល (សោម-ឈុន) ៤៥០,០០
- ធ្វើកត្តប្រគេនព្រះសពព្រះសាសនមុនី (មាស-កង) ១.០០០,០០
- ឈ្នួលមនុស្សចាំផ្ទះ ពុ ម.ក. . . . . . . ១.៨០០,០០
- បុណ្យថ្វាយព្រះរាជកុសល . . . . . . ២.៥០៨,០០
- ចេញថ្លៃអាកាសយានឲ្យនិស្សិត គួច-គីឡេង . . ៣.៧៥០,០០
- ព្រហ្មទាននឹងវត្តផ្សេង ១ . . . . . . ១.៦២៥,០០

បូករួម . . . ២៧០ ២៦៧ៈ៦៥

កាត់ប្រាក់ចំណាយនេះចេញអំពីប្រាក់ចំណូល ឃើញថាប្រាក់នៅសល់ត្រឹមថ្ងៃទី ៣១. ១២. ៦០ មានចំនួន៖

៣១៥.៦៧៦ៈ០២ ២៧០.២៦៧ៈ៦៥ = ៤៥.៤០៨ៈ៣៤ ៛

សូមមហាសន្និបាតជ្រាបថា ពុទ្ធិកសមាគមមជ្ឈមណ្ឌលកម្ពុជរដ្ឋមានជនជាតិត្រឹមថ្ងៃទី ៣១. ១២. ៦០ ដូចតទៅនេះ៖

- ប្រាក់ផ្ញើយកប្រតិលាភ . . . . . . . . . . ៨៦០.០០០៛,០០
- ប្រាក់ផ្ញើនៅធនាគារ . . . . . . . . . . . ៨៧០៛,០០
- ប្រាក់សល់អំពីការិយបរិច្ឆេទឆ្នាំ ១៩៦០ . . . ៤៥.៤០៨៛,៣៤

រួមទាំងអស់ . . . ៩០៦ ២៧៨៛៣៤

បន្ទាប់មក លោក ពៃយ-លូត បានដំកល់មហាសន្និបាតថា តាមប្រការ ៣ នៃបទបញ្ញាមានថែងថា មុននឹងបោះឆ្នោតជ្រើសរើសគណៈកម្មាធិការនាយកថ្មី, គណៈកម្មាធិការនាយកគង់ដំណែង ត្រូវតែប្រកាសលាលែងតាមសម្ដេចរបស់ប្រធាន ៗ អាស្រ័យហេតុនេះគណៈកម្មាធិការនាយកសម្រាប់ឆ្នាំ ១៩៦០ ដែលមានខ្ញុំជាប្រធាន សូមប្រកាសលាលែងហើយ សូមមហាសន្និបាត ចាត់តាំងក្រុមអធិបាលបណ្ដោះអាសន្នមួយដែលមានប្រធាន ១ រូបនឹង លេខាធិការ ២ រូប ឲ្យធ្វើការបោះឆ្នោតជ្រើសរើសគណៈកម្មាធិការនាយក សម្រាប់ឆ្នាំ ១៩៦១ តទៅ ។

មហាសន្និបាតបានចាត់តាំងលោកហ្លួងសេនិយ អ៊ុក-ផាន់ ឲ្យធ្វើជាព្រឹទ្ធប្រធាន លោកឆៃ-វង្ស និងលោក សៅ-វ៉ែន ឲ្យធ្វើជាលេខាធិការៗ

អស់លោកដែលស្ម័គ្រចិត្ត ឈរឈ្មោះធ្វើជាគណៈកម្មាធិការនាយកសម្រាប់ឆ្នាំ ១៩៦១ ដូចមាននាមខាងក្រោមនេះ៖

១- លោក ពៃយ-លូត
២- " គង់-សរ
៣- លោក នូ-ឯម
៤- " សំ-ថៃម

| | |
|---|---|
| ៥– លោក ប៉េ-យាន | ១៣– លោកស្រី អ៊ុំង-គឹមង៉ន |
| ៦– ” អ៊ុង-គឹមង៉ន | ១៤– ” គង់-សារ |
| ៧– ” សោម-នៅ | ១៥– ” ដុស-ដួង |
| ៨– ” ទា-ដាវលី | ១៦– ” ចាយ-ឆុល |
| ៩– ” ប៊ុន-ថាន់ | ១៧– ” អ៊ុក-ដី |
| ១០– ” តាប-ខាន់ ហៅឆាន់ | ១៨– ” ប៊ិន-ឈឹមសួន |
| ១១– ” សោម-ដាំ | ១៩– ” ព៉ាយ-លុត |
| ១២– លោកស្រី ដោក-ស៊ុដេត | ២០– ” សួរ-ធុំ |

ក្រោយការប្រកាសសុំនាម អស់លោកឲ្យឈរឈ្មោះជាបេក្ខជនរួបហើយលោក ឆៃ-វង្ស លេខាធិការព្រឹទ្ធប្រធានបានប្រកាសថា បើមហាសន្និបាតពុំយល់ទាស់ទេ សូមអនុម័តិយកនាមអស់លោកដែលស្នំគ្រប់គ្រាន់ ២០ រូបនេះ ឲ្យទៅជាគណៈកម្មាធិការនាយកសម្រាប់ឆ្នាំ ១៩៦១ តែម្តង ដោយពុំចាំបាច់បោះឆ្នោតជ្រើសរើសអ្វីឡើយ; ប៉ុន្តែរឿងនេះស្រេចនៅយោបល់ភាគច្រើននៃមហាសន្និបាត បើអស់លោកណាយល់ឃើញថាពុំបាច់បោះឆ្នោតសូមមេត្តាលើកដៃ ។ ខណៈនោះ សមាជិកមហាសន្និបាតបានលើកដៃជាឯកច្ឆន្ទ ពេញចិត្តទទួលយកអស់លោកទាំង ២០ រូប ដែលមាននាមខាងលើ ឲ្យធ្វើជាគណៈកម្មាធិការនាយកនៃពុទ្ធិកសមាគមកម្ពុជរដ្ឋសម្រាប់ឆ្នាំ ១៩៦១ ។

យើងសូមកត់សំគាល់ថា នៅពេលមហាសន្និបាតនេះ សម្តេចព្រះមហាសុមេធាធិបតីជ.ណ.ព្រះសង្ឃនាយកគណៈមហានិកាយ បានធ្វៀតពេលនិមន្តមកថ្លែងអំណរចំពោះសមាជិក-ជិកាមហាសន្និបាត ជាពិសេសចំពោះសមាជិក-ជិកាគណៈកម្មាធិការនាយកសម្រាប់ ឆ្នាំ ១៩៦០–៦១ ដែលស្មគ្រចិត្តយកខ្លួនមកបំរើព្រះពុទ្ធសាសនា ដោយឥតគិតខ្វាចនឿយហត់នឹងខាតបង់ផលប្រយោជន៍ផ្ទាល់ខ្លួន ។ ទីបំផុត សម្តេចបានមានថេរដីកាផ្តែផ្តាំចំពោះសមាជិកទូទៅ ជាពិសេសសមាជិកផ្នែកខាងព្រះសង្ឃសុំឲ្យជួយយកព្រះទ័យយកចិត្តទុកដាក់ ធ្វើយ៉ាងណាឲ្យ ពុ ម.កមានដំណើរដឿនលឿនទៅមុខ កុំឲ្យតាញ់ប្រៀបពុទ្ធសមាគមនៅប្រទេសនានាខ្លះដែលពីដើមពុំធ្លាប់ចាំងដឿកាន់ពុទ្ធសាសនាផង, ឥឡូវនេះពុទ្ធសមាគមនៅប្រទេសនោះៗ ចំរើនរុងរឿងណាស់ទៅហើយ ដូចប្រទេសឥណ្ឌូនេស៊ីបែលហ្ស៊ិក និងម៉ាឡាយូជាដើម ។ សម្តេចបានប្រសិទ្ធិពរជ័យសិរីមង្គលសុំឲ្យអស់លោកសមាជិក-ជិកាវនៃ ពុ ម.ក ទូទៅបានប្រកបដោយពុទ្ធពរ ៤ គឺ អាយុៈវណ្ណៈសុខៈពលៈ គរៀងទៅ កុំបីប្រែក្លាយជាប្រការអ្វីឡើយ ។

គ្មានហេតុអ្វីប្លែក មហាសន្និបាតបានលើកនៅម៉ោង ២១ ។

កត់ហេតុធ្វើនៅមន្ទីរសំណាក់ការ ថ្ងៃ-ខែ ឆ្នាំដូចខាងលើ ។

ព្រឹទ្ធប្រធានៈ អ៊ុក-ផាន់

លេខាធិការ { សៅ-វ៉ែន / ឆៃ-វង្ស

# ពិធីសម្ពោធបើកការអប់រំវិជ្ជាគរុកោសល្យ

កិច្ចបើកពិធីសម្ពោធការអប់រំវិជ្ជាគរុកោសល្យ នៃលោកអាចារ្យបង្រៀនសាលាពុទ្ធិកបឋមសិក្សា ដែលនិមន្តមកពីខេត្តនានានិងក្រុងភ្នំពេញ នៅថ្ងៃសុក្រទី៣ មីនា គ.ស. ១៩៦១ ។

កាលពីថ្ងៃទី ៣ មិនា ១៩៦១ ពេលម៉ោង ៧.៣០ នាទី នៅយ៉ពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត មានកិច្ចបើកពិធីសម្ពោធការអប់រំវិជ្ជាគរុកោសល្យនៃលោកអាចារ្យសាលាពុទ្ធិកបឋមសិក្សា មានចំនួន ៣០០ អង្គ ជាលើកទី ៤ ។

បាននិមន្តនិងអញ្ជើញមកជួបជុំ ផ្នែកខាងបព្វជិត :

- សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ
- សម្តេចព្រះសុធម្មាធិបតី សង្ឃនាយកគណៈធម្មយុត្តិកនិកាយ
- ព្រះតេជព្រះគុណព្រះពោធិវង្ស អគ្គាធិការពុទ្ធិកសិក្សា
- លោកសាស្ត្រាចារ្យ ពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រិត

ផ្នែកខាងគ្រហស្ថ :

សហជីវិន ស៊ុន-បុប្ផកោ រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនៈសិក្សាធិការ

សហជីវិន គួង - សន នាយកការិយាល័យ ក្រសួងធម្មការ

សហជីវិន កែ - មេងហាប់ អគ្គលេខាធិការ ពុទ្ធិកមហាវិទ្យាល័យ

ព្រះសីហនុរាជ

លោកសាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រឹត -

ពេលម៉ោង ៨ ព្រះតេជព្រះគុណព្រះពោធិវង្ស ហួត-តាត អគ្គាធិការ ពុទ្ធិកសិក្សា បានបញ្ចប់ហ្វឹកហ្វឺនការអប់រំវិជ្ជាគរុកោសល្យនេះ មានព្រះពុទ្ធដីកា ដោយសេចក្ដីសង្ខេប ដាស់តឿនក្រើនរំលឹកលោកអាចារ្យជាគ្រូបង្រៀន ពុទ្ធិកបឋមសិក្សាឲ្យព្យាយាមសិក្សាវិជ្ជានេះ ជាយ៉ាងមាំមួនព្រោះជាវិជ្ជា មានសារៈសំខាន់ចំពោះគ្រូបង្រៀន ។

លំដាប់តមកសម្ដេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហា-និកាយ ទ្រង់មានព្រះពុទ្ធដីកាទៅកាន់លោកសាស្ត្រាចារ្យពុទ្ធិកបឋមសិក្សា ថាៈ វិជ្ជាគរុកោសល្យនេះ ដែលជាវិជ្ជាសម្រាប់រចនាមនុស្សធម្មតាឲ្យទៅ ជាគ្រូអាចារ្យ លោកជាសាស្ត្រាចារ្យពុទ្ធិកបឋមសិក្សា ដែលបាននិមន្តមក ទទួលការអប់រំវិជ្ជានេះ សូមបំពេញកល្យាណកិច្ចរបស់លោក ដោយកុំ ប្រមាថចំពោះការសិក្សានេះ ព្រោះជាវិជ្ជាមានប្រយោជន៍ដ៏សំខាន់បំផុត ។

ក្រោយដែលសម្ដេចបានមានពុទ្ធដីកាអំពីលក្ខណៈវិជ្ជាគរុកោសល្យ គោលការណ៍នៃការបង្ហាត់បង្រៀនធម៌សាមគ្គីជាដើម សម្ដេចបានបញ្ចប់ ព្រះសង្កថាៈប្រគេនពរសព្វសាធុការ ចំពោះលោកសាស្ត្រាចារ្យ ដែល បាននិមន្តមកទទួលការអប់រំជាអវសាន ។

រួចទើបសម្ដេចព្រះសុធម្មាធិបតីសង្ឃនាយកគណៈធម្មយុត្តិកនិកាយ

បានមានព្រះពុទ្ធដីកា ទៅកាន់លោកអាចារ្យទាំងឡាយថា: ពេលនេះ ជាពេលដ៏ប្រសើរ លោកអាចារ្យបានមកទទួលការអប់រំវិជ្ជាដ៏វិសេសវិសាល កុំធ្វើវេលានេះឲ្យខូចទៅទទេ គួរតែប្រញាប់ប្រញាល់ធ្វើវេលានេះឲ្យមានសារៈប្រយោជន៍គ្រប់យ៉ាងតទៅ ព្រមទាំងខ្នះខ្នែងប្រឹងប្រែងនូវការសិក្សានេះឲ្យបានចម្រើនទៅមុខជាដើម ។

លំដាប់ពីនេះ សហជីវិន ស៊ុន-បុប្ផកា រដ្ឋលេខាធិការ ក្រសួងធម្មការ នឹងសាសនៈសិក្សាធិការ បានថ្លែងនូវសុន្ទរកថាមួយដូចតទៅនេះ

x

x x

## សុន្ទរកថា

សូមនមស្ការដោយគារវភាពយ៉ាងខ្ពង់ខ្ពស់ ចំពោះសម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ ។

សូមនមស្ការដោយគារវភាពយ៉ាងខ្ពង់ខ្ពស់ ចំពោះសម្តេចព្រះសុធម្មាធិបតី សង្ឃនាយកគណៈធម្មយុត្តិកនិកាយ ។

សូមថ្វាយបង្គំ ចំពោះព្រះតេជព្រះគុណមហាថេរានុត្ថេរៈទាំងឡាយ,

សូមជំរាបអស់លោក-អ្នកទាំងឡាយ,

ខ្ញុំព្រះករុណា ខ្ញុំបាទគាំងនាមក្រសួងធម្មការ នឹងសាសនសិក្សាធិការ សូមថ្លែងនូវកតញ្ញុតាធម៌យ៉ាងជ្រាលជ្រៅ ចំពោះសម្តេចទាំងពីរ

ព្រះអង្គ-ព្រះតេជព្រះគុណ នឹងអស់លោក-អ្នកជាសប្បុរសទាំងឡាយ ដែលបាននិមន្ត នឹងអញ្ជើញមករួមក្នុងកិច្ចបើកពិធីសម្ពោធការអប់រំវិជ្ជាគរុកោសល្យ នៃលោកអាចារ្យជាគ្រូបង្រៀន សាលាពុទ្ធិកបឋមសិក្សា នៃព្រះរាជាណាចក្រ ។ ការនិមន្តនឹងអញ្ជើញមកនេះ ទុកជាកិត្តិយសដ៏ប្រសើរចំពោះក្រសួងនឹងជាកិច្ចដ៏ប្រសើរវិសេស សម្រាប់លើកទឹកព្រះទ័យព្រះតេជព្រះគុណជាអាចារ្យគ្រប់អង្គ ឲ្យមានការព្យាយាមយ៉ាងម៉ឺងម៉ាត់ ចំពោះការសិក្សាវិជ្ជាគរុកោសល្យ នេះតទៅខាងមុខទៀត ។

ការអប់រំវិជ្ជាគរុកោសល្យនេះ មានមកបីលើកហើយ គឺលើកទី ១ ក្នុងឆ្នាំ ១៩៥៦ លើកទី ២ ក្នុងឆ្នាំ ១៩៥៨ លើកទី ៣ ក្នុងឆ្នាំ ១៩៦០ ។ ថ្ងៃនេះជាកាលបរិច្ឆេទនៃការបើកកិច្ចអប់រំវិជ្ជាគរុកោសល្យជាលើកទី ៤ ។ កល្យាណកិច្ចដ៏ប្រសើរនេះ ដែលនឹងកើតមានឡើងបានដោយសេចក្ដីខ្នះខ្នែងនៃព្រះតេជព្រះគុណព្រះពោធិវង្ស អគ្គាធិការនៃពុទ្ធិកសិក្សាលោកយកព្រះទ័យទុកដាក់ចំពោះការរចនាពុទ្ធិកសិក្សា ឲ្យមានវឌ្ឍនភាពតទៅអនាគត ។ បើយើងសង្កេតមើលដាក់លាក់ចំពោះការអប់រំវិជ្ជាគរុកោសល្យទាំងបីលើកកន្លងទៅហើយ យើងអាចបានឃើញនូវលទ្ធផលដ៏ប្រសើរ គឺលោកអាចារ្យពុទ្ធិកបឋមសិក្សា ដែលបាននិមន្តចូលមកអប់រំវិជ្ជានេះហើយ ៗ ដែលមានចំណេះនឹងមធ្យោបាយបង្ហាត់បង្រៀនសមណសិស្សគ្រប់គ្រាន់បរិបូណ៌ ដើម្បីនឹងញ៉ាំងពុទ្ធិកសិក្សាឲ្យមានរបៀបរៀបរយល្អ

ឲ្យមានក្បួនច្បាប់សិក្សាដ៏ប្រសើរដែលបណ្ឌិតខាងវិជ្ជាគរុកោសល្យ បាន
ពិសោធពីអតីតកាលមក បានសុកផលយ៉ាងក្រៃពេក ៗ ក្នុងការ
អប់រំនេះ យើងអាចសង្កេតឃើញ លោកអាចារ្យគ្រូបង្រៀនទាំងឡាយ
ដែលបានមកទទួលការអប់រំរួចមកហើយ ពុំសូវជួបប្រទះនឹងការលំបាក
ក្នុងកិច្ចប្រតិបត្តិមុខងាររបស់លោក ៗ ឯលទ្ធផលនៃការបង្រៀនរបស់
លោកទៀត ក៏ឃើញបានចំរើនដោយប្រពៃដែរ ៗ ព្រោះហេតុដូច្នេះ
ព្រះតេជព្រះគុណគ្រូបង្រៀន ដែលបាននិមន្តមកអប់រំវិជ្ជាគរុកោសល្យនៅ
ទីនេះ ព្រះតេជព្រះគុណនឹងបានក្រេបជញ្ជក់នូវវិជ្ជាដ៏វិសេសវិសាលនេះ
លុះដល់ព្រះតេជព្រះគុណនិមន្តត្រឡប់ទៅកាន់វត្តអារាមវិញ ព្រះតេជព្រះ
គុណនឹងបានញុំាងពុទ្ធិកសិក្សាឲ្យមានពន្លឺភ្លឺស្វាងរុងរឿងតទៅអនាគត ៗ

ព្រះតេជព្រះគុណជាអាចារ្យបង្រៀនទាំងឡាយ ! ខ្ញុំព្រះករុណាសូម
ថ្វាយនូវសេចក្តីស្ញប់ស្ញែងដោយគោរព ចំពោះព្រះទ័យព្រះតេជព្រះគុណ
ដែលបានព្យាយាមលះបង់នូវពេលវេលានិមន្តចូលមកទទួលការអប់រំ ក្នុង
ឱកាសនេះអស់រយៈកាលមួយខែ ដើម្បីជាប្រយោជន៍នៃពុទ្ធិកសិក្សារបស់
យើង ៗ ពិតមែនតែព្រះតេជព្រះគុណបានអប់រំខាងវិជ្ជាគរុកោសល្យ
ល្អហើយ តែបើគ្មានធម៌សាមគ្គី ព្រះពុទ្ធសាសនាប្រទេសយើង មិនអាច
ឡើងទៅកាន់វឌ្ឍនភាពបាន ៗ ដោយហេតុនេះហើយបានជាខ្ញុំព្រះករុ-
ណាមានសេចក្តីសង្ឃឹមយ៉ាងមាំ ចំពោះព្រះតេជព្រះគុណជាគ្រូបង្រៀន

ទាំងឡាយ ជាព្រះអង្គមុខជានឹងប្រព្រឹត្តប្រតិបត្តិតាមធម៌និងវិន័យដែលជាឱវាទនៃព្រះបរមគ្រូសម្មាសម្ពុទ្ធជាម្ចាស់នៃយើង ញុំាងសាមគ្គីធម៌ឲ្យកើតមានឡើងនៅក្នុងខន្ធសន្តាន ជួយរម្ងាប់អធិករណ៍ដែលផុសផុលឡើងឲ្យវិនាសសាបសូន្យ រក្សាសេចក្តីស្ងប់រៀបរយនៅក្នុងវត្តអារាម បំពេញវ[illegible]នភាពនូវកល្យាណកិច្ច សន្តោសគ្នាទៅវិញទៅមកដោយមិត្តភាព ភាតរភាព នឹងសីលធម៌ ទើបព្រះពុទ្ធសាសនាប្រទេសកម្ពុជា នឹងបានអណ្តែតត្រសែត នឹងសន្តិភាព ព្រមទាំងសេចក្តីសុខជាកិយ្យោភាពតទៅ ។

ជាអវសានខ្ញុំព្រះករុណាសូមគុណានុភាពព្រះរតនត្រ័យ ប្រសិទ្ធិពរសូមសម្តេចទាំងពីរព្រះអង្គ ព្រះតេជព្រះគុណគ្រប់អង្គ នឹងអស់លោកអ្នកទាំងឡាយ ប្រកបដោយសុវត្ថិជ័យមង្គលសិរីសួស្តីគ្រប់យ៉ាង ព្រមទាំងអាយុ វណ្ណៈ សុខៈ ពលៈ បដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ; សូមព្រះពុទ្ធសាសនាផ្សាយរីកពេញសាកលលោក ទៅកាន់សន្តិភាពដ៏ប្រសើរ កុំបីអាក់ខានឡើយ ។

ពិធីបើកការអប់រំវិជ្ជាគរុកោសល្យនៃលោកអាចារ្យ ជាគ្រូបង្រៀនសាលាពុទ្ធិកបឋមសិក្សា បានបញ្ចប់នៅពេលម៉ោង ១០ ។

---

# ដំណឹងផ្សាយចេញពីក្រសួងធម្មការ

នៅឱកាសដែលបងប្អូនខ្មែរកម្ពុជាក្រោម បានទទួលរងទុក្ខវេទនា ដោយការជិះជាន់ពីរដ្ឋាភិបាល ង៉ោ-ឌិន-យៀម ហើយបានភៀសខ្លួន មកនៅ វត្តកំផិន ស្រុកគិរីវង្ស ខែត្រតាកែវ ដោយនៅក្នុងចំណោមនោះ មានព្រះសង្ឃចំនួន ១៧ អង្គផង, ដើម្បីជួយសម្រាលព្រះទ័យនៃព្រះសង្ឃ ទាំងនោះ លោក ស៊ុន · បុប្ផកោ រដ្ឋលេខាធិការក្រសួងធម្មការបាននាំ យកគ្រឿងបរិក្ខារ ដែលបានមកពីសេចក្ដីជ្រះថ្លានៃបុគ្គលិកនៅក្រសួងនេះ ទៅប្រគេនកាលពីថ្ងៃទី ២២ មីនា ១៩៦១ គឺព្រះសង្ឃមួយអង្គ ៗ បាន ប្រគេនស្បង់ ១, តែ ១ កញ្ចប់, ស្ករ ១ ប្រអប់, ឈើគូស ១ ហោ, បារី ៥ កញ្ចប់, ទៀន-ធូប, សាប៊ូ ១ ដុំ នឹងផ្ទឹត ១ ។

កាលពីថ្ងៃទី ២៩ មីនា ១៩៦១ លោករដ្ឋលេខាធិការក្រសួងធម្មការ នឹងសាសនសិក្សាធិការ បានចាត់សហការីរបស់លោក ឲ្យនាំយកគ្រឿង បរិក្ខារ ដែលបានមកពីសេចក្ដីជ្រះថ្លា នៃបុគ្គលិកនៅក្រសួងនេះដដែល ទៅជូន សហជីវិនចៅហ្វាយខែត្រតាកែវ ដើម្បីចាត់ឲ្យប្រគេនព្រះសង្ឃ ៦ អង្គជាលើកទី ២ ម្ដងទៀត ដែលទើបនិមន្តមកពីកម្ពុជាក្រោម ហើយ មកគង់នៅ វត្តកំផិន ស្រុកគិរីវង្ស ខែត្រតាកែវ ដែលបណ្ដាលមកពីការ ជិះជាន់នៃរដ្ឋាភិបាល ង៉ោ-ឌិន-យៀម ។ ឯគ្រឿងបរិក្ខារនោះ មានដូចកាលប្រគេនលើកមុនដែរ ។

ព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់នៃសម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិត និងសម្តេចព្រះឧបយុវរាជព្រះប្រមុខរដ្ឋ ។ ក្នុងពិធីបុណ្យនេះ បាននិមន្តព្រះសង្ឃព្រះរាជាគណៈ ឋានានុក្រម-មេគណ-អនុគណ ចៅអធិការខ្លះ ក្នុងព្រះរាជធានីនិងខេត្តក្រៅ ចំនួន ១១១ អង្គ ដើម្បីទទួលទេយ្យទាន ។

នៅថ្ងៃសៅរ៍វេលាម៉ោង ១៩, សម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិត និងសម្តេចព្រះប្រមុខរដ្ឋ ស្តេចយាងមកដល់ ។ ភ្លាមនោះទ្រង់ប្រគេនចីវរចំពោះព្រះសង្ឃចំនួន ១១១ អង្គគ្រង ។ ក្រោយពីការប្រគេនចីវរ, ទ្រង់នមស្ការព្រះរតនត្រ័យ សមាទាននិច្ចសីល និងទ្រង់ព្រះសណ្តាប់ព្រះបរិត្តមួយអន្លើ ដោយពុទ្ធបរិស័ទរួចហើយ សម្តេចព្រះមាតាជាតិ សម្តេចព្រះប្រមុខរដ្ឋ ទ្រង់ព្រះរាជនិវត្តន៍ទៅកាន់ព្រះរាជដំណាក់វិញ ។ តពីនោះមក ពុទ្ធបរិស័ទបាននិមន្តព្រះធម្មកថិក ២ អង្គ សំដែងធម៌ទេសនា បុច្ឆាវិសជ្ជនា ក្រៃពីរ ។

ព្រឹកឡើងថ្ងៃអាទិត្យ វេលាម៉ោង ៩ សម្តេចព្រះមហាក្សត្រិយានី ជាម្ចាស់ជីវិត និងសម្តេចព្រះប្រមុខរដ្ឋ ស្តេចយាងទៅព្រះរាជភានការ ប្រោះព្រំព្រះសុគន្ធវារី លើព្រះហស្តសម្តេចព្រះសង្ឃនាយកជានិម្មិតរូប, នៃការប្រគេនស័ព្ទុការភារ ។

ក្រុមពុទ្ធសាសនបណ្ឌិត្យ បានចូលរួមក្នុងពិធីបុណ្យនេះដែរ សូមប្រសិទ្ធិពរបវរសួស្តី សិរីមង្គលវិបុលសុខមហាប្រសើរគ្រប់ប្រការ ចំពោះសម្តេច សូមសម្តេចជាម្ចាស់មានព្រះជន្មវស្សាយឺនយូរតទៅ ។ ដើម្បីដឹកនាំពុទ្ធបរិស័ទនិងពុទ្ធសាសនានៅប្រទេសកម្ពុជា ឲ្យបានរុងរឿងថ្កើង ត្រចះត្រចង់ផ្សព្វផ្សាយពេញសាកលលោក ។

ពុទ្ធសាសនបណ្ឌិត្យ